សេចក្តីគាំទ្ររបស់មហាមុហ្វទី [illegible]

[illegible]

យើងខ្ញុំបានពិនិត្យ មើលយ៉ាង [illegible] ([illegible]) បកប្រែ ភាសាខ្មែរ [illegible]

[illegible] ។

[illegible]

[illegible] ។

[illegible]
محمد يوسف بن حاج [illegible]

19.8.86 [illegible]

ប្រវត្តិ អាល់គួរអាន القرآن

អ្វីទៅ អាល់គួរអាន (القران) ?

ក) គួរអាន (القران) ប្រែតាមភាសា អារ៉ាប់ថា ការសូត្រ នៅក្នុងព្រះគម្ពីរ គួរអាន (القران) នោះ គឺមានពាក្យសំដីហៅថា អាល់គួរអាន (القرآن) នៅក្នុងព្រះគម្ពីរនោះដែរ ។

ពាក្យថា អាល់គួរអាន (القرآن) នេះគេយកសំពីរ៉ូត (سورة) អាល់គីយ៉ាម៉ាស់ (القيامة) នៅក្នុងបរាទី១៧ ទៅដល់ទី១៨ នៃរឺតនេះ ដូចជាមានបន្ទូលពោលដូចតទៅ (إِنَّ عَلَيْنَا جَمْعَهُ وَقُرْآنَهُ فَإِذَا قَرَأْنَاهُ فَاتَّبِعْ قُرْآنَهُ) មានន័យថា ដោយប្រាកដ នៅលើការប្រមូលរបស់យើង ហើយ ដែលប្រមូលវា (អាល់គួរអាន) ហើយនិងសូត្រគួរអាននោះ (ដើម្បីអោយអ្នកបានការចេះដឹងក្នុងការសូត្រ) ។

ហើយ កាលណាយើងបានសូត្ររួចហើយ ចូរអ្នកឯង (មូហាំម៉ាត់) សូត្រតាមវាចុះ ។

បន្ទាប់មកគេបានយកពាក្យ គួរអាន (القران) នោះ មកសរ-សេរជាកិច្ចដាក់ឈ្មោះជា អាល់គួរអាន (القران) ដែលមានស្រុកក្នុងពិភពលោក គេបានដឹងស្គាល់ ថាមានព្រះគម្ពីរ អាល់គួរអាន (القران) ទៀងរហូតមកដល់សព្វថ្ងៃនេះ ។

អាល់គួរអាន (القران) គឺជាពាក្យសំដីរបស់អល់ឡោះ ស៊ុបហាណាហ៊ូវ៉ាតាអាឡា ដោយមានបុព្វហេតុ ដែលគេបានបញ្ចុះទៅលើណាពី (نبي) មូហាំម៉ាត់ សុឡលឡលឡោហ៊ូអាឡៃហ៊ីវ៉ា-សាល់ឡាំ ។

ហើយទៀត ចំពោះការសូត្រគួរអាន (القران) នេះ ជាកិច្ចប្រតិបត្តិ (العبادة) ដែលនាំអោយបានបុណ្យ ។

ពាក្យសំដីរបស់អល់ឡោះ ស៊ុបហាណាហ៊ូវ៉ាតាអាឡា ដែលបានបញ្ចុះទៅលើណាពី (نبي) ផ្សេងៗពីណាពី (نبي

មូហាំម៉ាត់ សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ នេះគេមិនអោយ
ឈ្មោះថាជា សាល់គួរអាន (القران) ទេ គឺគម្ពីរតៅរ៉ត (تورات) ដែល
គេបានបញ្ចុះទៅលើណាពី (نبي) មូសា ហើយ អ៊ិញជីល (انجيل)
ទៅលើណាពី (نبي) អ៊ីសា ។

ដូចនោះទៀតដែរ ពាក្យសិទ្ធិ របស់ អល់ឡោះ ដែលបានបញ្ចុះទៅលើ
ណាពី (نبي) មូហាំម៉ាត់ សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ក្នុងអាហា.
ទិស គូឌូស៊ី (حديث قدسي) នៅពុំមែនជា គួរអានទេ ។

ប្រៀបសិនជានរណាមួយបានសូត្រហើយ ហាទិស (حديث) នេះពុំ
-មានកើតជាសាកម្ម ប្រតិបត្តិ (عبادة) ទេ ។

១) របៀបគេបញ្ចុះ វ៉ះយូ (وحي) សាល់គួរអាន (القران)
ណាពី (ណាពី) មូហាំម៉ាត់ សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ក្នុង-
ពីពេលការណ៍ ទទួល វ៉ះយូ (وحي) គាត់ក៏បានពេលព្រួយខ្លាំង
ដែលបង្គួរយ៉ាង នៅក្នុងពេលទទួល វ៉ះយូនោះ ដូចតទៅ ៖

១. គោរ៖ (ម៉ាឡៃអ៊ីកាត់) (ملك) បានបញ្ចូល វ៉ះយូ (وحي) នោះ
ទៅក្នុងចិត្ត រ៉ស៊ូលុលឡហ៊ីសុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ក្នុងពេលឃើ-
-ញរូបរាងឡើយ គឺចាំតែគាត់ មិនអាចមើលឃើញរូបរាងក្តី ព្រោះជា វ៉ះយូ
(وحي) ចូលទៅក្នុងចិត្តរបស់គាត់ហើយ ។

ក្នុងជំនឿការណ៍នេះ ណាពី (ណាពី) មូហាំម៉ាត់ សុលឡលឡហ៊ូអាឡៃ-
ហ៊ីវ៉ាសាល់ឡាំ បានពោលថា រូហ៊ុលគូឌូស (روح القدس) បាន វ៉ះយូ
ចូលមកក្នុងចិត្តរបស់អញហើយ (សូម ពិនិត្យមើលក្នុងវគ្គ
(سورة الشورى) ក្នុងឃ្លា ៥១) ។

២. គោរ៖ (ម៉ាឡៃអ៊ីកាត់ «ملك») បាននិម្មិតខ្លួនរបស់វាទៅ
ជារូប បុរសម្នាក់យ៉ាងស្អាត ដើម្បីជឿនោះមកការ ណាពី (نبي) មូហាំម៉ាត់
សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ហើយនៅពេលនោះ ម៉ាឡៃអ៊ីកាត់ (ملك)
នោះឯង បានសម្តែងសូត្រ ពាក្យសិទ្ធិរបស់អល់ឡោះ ដែលសំខាន់ជា
ទីបំផុត ទៅដល់ រ៉ស៊ូលុលឡោះ លុះក្រោយដែល គាត់ចាំយ៉ាងច្បាស់

វ៉ះយូ (وحي) គឺជាពាក្យសិទ្ធិរបស់អល់ឡោះ ដែលបញ្ជូនទៅដល់
ជំពោះណាពី (ណាពី) មូហាំម៉ាត់ តាមរយៈគោរ៖ (ملك)

ហាស់ អំពីការក្បាលដីរបស់អ្នកល្បោះនោះ ។

៣) អាល់វ៉ះយូ (الوحي) បានចូលមកចំពោះ សាវ៉ាប្រុស(ណាពី) មូហាំម៉ាត់ ពេលនោះ ហាក់បីដូចជាមានរវៀមកគ្របដណ្ដប់សង្កត់ពីលើអង្គរបស់សាវ៉ា(ណាពី) នោះឯង ។ អាល់វ៉ះយូ (الوحي) បែបនេះហើយដ៏មហាវិសេសធ្ងន់ ដែលសាវ៉ា:(ណាពី) បានពើបប្រទះនោះ គាប់ជួនពេលនោះ សត្វអូដ្ឋដែលសាវ៉ា:(ណាពី) លោកកំពុងជិះពីលើវានោះ ក៏ទៅជាស្លុតខ្លាំងដួលសន្លប់ លុតជង្គង់ ចុះក្រោមគ្រានោះទៅ ដោយសារអាល់វ៉ះយូ (الوحي) ដែលសង្កត់ធ្ងន់ បានបញ្ចុះទៅលើសាវ៉ា:(ណាពី) ដ៏មហាវិសេសធ្ងន់បែបនោះ ។ នៅក្នុងរឿងនោះ ហ្សៃតប៊ុនសាប៊ិត (زيد بن ثابت) បានតាំងពីណាលរៀបរាប់មកថា៖ អញហើយជាអ្នកសរសេរ កត់ត្រាទុក អំពី អាល់វ៉ះយូដែលគេបានបញ្ចុះទៅលើរ៉ស៊ូលុលឡោះ ។ អញបានឃើញរ៉ស៊ូលុលឡោះ នាពេលដែលគេបញ្ចុះ អាល់វ៉ះយូ (الوحي) នោះឯង ហាក់បីដូចជាដង្ហើមគេបានមកសង្កត់លើសាវ៉ា:(ណាពី) នោះមិនខាន ពេលនោះ ញើសរបស់សាវ៉ា:(ណាពី) ហូរពាសពេញរាងកាយ ហាក់ដូចជាគ្រាប់ត្បូងពេជ្រដូរវៃ ។ ក្រោយពីពេលដែលគេបានបញ្ចុះ អាល់វ៉ះយូ (الوحي) រួចស្រេចបាច់អស់ហើយ ទើបណានោះ រ៉ស៊ូលុលឡោះ ក៏ត្រឡប់មកមានសភាព ដូចដើមវិញ ។

៤). ទេវ: (ملك) បានបង្ហាញរូបរបស់វា ទៅចំពោះ សាវ៉ា:(ណាពី) មូហាំម៉ាត់ សលល្លលឡហ៊ូអាឡៃហ៊ីវ៉ាសាល្លាំ ដោយរូបពិតរបស់វា ដែលព្រះអល់ឡោះបានបង្កើតវាពេលដើមដំបូងនៃរូបរាងរបស់វានោះ ។ ដូចដែលបានរៀបរាប់នៅក្នុងទី២ នោះរួចមកហើយ ។

នៅក្នុងសភាពការ បែបនេះ គេបានរំលឹកនៅក្នុងអាល់គួរអាន (القرآن) នៅវគ្គ (النجم) ឃ្លា ១៤ ថា៖

(ولقد رآه نزلة أخرى عند سدرة المنتهى)

មានន័យថា៖ ពិតប្រាកដ សាវ៉ា:(ណាពី) មូហាំម៉ាត់ បានឃើញវា (ទេវ: (ملك)) នៅពេលចុះម្ដងទៀត នឹងកន្លែង(سدرة المنتهى).

គ) សារប្រយោជន៍ដ៏សំខាន់ៗនៅពេលដែលគេបញ្ចុះអាល់គួរអាន

គេបានបញ្ចុះអាល់គួរអាន (القران) នោះ ដោយបន្តិចម្តងៗ រយៈពេលអស់កាល ២២ ឆ្នាំ ២ខែ ២២ថ្ងៃ ។

ការបញ្ចុះអាល់គួរអានបែបនេះ នឹងធ្វើអោយមានផលប្រយោជន៍ ដូចតទៅ ៖

១) ដើម្បីអោយគេបានយល់ន័យនៅក្នុងអាល់គួរអាន (القران) ដោយងាយស្រួល ហើយនិងងាយទន្ទេញ តាមអាល់គួរអាន នៅក្នុងការបញ្ចុះម្តងៗ និងការបកស្រាយរបស់អាល់គួរអាននោះ ។ ប្រៀបបើសិនណាជាគេបញ្ចុះអាល់គួរអាន (القران) តាំងមូលនោះ ពិតមែនតែពិបាកការទេសៈ ដូចដែល (البخاري) បាននិយាយអំពីនាងអាអ៊ីស្ហាំងមកអោយ (عائشة – رضى الله عنها)

២) នៅក្នុងបទអាល់គួរអាន(القران) នោះ មានបទខ្លះៗដែលអាចបំបាត់ឃ្លាដទៃៗទៀត (الناسخ) ហើយមានបទខ្លះទៀតត្រូវគេបំបាត់ចោល (المنسوخ) ដោយសមហេតុសមផល ទៅតាមសភាពការរស់នៅ ។ ដោយហេតុដូចនេះ បើប្រសិនណាគេបញ្ចុះអាល់គួរអាន(القران) តាំងមូលតែម្តងនោះ ប្រាកដជាមិនអាច (الناسخ) ហើយនិង (المنسوخ) ទាំងឡើយ ដែលអាល់គួរអាន(القرآن) បានបញ្ជាក់មកនោះ ។ នេះជាការយល់ឃើញរបស់អ្នកដែលថា ៖ នៅក្នុងគួរអាន(القرآن)នោះ មាន (الناسخ) ហើយនិង (المنسوخ) ។

៣) ការបញ្ចុះបទអាល់គួរអាន(القران) ម្តងមួយៗនោះ មានន័យសមហេតុសមផល តាមកាលទេសៈដែលកើតមានឡើងនាពេលនោះ

ការបញ្ចុះបទអាល់គួរអានរបៀបនេះធ្វើអោយមានផលប្រយោជន៍ជាច្រើន ហើយលើសអំពីនេះទៅទៀត នឹងអាចធ្វើអោយទាក់ទាញចិត្តរបស់មនុស្សលោក ដោយងាយស្រួល ។

៤) ដើម្បីអោយងាយចាំដល់អ្នកដទៃនូវទន្ទេញអាល់–
–គួរអាន (القران)។

អ្នកដទៃលោកនិយមជឿញ្ញើ (المشركون) បានសួរថា៖ ហេតុដូចម្ដេចបានជាគេមិនបញ្ចុះអាល់គួរអាន (القران) ទាំងមូលនេះតែមួយដងតែម្ដងទៅ? ។ នៅក្នុងសំនួរនេះអល់ឡោះ បានបញ្ជាក់ថា ក្នុងព្រះគម្ពីរ អាល់គួរអាន (القران) ជំពូក (الفرقان) ប្រយោគ ៣២ ។

មានន័យថា ហេតុដូចម្ដេច គេមិនបញ្ចុះអាល់គួរអាន (القران) ទាំងមូលទៅលើព្រះសាវ៉ៈ មូហាំម៉ាត់ តែមួយដងតែម្ដងទៅ? បន្ទាប់មកគេក៏បានឆ្លើយតបមកវិញថា ហេតុដែលយើងបានបញ្ចុះអាល់គួរអាន (القران) នេះ បន្តិចម្ដងៗបែបនេះ គឺដើម្បីអោយចិត្តរបស់ឯង (សាវ៉ៈ មូហាំម៉ាត់) បាននឹងនឹង ។

៥) នៅក្នុងការបង្រៀនសាសនា ដោយបានបញ្ជាក់នូវការឆ្លើយតបសំណួរ ឬការបដិសេធចេញនូវដែលបរលំបៀញ ឬសាកល្បងកើតមាន ដើម្បីអោយពាក្យសំដីរបស់ក្នុងសាសនាច្បាស់ ប្រើប្រាស់នូវការដែលបញ្ចុះអាល់គួរអាន ទាំងមូលនេះតែមួយដងតែម្ដង នៅក្នុងពិធីកម្មលក្ខណ៍បែបនេះ គ្មាននរណាបានសន្និដ្ឋានក៏ប្រែបមិត្ត ទាំងនោះបានទៀយ ។

៦) បណ្ដាបញ្ហាសាសនាដែលគេបានបញ្ចុះនៅម៉ឹកកាស់និងនៅម៉ាឌីណាស់:

គេបានប្រមើលមើលទៅពេលណាបញ្ចុះអាល់គួរអាន (القران) ហើយនោះ ទើបបានគេចែកបណ្ដាបទ្ធ អាល់គួរអាន (القران) នោះទៅជាពីរភាគ

១) ភាគម៉ាក្គីយ៉ះ: បណ្ដាទិត្ត ដែលគេបានបញ្ចុះនៅម៉ឹកកាស់នោះ គឺមុនពេលដែល សាវ៉ៈ មូហាំម៉ាត់ ភាស់វ៉ៃនរទៅម៉ឹកកាស់

- នៅហ៊ីជ្ញីកាស់ បណ្តាវគ្គទាំងនេះគេហៅឈ្មោះថា បណ្តាវគ្គ ម៉ិកគីយ៉ះ (مكية)

៤/ បណ្តាវគ្គដែលគេបានបញ្ចុះ នៅហ៊ីជ្ញីកាស់ ពោលគឺ ពេលដែល ណាពី (ណាពី) មូហាំម៉ាត់ រ៉សិលុលឡប់ហ៊ីសុលឡលឡហ៊ូអាលៃហ៊ីវ៉ាសាល់ឡាំ បានភាសខ្លួនទៅរស់ មាឌីណាស់ហើយនោះ ។

បណ្តាវគ្គទាំងនេះ គេហៅឈ្មោះថា បណ្តាវគ្គ ម៉ាឌានីយ៉ះ (مدنية)

បណ្តាបន្ទាគាល់បន្ទា ម៉ិកគីយ៉ះ ដែលមានចំនួន ១៩/៣០ ភាគនៃគម្ពីរបស់អាល់គួរអាន (القرآن) ដែលមាន ៨៦ វគ្គ ។

និងដំណែកបណ្តាវគ្គ ម៉ាឌីរនីយ៉ះវិញនេះ គេបានប្រមូលដាក់ក្នុង បាន ១១/៣០ ភាគនៃគម្ពីរបស់អាល់គួរអាន (القرآن) ដោយមាន ២៨ វគ្គ

៥/ ការលះដែក រវាងបណ្តាបន្ទាម៉ិកគីយ៉ះ (مكية) និង បណ្តាបន្ទា ម៉ាឌីរនីយ៉ះ (مدنية) ៖

១/ បណ្តាបន្ទាម៉ិកគីយ៉ះ (مكية) ដែលតាកព្យង បន្ទានៃវគ្គនោះ ខ្លីៗ ។ និងដំណែក បណ្តាបន្ទាម៉ាឌីរនីយ៉ះ (مدنية) នេះវិញ មានបន្ទានៃវគ្គ វែងៗ ។

បណ្តាវគ្គ ម៉ាឌីរនីយ៉ះដោយមាន ១១/៣០ ភាគនៃគម្ពីរ សារបស់អាល់គួរអាន(القرآن) នោះគឺមានចំនួន ១៦២៣ បន្ទា ។

និងដំណែកបណ្តាវគ្គ ម៉ិកគីយ៉ះ ដោយមាន ១៩/៣០ ភាគនៃ គម្ពីរសារបស់អាល់គួរអាន (القرآن) នោះដែរ គឺមាន ៤៧៨០ បន្ទា ។

នៅក្នុង ភាគ (جزء) ទី ២៨ ទាំងមូលនេះគេបានបញ្ចុះ នៅហ៊ីជ្ញីកាស់ ។

លើកលែងតែ វគ្គទី ៦០ អាល់មុំតាហ៊ីណះ (الممتحنة) ដែលមាន បន្ទាទាំងអស់នោះ ១៣ បន្ទា ។

ទីងដំណែក ភាគ (جزء) ទី ២៩ គឺវគ្គម៉ិកគីយ៉ះ

លើកលែងតែ វគ្គទី ៧៦ គឺ អាត់ដូះរ៍ (الدهر) ដែលមាន ៣១ បន្ទា

ភាគ (جزء) សាល់ទាំបាល (الإسراء) ហើយនឹង ភាគ (جزء)
សេសសុភាគ (الشعراء) ទាំងពីរនេះ ដែលគាប់ផ្តើមពីដំបូង រហូតទៅ
ចល់ពាក់កណ្តាល. ភាគ (جزء) គេបានបញ្ចុះនៅម៉ាក្កាស់ដែល
មាន ៧៥ ប្លា ។ រីឯដំណែកពីពាក់កណ្តាល រហូតទៅចល់ចុងក្រោយ
បង្អស់នៃគម្ពីរគាល់អ៊ីន ភាគ ទាំងពីរនេះ គេបានបញ្ចុះនៅម៉ាក្កាស់
ដែលមាន ២២៧ ប្លា ។

២/ នៅក្នុងបាសាគានៃបណ្តាប្លា ម៉ាក្កីស៊ីយយ៉ះ គឺយើងបាន
ពាក្យពោលថា: (يا أيها الذين امنوا) ទេ ដែលមានតែរឿងតិច
ហើយនឹងពាក្យពោលថា: (يا أيها الناس) នេះដែលមានគឺជាងបំផុត ៗ
ផ្ទុយទៅវិញ រីឯដំណែក បណ្តាប្លា ម៉ាទីនីយយ៉ះ វិញនេះ ដែល
មានពាក្យពោលថា (يا أيها الناس) នេះតិចច្រើន ហើយនឹងពាក្យពោល
ថា (يا أيها الذين امنوا) នេះ ដែលមានតិចជាងបំផុតទៅវិញ ។

៣/ បណ្តា បាសាគាដែលគេបានបញ្ចុះនៅម៉ាក្កាស់ . ភាគ
ទាំងអស់នៃប្លាទាំងនោះផងដែរ បានបញ្ចូលអំពីជំនឿសក្ការៈ
ចំពោះព្រះជាម្ចាស់តែមួយ , អារម្ភកថា , ផលបុណ្យ ហើយនឹង
បញ្ជាក់ អំពីប្រវត្តិ របស់ ពីរឿង មនុស្សលោក កាលសម័យមុនៗ
ដែលគេបានឆ្លងកាត់ ទុកជាមេរៀន ក្នុងការឧត្តម និងណែនាំ
សភាពភាបសា ។

រីឯបណ្តាបាសាគា ដែលគេបានបញ្ចុះ នៅម៉ាទីណាស់
ហៅថា ប្លាម៉ាទីនីយយ៉ះ វិញនោះ ដែលគេមានបំព្រួញ
រឿង. ដើម្បីនឹងបញ្ជាក់ច្បាប់ អំពីច្បាប់សាសនា ទាំងឡាយពោះ
ជាច្បាប់នីតិប្រពៃណី ជាទីបំផុត ដោយមានទាក់ទងនឹងទំនៀម
ទំលាប់ , ច្បាប់សំរាប់គ្រប់គ្រងពិភពលោកស្ដីជាជា ច្បាប់សង្គមមនុស្ស
លោក , ច្បាប់សំរាប់គ្រប់គ្រងប្រទេសជាតិ , ច្បាប់យុទ្ធសាស្ត្រ
ច្បាប់វិជ្ជាសាស្ត្រ , ច្បាប់សំរាប់ទាក់ទងសាកលលោក ហើយនឹង
ច្បាប់សំរាប់ ទាក់ទង វាងសាសនាផ្សេងៗ ។

បណ្ដាឈ្មោះ អាល់គួរអាន القرآن

អល់ឡោះ ម្ចាស់ទ្រង់បានដាក់ឈ្មោះ ឲ្យព្រះគម្ពីរ របស់ទ្រង់ ថា អាល់គួរអាន(القران) មានន័យថា ការសូត្រ

ក្នុងន័យដែលនេះ ដោយទ្រង់បានមកអំពីការបញ្ជាក់ នៅក្នុងវគ្គ سورة القيامة ត្រង់ឃ្លាទី ១៧ ថា (ان علينا جمعه و قرانه)

និងឃ្លាទី ១៨ ថា (فاذا قرأنه فاتبع قرانه)

ហើយគេបានបញ្ជាក់ យ៉ាងច្បាស់ថែមទៀត អំពីឈ្មោះ អាល់គួរអាន(القران) នេះ នៅមានវគ្គ និងឃ្លា ដូចតទៅ

នៅក្នុងវគ្គទី ១៧ الاسراء ត្រង់ឃ្លាទី ៨៨
ក្នុងវគ្គទី ២ البقرة ត្រង់ឃ្លាទី ១៨៥
ក្នុងវគ្គទី ១៥ الحجر ត្រង់ឃ្លាទី ៨៧
ក្នុងវគ្គទី ២០ طه ត្រង់ឃ្លាទី ២
ក្នុងវគ្គទី ២៧ النمل ត្រង់ឃ្លាទី ៦
ក្នុងវគ្គទី ៤៦ الاحقاف ត្រង់ឃ្លាទី ២៩
ក្នុងវគ្គទី ៥៦ الواقعة ត្រង់ឃ្លាទី ៧៧
ក្នុងវគ្គទី ៥៩ الحشر ត្រង់ឃ្លាទី ២១
ហើយនិងក្នុងវគ្គទី ៧៦ الانسان ត្រង់ឃ្លាទី ២៣

បណ្ដាឃ្លាទាំងអស់ ដែលបាន ពោលពាក្យបញ្ជាក់ ដូចខាងលើនេះ ត្រូវជាព្រះបន្ទូលដ៏ពិតប្រាកដ របស់ អល់ឡោះ ដែលទ្រង់បានបញ្ចុះវ៉ាហ៊ីយ (وحى) ទៅដល់លោកណាពី (ណាពី) មូហាំម៉ាត់ ស៊ូលុលឡោះ សុលឡល់ឡោហ៊ូអាឡៃហ៊ី វ៉ាសាល់ឡាំ នោះឯង ។

ហើយឈ្មោះផ្សេងៗ អំពីឈ្មោះ អាល់គួរអាន(القران) នេះនៅមានទៀត គឺឈ្មោះ ទ្រង់បានដាក់ឈ្មោះ និង ឈ្មោះផ្សេងៗទៀត ដែលនៅក្នុងគម្ពីរ របស់ទ្រង់នេះ ដូចជា ៖

១) គីតាប (كتاب) ឬគីតាបបុលឡោះ (كتاب الله) ដែលមានពាក្យស៊ើ

ទី១ ពាក្យ អាល់គួរអាន (القران)

ដែលបានដឹង ដូចមានពាក្យពោលនៅក្នុងវគ្គទី ២ ឈ្មោះវគ្គ (البقرة) ត្រង់ឃ្លា

ទី ២ ថា (الم ・ ذلك الكتب لا ريب فيه هدى للمتقين)

មានន័យថា: នោះគឺគម្ពីរ ដែលគ្មានការសង្ស័យ នៅក្នុងវា (គម្ពីរ) ឡើយ

គឺ សំរាប់ជាផ្លូវបង្ហាញ ទៅដល់បណ្តាអ្នកកោតខ្លាច ។

២/ អាល់ហ្វួរកន (الفرقان) មានន័យថា ការញែកចេញ

នោះសំដៅបានបញ្ជាក់ ញែកចេញ រវាង ការពិតប្រាកដ ហើយនិង[illegible]

ដែលគេបានពោលរំលឹកក្នុងវគ្គទី ២៥ ឈ្មោះវគ្គ អាល់ហ្វួរកន នៅត្រង់ឃ្លាទី ១. ថា

(تبارك الذى نزل الفرقان على عبده ليكون للعلمين نذيرا)

មានន័យថា: អល់ឡោះ មហាខ្ពង់ខ្ពស់ ដែលបានបញ្ចុះប្រទានមកហើយ

អាល់ហ្វួរកន ទៅលើខ្ញុំរបស់ទ្រង់ ដើម្បីទ្រង់ឲ្យ[illegible] បានក្តីរំលឹក ទៅដល់ពិភព

របស់ពិភពលោក.

៣/ អាល់ហ្ស៊ិករី (الذكر) មានន័យថា: ការរំលឹក

នេះ ដូចដែលបានពោលពាក្យរំលឹកក្នុងវគ្គទី ១៥ ឈ្មោះវគ្គ (الحجر)

នៅត្រង់ឃ្លាទី ៩ ថា:

(انا نحن نزلنا الذكر وانا له لحفظون)

មានន័យថា: ពិតប្រាកដ ហើយយើង យើងនេះ: យើងបាន

បញ្ចុះហើយ សេចក្តីរំលឹក (អាល់គួរអាន) ហើយប្រាកដ[illegible]ត្រូវ

ថែរក្សា[illegible] យើងនឹងថែរក្សា ការពារ វា ។

នៅបណ្តាឈ្មោះទាំង ៤ ដែលគេបានពោលពាក្យបញ្ជាក់

នៅខាងលើរួចស្រេចមកហើយ គឺមានឈ្មោះដែលទើបនឹងល្បី

ល្បាញជាងគេ ហើយដែលគេប្រើសព្វសាកល[illegible] ដែរ.

សំខាន់ជាងគេនោះ គឺឈ្មោះ អាល់គួរអាន (القران) ។

ហើយក្រៅពីឈ្មោះទាំង ៤ ខាងលើនោះទៀត គឺមាន

ឈ្មោះជាច្រើនផ្សេងទៀត សំរាប់ អាល់គួរអាន (القران) ។

ផលប្រយោជន៍នៃការសូត្រ

أَعُوْذُ بِاللّٰهِ مِنَ الشَّيْطَانِ الرَّجِيْمِ

មានន័យថា: ខ្ញុំសុំការពារនិងពឹងទៅនឹង អល់ឡោះ (ស.វ) អោយឆ្ងាយ ពីសាច ដែលត្រូវគេប្រគប់ដោយដុំថ្ម

ពាក្យ (أَعُوْذُ بِاللّٰهِ مِنَ الشَّيْطَانِ الرَّجِيْمِ) នេះមានសារប្រយោជន៍សំខាន់ៗជាច្រើន ដូចអល់ឡោះសុភាណាហ៊ូវ៉ាតាអាឡា មានព្រះបន្ទូលថា (وَإِمَّا يَنْزَغَنَّكَ مِنَ الشَّيْطَانِ نَزْغٌ فَاسْتَعِذْ بِاللّٰهِ سَمِيْعٌ عَلِيْمٌ)

មានន័យថា បើប្រសិនណាហើយ បានមកញុះញង់ពីសំណាក់ឯង នៃការលោភលន់ អោយឆ្ងាយពីសាច ដូច្នេះឯង សុំការពារនិងអល់ឡោះ ពិតប្រាកដទ្រង់ហើយម្ចាស់នឹងលឺមហាឮ ទៀតដឹងលឺមហាពិតនឹង ។

មានទៀត រ៉ស៊ូលុល្លោះ ស្វល្លល្លោហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ មានប្រសាសន៍ថា (أَعُوْذُ بِاللّٰهِ السَّمِيْعِ الْعَلِيْمِ مِنَ الشَّيْطَانِ الرَّجِيْمِ مِنْ هَمْزِهِ وَنَفْخِهِ وَنَفْثِهِ)

អល់ឡោះ និងរ៉ស៊ូលរបស់ទ្រង់ បានច្រើអោយយើងសូត្រ (اعوذ بالله من الشيطان الرجيم) នេះ ជួនសព្វពេលយើងចាប់ផ្ដើមធ្វើអ្វីមួយៗ ដោយហេតុមកពី ព្រោះពីសាចនោះ វាតែងតែរង់ចាំ ចាក់ញុះញង់ ដែលគេនៅក្នុងកិច្ចការរបស់យើងដើម្បីធ្វើនោះ និងធ្វើអោយរស់លេខដ៏ល្អ លោះសប្បុរស ទៅជាការហួស និងក្លាយទៅជាអគតិរបស់ផលបានបុណ្យឡើយ ។.

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

មានន័យថា នឹងព្រះនាម អល់ឡោះ ម្ចាស់ដ៏មហាសប្បុរស ទៀតដ៏មហាមេត្តាប្រណី

គេបានរាប់មកនូវពាក្យសំដី គុណរបស់អាត្មាស់· អល់ឡោះបានប្រទាន សេចក្ដីសុខចំពោះទៅដល់អ្នកទាំងពីរនាក់នោះហើយ .

ដោយប្រាកដថា រ៉ស៊ូលុល្លោះ ស្វល្លល្លោហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ នេះ កាលពីមុនៗមក គាត់ពុំបានដឹងនូវការស់ 33 ពែកពាក់កណ្តាល (سورة) មួយទៅក្នុ

ម្ដង រហូតលោកទាល់តែ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះនៅលើគាត់នឹង (بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ) នេះឯង ទើបគាត់បានដឹង លះវិលក ។

ដូច្នោះដែរ ដោយព្រោះតែ បណ្ដាមិត្តភក្តិរបស់រ៉សូលលុលឡោះ បាន បើកវគ្គព្រះគម្ពីរ អាល់គួរអាន នឹង (بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ) ដោយហេតុនេះហើយ គេក៏តម្រូវអោយសរសេរ (بسم الله الرحمن الرحيم) នេះ ក្នុងកិច្ចចាប់ផ្ដើម ទៅ មុននិយាយស្ដី ។

ដោយសាររ៉សូលលុលឡោះ បាន ពោលពាក្យ បញ្ជាក់ថា :

((كُلُّ أَمْرٍ لَا يُبْدَأُ فِيْهِ بِبِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ فَهُوَ أَجْذَمُ))

មានន័យថា : រាល់កិច្ចការណាក៏ដោយ ដែលគ្មានចាប់ផ្ដើម ក្នុងកិច្ចការនោះ នឹង (بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ) នេះទេ កិច្ចការនោះឯង ក៏គ្មានបានទទួលលទ្ធផលល្អពិតប្រាកដឡើយ ។

ដោយហេតុនេះ បានជាអល់ឡោះម្ចាស់ព្រមទាំងរ៉សូលរបស់ទ្រង់ បាន តម្រូវអោយយើងនឹកដល់ព្រះនាមរបស់ទ្រង់នោះ ដោយសារការនឹកព្រះនាមនេះហើយ ទើបអោយយើងទទួលការចង្អុលបង្ហាញ តម្រង់ផ្លូវ អោយធ្វើ រុងរឿងគ្រប់បែបយ៉ាង ក្នុងការធ្វើនិងការនិយាយស្ដី ហើយដើម្បីកុំអោយយើង ភ្លេចនូវគុណបំណាច់នៃទ្រង់ប្រទានអោយ មកដល់យើងនោះ ដូចជា ទ្រង់បានបង្កើត រូបកាយរបស់យើង នឹងវិញ្ញាណ - ទៀតទ្រង់ប្រទានប្រាជ្ញាស្មារតី និងកម្លាំងកាយនិងសុខភាពដល់យើង ហើយទៀតទ្រង់ផ្ដល់ រស់រាននៃចំណីអាហារ និងការសប្បាយគ្រប់បែបយ៉ាង មកដល់ជីវិតយើង

ឱ មនុស្សលោកអើយ! មិនតែប៉ុណ្ណោះ ទ្រង់បានបង្កើត មេឃ និង-ផែនដី ដែលមាននៅក្នុងលោកនេះ យើងឃើញមានព្រះអាទិត្យ , ព្រះចន្ទ និងតារាភ្លឺចែងចាំង ដើម្បីសម្រាប់ ចែកកាលវេលា អោយមានពេល យប់និងពេលថ្ងៃ ពីមួយសប្ដាហ៍ទៅដល់មួយខែ ពីខែទៅដល់ឆ្នាំ ពីឆ្នាំទៅ ដល់សតវត្ស ។ល។ ម្យ៉ាងទៀតយើងក្រឡេកមើលទៅលើផ្ទៃផែនដី ដែល ពេញទៅដោយ ដើមឈើ-ស្មៅ ទន្លេ និងសមុទ្រ ដោយនៅក្នុងនោះ យើង

ឃើញពពួកសត្វដែលរស់នៅក្នុងទឹក ដូចជាពពួកមច្ឆាជាតិ. មង្គង.ក្តាម
ហើយនិងសត្វល្អិតល្អៀងដទៃទៀតផង។ ឯផែនដីវិញ យើង
ឃើញមានភ្នំ ព្រៃព្រឹក្សា ទន្លេសមុទ្រ ផ្កាឈើណាំណា ដែលប្រកបទៅ
ដោយពណ៌ចម្រុះ ស្រស់បំព្រង និងពពួកសត្វចតុប្បាទ. បក្សាបក្សីគ្រប់ប្រភេទ
ច្រើនឥតគណនា ពុំនោះទៀតឯផែនដីលោកនៅកប់ក្នុងដី សម្បូរណ៍ទៅដោយ
វត្ថុធាតុ ដូចជា: សំណ, ស្ពាន់, ដែក ហើយនិងគ្រឿងលំអរផ្សេងៗទៀត ដូច
ជាប្រាក់-មាស-ត្បូង-ពេជ្រ រីឯលេចឡើងដោយពណ៌សូរ្យប្រណីត ផ្សេង
ពីនេះមានជាតិច្រើន ដូចជាប្រេងកាត, ប្រេងសាំង ដែលគេយកមកប្រើ
ប្រាស់រហូតមកដល់សព្វថ្ងៃនេះឯង។ ទាំងអស់នេះ សុទ្ធសឹងជារបស់
ដែលអុលឡោះជាម្ចាស់ទ្រង់មានមហិទ្ធិឫទ្ធិដ៏ខ្លាំងពូកែ បានបង្កើតសំរាប់
ទុកបំរើសារគុណ របស់មនុស្សលោកយើងនេះ។ ដូចនេះដែរជា.
ពិសេស អុលឡោះទ្រង់បានបង្កើតវត្ថុ ក្តសិទ្ធ ដ៏មហាសារៈ ដែលមាន
ការរកចិត្តកំបាំង សំរាប់ទុកអោយយើងទាំងអស់គ្នា គឺឋាននរក ហើយ
និងឋានសួគ៌ ។

តើដូចម្ដេចទៀត បើសិនជាគ្រប់គ្រាន់ដូចនេះហើយ ចូរអ្នក
រិះគិត: ទៅចំពោះព្រះជាម្ចាស់របស់អ្នក ពីព្រោះអ្វីៗទាំងអស់
នៅក្នុងលោកិយ និងនៅក្នុងឋានបរលោកនោះ សុទ្ធសឹងជារបស់ដែលទ្រង់
បានបង្កើត ហើយមានសារប្រយោជន៍ សំខាន់ៗណាស់ ពុំមែនទ្រង់បង្កើត
ដោយឥតប្រយោជន៍ ហើយនិងជាការលេងសើចទេ ដូចមានកត់ត្រាក្នុង
គីតាប់ដែលអុលឡោះមានព្រះបន្ទូលថា :

((وَمَا خَلَقْنَا السَّمٰوٰتِ وَالْأَرْضَ وَمَا بَيْنَهُمَا لٰعِبِيْنَ))الدخان ٣٨ ٠

មានន័យថា: យើងគ្មានបង្កើតមេឃ និងផែនដី ហើយនិងសព្វ
សារពើអ្វីៗទៀតដែលនៅចន្លោះរវាងទាំងពីរភពនេះ ពុំមែនជាការ
លេងសើចទេ។ ទ្រង់មានបន្ទូលទៀតថា:

((مَا خَلَقْنٰهُمَا إِلَّا بِالْحَقِّ وَلٰكِنَّ أَكْثَرَهُمْ لَا يَعْلَمُوْنَ)) الدخان ٣٩

មានន័យថា: យើងគ្មានបង្កើតទេ ទាំងពីរនា (មេឃ, ផែនដី)

លើកលែងតែបង្កើតនោះ ដោយមានការពិតប្រាកដ ហើយក៏ប៉ុន្តែ មនុស្សភាគច្រើន ពុំបានយល់ដឹងឡើយ ។

ម្ចាស់ទ្រង់គឺមានបន្ទូលបន្ថែមទៀតថា:

((وَمَا خَلَقْنَا السَّمٰوٰتِ وَالْأَرْضَ وَمَا بَيْنَهُمَا بَاطِلًا)) سورة: ص ٢٧ .

មានន័យថា: ហើយយើងគ្មានបង្កើតទេ វេហា ហើយនិងផែនដី ព្រមទាំងអ្វីៗស្ថិតនៅទាំងអស់ ដែលស្ថិតនៅចន្លោះ វេហានិងផែនដី គោលការណ៍ ដោយ: ឥតប្រយោជន៍នោះទេ ។

ទាំងអស់ពិភពលោក គឺស្ថិតនៅក្រោមអំណាចព្រះចេស្ដា របស់ អល់ឡោះជាម្ចាស់ ពុំមានអ្វីៗលាក់បាំង អាច គេចផុតពីកណ្ដាប់ដៃរបស់ ទ្រង់បានឡើយ ។ ដូចនោះហើយ ទើបអ្នកទាំងឡាយ គោរពកោតខ្លាច អល់ឡោះជាម្ចាស់ៈ គឺគោរពអនុវត្តតាមបញ្ញត្តិ ហើយ ចៀសចេញមិនអនុវត្ត នូវកិច្ចការណាដែលទ្រង់ហាមឃាត់ ។

ការបើកកជាវគ្គ الفاتحة

សេចក្តីផ្តើម

វគ្គ الفاتحة នេះ ដែលសម្តែង ស្មោះ ស្មឹកហាណាហ៊ីរ៉ាយរឿ បានបញ្ចុះនៅម៉ាកាស់ ដោយមាន ៧ឃ្លា ។ វគ្គនេះហើយដែលទ្រង់បានបញ្ចុះដំបូងគេ ដោយពោរពេញលក្ខណៈនៅក្នុងគួរអាន ហើយជាដំបូងគេបង្អស់ អំពីបណ្តាវគ្គផ្សេងៗ ទាំងអស់ទៀត ដែលទ្រង់បានបញ្ចុះនៅឯម៉ាកាស់នោះ ។

គេអោយឈ្មោះ الفاتحة នេះ ហេតុដោយវគ្គនេះហើយ គេបានចាប់ផ្តើមបង្រួមគួរអាន» នឹងវគ្គនេះ ។

គេអោយឈ្មោះទៀត អុំមុលគួរអាន أم القران (កំពូលគួរអាន) ឬ អុំមុលគីតាប أم الكتاب (កំពូលគម្ពីរ) ដោយហេតុវគ្គនេះ មានបង្កប់ មូលហេតុ គឺភាពនៃអត្ថន័យរបស់គួរអាន ទាំងមូលទាំងស្រុង ក្នុងការធ្វើសង្ខេបអោយនៃគួរអាននេះ ។

ហេតុដូច្នេះ គេតម្រូវអោយសូត្រ الفاتحة វគ្គនេះពេលធ្វើបន្ទ (الصلاة)

គេបានអោយឈ្មោះវគ្គនេះទៀតជា អេសសាប់អ៊ុលម៉ាសានី السبع المثاني ដែលមាន៧ឃ្លា ដោយហេតុគេសូត្រវគ្គនេះ សារចុះសារឡើងក្នុងការធ្វើបន្ទ។ الفاتحة វគ្គនេះពោរពេញទៅដោយអត្ថន័យ ដែលមានខ្លឹមសារ ជ្រៅជ្រះ ហើយបានឆ្លុះបញ្ចាំង ទៅនឹងវគ្គដែលផ្សេងៗទាំងអស់នៃទៀតក្នុងគួរអាន ដូចជា៖

- ជំនឿ ។ – គឺអោយយើងមានជំនឿជឿជាក់ថា អល់ឡោះនោះជាម្ចាស់ តែមួយគត់ គ្មានគោ ដែលមានបញ្ជាក់ក្នុងវគ្គទី២ស្រាប់ វគ្គនេះទៀតបានបញ្ជាក់ អំពី ការសរសើរ :

- ការសរសើរ ។ – គឺការគោរពសរសើរគ្រប់ជំពូកគ្រប់យ៉ាង ហើយនឹងការខ្លួនអំណរគុណគ្រប់ជីពក ទៅចំពោះអល់ឡោះជាម្ចាស់ ក៏ដោយសារទ្រង់នេះហើយ ដែលបានបង្កើតក្តីសុខដុមរមនា(ជំនឿ) សព្វសារពើទាំងអស់ ក្នុងលោកនា

ក្នុងការដោតជ័យនេះ គឺ ការបកើត ការផ្តល់ ហើយនិងការបង្កើនរឿងនីពេះវិញ្ញា ។

ការសាធារណ៍និងមេត្តា — បញ្ជាក់អំពីករុណារបស់ទ្រង់ ដោយមិនរើសមុខ ទាំងអ្នកមានជំនឿ ហើយនិងអ្នកគ្មានជំនឿ នៅក្នុងលោកីយនេះ។

ការមេត្តាប្រណី .— បញ្ជាក់អំពីទ្រង់ ដែលបានការមេត្តាប្រណី ទៅលើ ចំពោះអ្នកដែលមានជំនឿក្នុងសាសនា នៃថ្ងៃបរលោកនាយ។

ការយុត្តិធម៌ .— បាននបញ្ជាក់នូវការយុត្តិធម៌ ផ្តល់ចំពោះ និងមហិទ្ធិឫទ្ធិ ទាំងពួកគេ នូវមានសាលាក្ដីមួយបានឡើយ ទៀតអំពីសភាពការ កាត់សេចក្ដី នៅថ្ងៃបរលោក។

អំណាចចេស្តា .— បានបញ្ជាក់ នូវអំណាចព្រះចេស្តា របស់ទ្រង់ ហើយ និងបញ្ជាក់ អំពីលក្ខណៈ និងលទ្ធភាពរបស់យើងជាកូន អ្នកសាងម្ចាស់។

និងនេះ ក្នុងប្លង់នេះ អល់ឡោះបានបញ្ជាក់ បង្ហាញប្រើយើងទាំងអស់គ្នាអោយសំពះទៅចំពោះទ្រង់តែមួយគត់ ទៀតត្រូវអោយយើងទាំងអស់គ្នា សុំជំនួយ អំពីទ្រង់តែមួយគត់ដែរ ហើយទៀតបំរាម របស់ទ្រង់ ថាអោយយើងសំពះឬ សុំអ្វី នោះក្រៅអំពីទ្រង់ឡើយ។

ការសុំជំនួយត្រឹមត្រូវ — បានបញ្ជាក់នូវលក្ខណៈពិត្រឹមត្រូវ ផ្តល់ទៅលើរបស់ទ្រង់ ទៀតទ្រង់បានបង្រៀន អោយយើងរកសុំផ្លូវដ៏ត្រឹមត្រូវ អំពីទ្រង់ គឺផ្លូវដែលទ្រង់បានអនុញ្ញាតិយល់ព្រម

ការផ្លូវដ៏ត្រឹមត្រូវ — បញ្ជាក់អំពីផ្លូវដែលទ្រង់ប្រទានអោយទៅដល់អ្នកដែលធ្លាប់មកហើយ គឺជាផ្លូវដែលអ្នកនាំសារ និងបណ្ដាមិត្តភក្តិរបស់គេទាំងនោះ ហើយគឺជាអ្នកប្រណិបត្តិ តាមផ្លូវរបស់អល់ឡោះ ដ៏ស្មោះស ហើយទៀតដែលមិនមែនជាផ្លូវខ្វេង ដែលទ្រង់មានកំហឹងទៅលើអ្នក ដែលគ្មានជំនឿនោះទេ។

الفاتحة

ការបើកវាចាគម្ពីរ

១. និងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់ មហាសាធារណ៍ក្រៃលែងទ្រង់ មហាមេត្តាប្រណី ។ — بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ ١

២. ការសរសើរទាំងអស់នោះ គឺសម្រាប់ អល់ឡោះ ម្ចាស់និងលគ្រប់គ្រងទាំងអស់ ពិភពលោក ។ — اَلْحَمْدُ لِلّٰهِ رَبِّ الْعٰلَمِيْنَ ٢

៣. អល់ឡោះ ម្ចាស់ទ្រង់មហាសាធារណ៍ក្រៃលែង ទ្រង់ មហាមេត្តាប្រណី ។ — اَلرَّحْمٰنِ الرَّحِيْمِ ٣

៤. អល់ឡោះ គឺស្ដេច (កាត់សេចក្ដី) នា ថ្ងៃ បរលោក ។ — مٰلِكِ يَوْمِ الدِّيْنِ ٤

៥. ចំពោះទ្រង់ហើយ គឺ ម្ចាស់ និងល យើងខ្ញុំសំពះ ក្រៃចំពោះទ្រង់ហើយ និងលយើងខ្ញុំ សុំជំនួយ ។ — اِيَّاكَ نَعْبُدُ وَاِيَّاكَ نَسْتَعِيْنُ ٥

៦. សូមលមេត្តាណែនាំ ចំពោះយើងខ្ញុំ ផ្លូវណា និងលត្រឹមត្រូវ ។ — اِهْدِنَا الصِّرَاطَ الْمُسْتَقِيْمَ ٦

៧. ផ្លូវនោះ និងលទ្រង់ប្រទានពរ [illegible] ដល់ពួកអ្នកទាំងនោះ និងលពុំមែនជាផ្លូវ និងលទ្រង់ខឹង លើពួកទាំងនោះ — صِرَاطَ الَّذِيْنَ اَنْعَمْتَ عَلَيْهِمْ غَيْرِ الْمَغْضُوْبِ عَلَيْهِمْ ٧

ហើយពុំមែននាំនូវផ្លូវដែលពួកទាំងនោះ វង្វេងផ្លូវឡើយ ។ وَلَا الضَّالِّينَ

សូមទទួលពាក្យអង្វរ សំណូមពររបស់យើងខ្ញុំ ។ آمِينَ

បិតកប់វិត្គ

គោលការណ៍ដ៏សំខាន់ៗ នៅក្នុងវិត្ត អាល់ហ្វាទីហាះ (سورة الفاتحة) នេះ បានបញ្ជាក់ នូវច្បាប់ទម្លាប់ក្នុងលោកា និងសង្គម ពុំនោះ មានឃ្លាល្អិតៗទៀត ក្នុងគម្ពីរគួរអាន (កូរ៉ាន) បានបញ្ជាក់យ៉ាងច្បាស់ក្លាយជាដូចនេះទៅទៀត បន្ទាប់ពីសូរ៉ត អាល់ហ្វាទីហាះ (سورة الفاتحة) នេះ ។

មនុស្សលោក   الناس

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅ ម៉ឹកាស់ និងមាន ៦ ឃ្លា ។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលគេបានបញ្ចុះវគ្គ الفلق ។ ឈ្មោះ الناس នេះគេបានយកមកពីពាក្យសំខាន់ ដោយហេតុថាមានគ្រប់ៗឃ្លា នៅក្នុងវគ្គនេះ មានពាក្យ الناس បានន័យថា មនុស្សលោក ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ម្ចាស់ទ្រង់បានបញ្ជានៅចំពោះ មនុស្សលោក ដើម្បីអោយអ្នកទាំងនោះ សុំកិច្ចការពារពីទ្រង់ នូវ បិសាចៗ ការគំរាមកំហែងពីអាក្រក់ របស់ ដែល បានចូលទៅដល់ក្នុងវិញ្ញាណរបស់មនុស្សលោក អំពីពួកបិសាចនិងមនុស្ស ។

الناس

មនុស្សលោក

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហាសប្បុរស ទៀតទ្រង់មហាមេត្តាប្រណី ។   بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១. ចូរអ្នកនិយាយថា (ឱ! មូហាំម៉ាត់) ខ្ញុំសុំកិច្ចការពារពីម្ចាស់ ដែលគ្រប់គ្រងលើមនុស្សលោក ។   ١ قُلْ أَعُوْذُ بِرَبِّ النَّاسِ

២ (អល់ឡោះ) ជាស្ដេចលើមនុស្សលោក ។   ٢ مَلِكِ النَّاسِ

៣. ជាម្ចាស់ ដែលមនុស្សលោកត្រូវគោរព សំពះ   ٣ إِلٰهِ النَّاسِ

៤. អំពីពួកបិសាច គោះសំលើយ   ٤ مِنْ شَرِّ الْوَسْوَاسِ الْخَنَّاسِ

ដែលនាំសោយ ក្ខុត និងរវើរវាយចិត្ត

៥ វានោះហើយ ដែលដាស្នូកខ្សឹបសោយ • الَّذِى يُوَسْوِسُ فِى صُدُورِ
រវើរវាយក្នុងដើមទ្រូង មនុស្សលោក ។ النَّاسِ

៦ អំពីពពួក ជីណាត់ អាល់ជិន្ន (الجنة) ٦ مِنَ الْجِنَّةِ وَالنَّاسِ
និង មនុស្សលោក

បើតាមកថាវគ្គ អាល់គួរអាន (القرآن) គេបានចាប់ផ្ដើមឡើងនឹងវគ្គ (الفاتحة) ដែលមានពោលការណ៍សំខាន់ៗ បញ្ជាក់ប្រាប់ទៅមនុស្សលោក

-- ជឿនិងសុំអំពីរសុលឈ្មោះ ជាម្ចាស់ សោយទ្រង់ប្រោសប្រណីដល់ពួកគេ គ្រប់គ្រាន់ ។

-- ទៀតសុំជំនួយអំពីទ្រង់ ។

មិនតែប៉ុណ្ណោះទេ ទៅវិញបិទវគ្គ គួរអាន (القرآن) នេះវិញនឹងវគ្គ (الناس) នេះឯង ដែលមានសំខាន់បញ្ជាក់ប្រាប់ថា សោយមនុស្សលោក សុំកំពាំង អំពីទ្រង់ នូវប្រការទាំងឡាយ ការគំនូសបោក បោកដែលកើតក្នុងលោកនេះ ។

រាត្រីជៀបភ្លឺ الفلق

កំប៉ាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កះ ដែលមាន ៥ ឃ្លា គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الفيل ឈ្មោះ الفلق មានន័យថា រាត្រីជៀបភ្លឺ ។ គេយកឈ្មោះនេះពីពាក្យសំដី ដែលមាននៅក្នុងឃ្លាទីមួយបង្អស់នៃវគ្គនេះ ។

គេបានដាក់ឈ្មោះនេះទៀត បន្ថែមពីលើឈ្មោះ អាប៊ូបុត, អាក់គោរមីហ៊្ស អាលោស ពីនី អ៊ុគរ៉ាស់ និង អាន់ម៉ៀវ ៖

ពិតប្រាកដ ព្រះនោះ រ៉ស៊ូលុលឡោះ សូលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់
-ឡាំ បានធ្វើពិធីបួសបង្គំ (صلاة) ហើយ សាវ:(លាភ្ជី)បាន សូត្រវគ្គ الفلق និងវគ្គ الناس នៅក្នុងរយៈពេលធ្វើដំណើររបស់គាត់ ។

គោលការណ៍សំខាន់ក្នុងន័យរបស់វគ្គ

- អល់ឡោះ បានបញ្ជា អោយយើង សុំកំបាំង ពីទ្រង់ គ្រប់ ទាំងអស់ ពីអ្វីដែលល្អក្រក់ ហេតុ ហេតុ ។

الفلق

រាត្រីជៀបភ្លឺ

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា សប្បុរស ទៀតទ្រង់ មហា មេត្តាករុណា ។

١ قُلْ أَعُوذُ بِرَبِّ الْفَلَقِ

១ ចូរប្រសិនមោហ៊ម្មាត (ឱន ម៉ូហាំម៉ាត់) ចូរសុំ- កំបាំង ពី អល់ឡោះ ម្ចាស់ទ្រង់បង្កើត ពេលរាត្រីជៀបភ្លឺ

២ អំពើការ កង្វក់ នៅ ក្នុង លោក (خلق)។ ٢. مِنْ شَرِّ مَا خَلَقَ

៣ ហើយនិងអំពើការកង្វក់នៃរាត្រី ពេលណាដែលលង់ងឹត ។ ٣. وَمِنْ شَرِّ غَاسِقٍ إِذَا وَقَبَ

៤ ហើយនិងការកង្វក់របស់ស្រីទាំង អស់ ណា ដែលកំពង់ ស្ដុះ មន្តអាគមន៍ទៅ ក្នុងចំណងខ្សែ ។ ٤. وَمِنْ شَرِّ النَّفَّاثَاتِ فِي الْعُقَدِ

៥ ហើយនិងអំពើ ការដែល កង្វក់ របស់អ្នក ឈ្នានីស ក្នុងពេលណាដែលវាបានឈ្នានីស ។ ٥. وَمِنْ شَرِّ حَاسِدٍ إِذَا حَسَدَ

បិតកថាវិភាគ វគ្គ الفلق បានបញ្ជាក់ទៅលើបណ្ដាអ្នកដែលមាន ជំនឿជឿ. ដើម្បីសោយបណ្ដាអ្នកទាំងអស់នោះ សុំកំពាំង និង ការពារ ផុតពី អំពើទាំងអស់នៃការដែលកង្វក់បោះ បោកនៅក្នុងលោក ។

ភាពស្មោះត្រង់ الإخلاص

អំពីវគ្គ វគ្គនេះ គេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន ៤ ឃ្លា។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الناس ឈ្មោះ ណាស់ ។ ហើយសារសំខាន់របស់នៅក្នុងវគ្គនេះ បានបញ្ជាក់ អំពីការជ្រះស្អាត ស្មោះស ទៅម្ចាស់ ដែលមានតែមួយគត់ ប៉ុណ្ណោះ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

គេបានបញ្ជាក់ អំពីការស្មោះសទៅចំពោះម្ចាស់ដែលមានតែមួយគត់ ប៉ុណ្ណោះ ហើយបានបំបាត់គោលគំនិតរបស់ ពួកគ្រិស្ទាន ដែលចូលរួម នៅនិង អល់ឡោះ ហើយក៏បានបញ្ជាក់ថែមទៀត ដោយពិតប្រាកដ គ្មានអ្វីៗណា ដ៏ទៃទៀត មកប្រៀបផ្ទឹម ស្មើនឹងទ្រង់បានឡើយ ។

الإخلاص

ភាពស្មោះត្រង់

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា ករុណាទៀតទ្រង់មហាមេត្តាករុណា ។

١- قُلْ هُوَ اللّٰهُ اَحَدٌ

១. ចូរស្រដីទៅចុះ (ឱន.'មហាំម៉ាត់') ថា អល់ឡោះ នោះហើយជាម្ចាស់តែមួយគត់

٢- اَللّٰهُ الصَّمَدُ

២. អល់ឡោះ នោះហើយ ដែលជ្រកទៅក្នុងលោក សុំពឹង ។

(អល់ឡោះ) ពុំដែលនឹងបង្កើតប្រុសស្រី ហើយនិងពុំដែលនឹងកើតចេញពីស្រុកណា ប្រុសស្រី ណាទៀត ។ ٣ لَمْ يَلِدْ وَلَمْ يُوْلَدْ

ហើយគ្មាននរណាមួយ អាចនឹងប្រៀប ផ្ទឹមស្មើនឹងទ្រង់ បានឡើយ ។ ٤ وَلَمْ يَكُنْ لَّهُ كُفُوًا اَحَدٌ

បរិយាយអត្ថន័យ ចិត្តនេះ បញ្ជាក់ [illegible] ថា អល់ឡោះជាម្ចាស់ដែលមួយគត់ គ្មានពីរ ។

អណ្ដាតភ្លើង اللهب

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الفتح
ឈ្មោះ اللهب មានន័យថា អណ្ដាតភ្លើង ។ គេយកមកសំពីពាក្យ
សំដី لهب ដែលមាននៅក្នុងឃ្លាទី ៣ នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

និពណ៌នារឿងរបស់ឈ្មោះ អាប៊ូឡាហាប់ និងភរិយារបស់វា ដែលបានប្រឆាំងនឹង រ៉សូលុល្លោះ សុំលអូលឡោះហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ។ ចាប់ពីដោកប្ដីប្រពន្ធនេះ ខ្លួនគេគិត បណ្ដាសា បញ្ចូលទៅក្នុងឋាននរក ។ ឯចំណែកទ្រព្យសម្បត្តិរបស់ អាប៊ូឡាហាប់នេះដែល ពុំអាចជួយ - ក្រោះជាសរ់ទោសរបស់គេពីភ្លើងនរកបានឡើយ ។ ដូចនេះដែរ ការប្រឹងប្រែងរបស់គេស្មុរបស់វាក៏គេបានផលប្រយោជន៍អ្វីដែរ ។

اللهب
អណ្ដាតភ្លើង

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហាករុណា ទៀតទ្រង់មហាមេត្តាប្រណី ។

١. تَبَّتْ يَدَآ اَبِيْ لَهَبٍ وَّتَبَّ

១. អន្តរាយហើយទាំងពីរដៃ(អាប៊ូឡាហាប់) និងប្រាកដណាស់អន្តរាយដែរ - ហើយ ។

២. ពុំបានផលប្រយោជន៍ សំរាប់គាត់ អំពី ទ្រព្យសម្បត្តិ របស់គាត់ និងបានរកទៀតដែរ ស្ញើៗ ដែលគាត់បានប្រឹងធ្វើសកម្មភាព ។ مَا أَغْنَىٰ عَنْهُ مَالُهُ وَمَا كَسَبَ ٢

៣ គាត់នោះ គង់តែនឹងចូលទៅក្នុង ឋាននរក ដែលកំពុងឆេះ ឆេះព្រោងព្រាតណាស់ ។ سَيَصْلَىٰ نَارًا ذَاتَ لَهَبٍ ٣

៤ ហើយនឹង ភរិយារបស់គាត់នោះផងដែរ ជាអ្នកនាំ អង្កត់ អុស ។ وَامْرَأَتُهُ حَمَّالَةَ الْحَطَبِ ٤

៥ នៅលើក របស់គាត់ មានខ្សែ ធ្វើពីសរសៃ ត្រាវ៉ា យ៉ាងរឹងប៉ឹង ។ فِي جِيدِهَا حَبْلٌ مِّن مَّسَدٍ ٥

បិទ [illegible] ទំព័រ [illegible] នេះ បានបញ្ចប់ នូវសេចក្តីការណ៍ បកស្រាយ ពាក្យដែល ដែលគួរ ស្រាវជ្រាវ របស់ ឃ្លាំងម៉ាត់ ស្រលម្អលម្អិតម្ភៃ ពីរវគ្គ ទាំងអស់ឆ្នាំ ។

ជំនួយ النَّصْر

ការហៅវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣ ឃ្លា។ គេបានបញ្ចុះវគ្គនេះ នៅម៉ាក្កាស់ ពីមានពិធី ដៃត្រូវបញ្ចូលហ្វេ នៅក្នុងគ្រាមួយនៃពិធី នៅ ហ៊ីជ្ជីលាស់ វគ្គនេះគេបញ្ចុះបន្ទាប់ពីវគ្គ ទីវគ្គ التوبة ។

ឈ្មោះ النصر គេយកមកអំពីពាក្យ សំដី النصر មានន័យថា ជំនួយ ដែលមាននៅក្នុង ឃ្លា អាយ៉ាត់ដំបូងបង្អស់ នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ក្នុងន័យរបស់វគ្គ

សន្យារបស់ អល់ឡោះជាម្ចាស់ ពីជំនួយដល់ជំនួយនោះ មកដល់ យើង ពេលនោះហើយ អ៊ិស្លាមនឹងបានជោគជ័យ ។

- បញ្ជាអំពីទ្រង់ ដើម្បីអោយយើង សំអាត កុំអោយមានការឆ្ងល់ហ៊ិន ក៏ដូចជាមួយទៅចំពោះទ្រង់ ហើយត្រូវអោយមានការសរសើរ ទៅចំពោះទ្រង់ ហើយដែលត្រូវសុំការអភ័យទោសទៅចំពោះទ្រង់ ពេលកើតមានហើយនូវជ័យ ក្នុងដែលនាំមកអោយសប្បាយរីករាយជាថ្មី ។

النَّصْر
ជំនួយ

នឹងព្រះនាមរបស់អល់ឡោះ ម្ចាស់ទ្រង់ មហាសប្បុរសក្រៃលែង មហា មេត្តាប្រណី ។ بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

១. ពេលណាបានមកដល់ហើយនូវ ជំនួយពី ١ إِذَا جَاءَ نَصْرُ اللَّهِ وَالْفَتْحُ

អុលឡោះ ហើយនិងជ័យជំនះ។

២. ពេលនោះហើយ ឯងបានឃើញមនុស្ស
លោក ចូលទៅក្នុងសាសនា អុលឡោះ
ជាពួកជាក្រុម

وَرَأَيْتَ النَّاسَ يَدْخُلُونَ فِي دِينِ اللَّهِ أَفْوَاجًا ٢

៣. ដើម្បីត្រូវស្រដីទៅចុះ (ស៊ូបហាំហ៊ក)
និងសរសើរ សរសើរ ទៅចំពោះ ម្ចាស់ឯង
ហើយ សុំអភ័យទោស ទៅចុះ ពីព្រោះម្ចាស់
ដោយប្រាកដប្រជាហើយ គឺម្ចាស់ នឹងតែ
អភ័យទោស ។

فَسَبِّحْ بِحَمْدِ رَبِّكَ وَاسْتَغْفِرْهُ إِنَّهُ كَانَ تَوَّابًا ٣

ប្រវត្តិកថាវគ្គ . វគ្គនេះបានជះបញ្ចាំងនូវសញ្ញាគាត់ ទៅពីកិច្ចការ
របស់ ណាបី (ណាប៊ី) មូហាំម៉ាត់ ស៊ុលឡលឡហ៊ុអាឡៃហ៊ីវ៉ាសាល្លាំ នោះ
ជា ម្នាក់ វិលូល និងលើផែនដីអស់របស់កាលទៅហើយ ។

បណ្ដាអ្នកដែលគ្មានជំនឿ الكافرون

កាហ៊ាវគ្គ វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន ៦ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الماعون ឈ្មោះ الكافرون មានន័យថា បណ្ដាអ្នកដែលគ្មានជំនឿ ។

គេយកមកអំពីពាក្យសំដី الكافرون ដែលមាននៅក្នុងឃ្លាទីមួយ បង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

សិក្ស ម្ចាស់ដែល មូហាំម៉ាត់ រ៉ស៊ូលលុល្លហ៊ូកាន់សាសនា ព្រមទាំងអ្នកដែលតាមគាត់ មានសិទ្ធិនោះ ពុំដែលនិងម្ចាស់ដូច អ្នកគ្មានជំនឿនោះសិទ្ធិនេះ ។

ហើយលោកបានពន្យល់ថា រ៉ស៊ូល មិនសិទ្ធិនឹងនាំ ដូចអ្នកដែលអ្នកគ្មានជំនឿ សិទ្ធិនោះឡើយ

الكافرون
បណ្ដាអ្នកដែលគ្មានជំនឿ

ដោយព្រះនាមអល់ឡោះ ម្ចាស់ប្រណីមហា សាណាស់ទៀតផង មហាមេត្តាបំផុត

بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ

១ ចូរស្រដីទៅថា (មូហាំម៉ាត់) អើ! បណ្ដាអ្នកដែលគ្មានជំនឿ ទៅលើសាសនា (របស់អល់ឡោះ) ។

١ قُلْ يَٰٓأَيُّهَا ٱلْكَٰفِرُونَ

២. ខ្ញុំមិនសំពះទេ អ្វីដែលអ្នកឯងទាំងអស់គ្នានេះ កំពុងតែសំពះ ។ — لَآ أَعْبُدُ مَا تَعْبُدُونَ ٢

៣. ហើយអ្នកឯងទាំងអស់គ្នា គ្មានសំពះទេ នូវអ្វីដែលខ្ញុំសំពះ ។ — وَلَآ أَنتُمْ عَٰبِدُونَ مَآ أَعْبُدُ ٣

៤. ហើយខ្ញុំមិនដែលសំពះទេ អ្វីដែលអ្នកទាំងអស់បានសំពះនោះ ។ — وَلَآ أَنَا۠ عَابِدٌ مَّا عَبَدتُّمْ ٤

៥. ហើយអ្នកឯងទាំងអស់គ្នា គ្មានសំពះទេ អ្វីដែលខ្ញុំសំពះ ។ — وَلَآ أَنتُمْ عَٰبِدُونَ مَآ أَعْبُدُ ٥

៦. សំរាប់អ្នកឯង សាសនាអ្នកឯង ហើយ សំរាប់ខ្ញុំ សាសនាខ្ញុំ ។ — لَكُمْ دِينُكُمْ وَلِيَ دِينِ ٦

បិតកបិវទិគ្គ វគ្គនេះបានឆ្លុះបញ្ចាំង នូវសភាពការណ៍ អស់សង្ឃឹម របស់ បណ្តាអ្នកដែលគ្មានជឿ ក្នុងការប្រឹងប្រែងរបស់គេ ដើម្បី អោយបរសាទៈ(ណាប្តី) មូហាំម៉ាត់ សូលឡលឡោហ៊ុអាលៃហ៊ីវ៉ាសាល់ឡាំ នោះ លះបង់ចោល ក្នុងការតស៊ូ សំគាល់ហៅជំពោះសាសនារបស់ពួកគេ ។

ស្រះស្រង់ពោរពេញទៅដោយទឹក សុខដុមរមនា ([illegible]) الكوثر

កប៉ាវិត្ត វិត្តនេះគេបានបញ្ចុះនៅម៉ាក្កះ ដែលមាន ៣ បន្ទូល ។

គេបានបញ្ចុះវិត្តនេះក្រោយពីពេលដែលគេបានបញ្ចុះវិត្ត العاديات ឈ្មោះ الكوثر នេះមានន័យថា សុខដុមរមនា ដែលច្រើន ។

គេយកមកអំពីពាក្យសំដី الكوثر ដែលមាននៅក្នុងបន្ទូលទីមួយបង្អស់នៃវិត្តនេះ ។

វិត្តនេះសំរាប់អាក់អាញចិត្តសាវ.(ហាត្ថ) មូហាំម៉ាត់ សុលឡុលឡហូអាឡៃហ៊ីវ៉ាសាល់ឡាំ ដើម្បីកោយបានក្ដីសុខសប្បាយរីករាយ ។

គោលការណ៍ទីសំខាន់ៗក្នុងន័យរបស់វិត្ត

រសូលឡោះ បានប្រទានវត្ថុសុខដុមរមនា ជាច្រើន ហេតុដូចនេះហើយ ចូរសំពះនិងធ្វើ បរាភសត្វ(قربان) ចុះ ដែល! មូហាំម៉ាត់ ។ សត្រូវរបស់អ្នកដែលមានការតាំងប្រឆាំង ព្រោះទាល់តែដល់ថ្ងៃបរលោក ហើយសង្ឃឹមបានកិត្តិយសកេរ្តិ៍ឈ្មោះ នឹងត្រូវស្លាប់ជាទីបំផុត នៅក្នុងឋានលោកនិងឋានបរលោក ។ ផ្ទុយទៅវិញនោះ ពុំសូវដូចការគោរពប្រណិប័តន៍របស់អ្នក ដែលល្អប្រពៃយ៉ាងដូចនោះឡើយ ។

الكوثر
ស្រះស្រង់ពោរពេញទៅដោយទឹក សុខដុមរមនា

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

នឹងព្រះនាមអល់ឡោះ ម្ចាស់ប្រណីមហាសាណាស់ ទៀតប្រណីមហាមេត្តាប្រណី

១. ពិតប្រាកដហើយ យើងបានអោយទៅឯង ហើយ (ស្ទឹងកាវ៉ស៊ើ) ស្រះមួយដែលពោរពេញ ទៅដោយវត្ថុ សុខុម្ពរម្យតា (និអ៊ំ) إِنَّا أَعْطَيْنَاكَ الْكَوْثَرَ ١

២ ហេតុនិងនេះ ចូរឯងគោរពសំពះថ្វាយបង្គំ (សឡាតុ) ទៅចំពោះម្ចាស់របស់ឯង ហើយនឹងបំ-ពេញការលើកកិច្ច ស្ទួតការ (قربان) ចុះ ។ فَصَلِّ لِرَبِّكَ وَانْحَرْ ٢

៣. ពិតប្រាកដ អ្នកដែលជាសត្រូវនឹងឯង នោះ មុខតែនឹងវិភ្លូបប្រាស នឹងមហន្តរាយ ភាពឥតមានឡើយ ។ إِنَّ شَانِئَكَ هُوَ الْأَبْتَرُ ٣

បរិកថាវិត្ថុ វិត្ថុនេះបានដឹងញ អោយយើងធ្វើគិច្ចប្រតិបត្តិ (عبادة) ទៅចំពោះអល់ឡោះ ហើយនិងធ្វើយាគសត្វ (قربان) ដើម្បីភាពស្គាល់ ចង្អុលបង្ហាញអោយឃើញការដឹងគុណ ទៅលើវត្ថុ សុខុម្ពរម្យតា (និអ៊ំ) ដែលអល់ឡោះបានប្រទានអោយមកដល់ យើង និងបាត់ទុក្ខក្រោយ ឥតគុណតា ។

របស់របរសំរាប់ប្រើប្រាស់ الماعون

មក្កាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ និងមាន ៧ បន្ទូល ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ التكاثر

ឈ្មោះ الماعون មានន័យថា របស់របរសំរាប់ប្រើប្រាស់ ។

គេបានដកយកអំពីពាក្យសំដី الماعون ដែលមាននៅក្នុងបន្ទូលទី៧នៃវគ្គនេះ

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

បញ្ជាក់ អំពីលក្ខណៈរបស់ មនុស្សលោកខ្លះៗ ដែលគេក្រឡេក មើលទៅ យ៉ាងជាក់ច្បាស់ថា ចិត្តនៅក្នុង ការភូតភរកុហក ទៅនឹងសាសនា ។

ការគ្រោះថ្នាក់ ធ្លាក់ទៅដល់ បណ្ដាអ្នកដែលធ្វើឪជីថ្វាយបង្គំ (المصلين) ដោយការធ្វើវារាប ក្នុងសេចក្ដីឈ្មោះស ។

الماعون

របស់របរសំរាប់ប្រើប្រាស់

ដោយព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា សាការុណ្យដ៏ទ្រង់ មហា មេត្តាប្រណី ។	بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ
១ តើឯងបានឃើញដែលរឺទេ? (ឱ! មូហាំម៉ាត់) អ្នកដែលភូតភរនឹងសាសនា ។	١ أَرَأَيْتَ الَّذِي يُكَذِّبُ بِالدِّينِ
២ គឺជានោះហើយ អ្នកគោះដង ដែលជាអ្នកកំព្រា ក្មេងកំព្រា ។	٢ فَذَلِكَ الَّذِي يَدُعُّ الْيَتِيمَ

٣- وَلَا يَحُضُّ عَلَىٰ طَعَامِ الْمِسْكِينِ

៣ ហើយអ្នកនោះឯង ពុំមានការយកចិត្ត
ទុកដាក់ ជួយផ្ដល់ នូវ ចំណីអាហារ ទៅ
ជនគ្រោះ និងជនក្រីក្រ ។

٤- فَوَيْلٌ لِّلْمُصَلِّينَ

៤. ទើបមានវិនាស ទារុណកម្ម សំរាប់បណ្ដា
អ្នកសឡាត ធ្វេយបង្អី (صلاة)

٥- الَّذِينَ هُمْ عَن صَلَاتِهِمْ سَاهُونَ

៥ ដោយសារអ្នកទាំងនោះ បានភ្លេចប្រហែស
ក្នុងការសឡាត ធ្វេយបង្អី (صلاة)

٦- الَّذِينَ هُمْ يُرَاءُونَ

៦. អ្នកទាំងនោះ បានបំពេញ ការលើកកិច្ច
សំរាប់សំដែង ដោយមនុស្សលោកនោះឃើញ

٧- وَيَمْنَعُونَ الْمَاعُونَ

៧. ហើយអ្នកទាំងនោះ បានហាមឃាត់ ការផ្ដល់
យកចិត្តនៃការបរិច្ចាគទាន (الزكاة)

ប៉ារីពកពីប៉ារីក ៧ គឺ الماعون បានបញ្ជាក់យ៉ាងច្បាស់លាស់ ពីលក្ខណៈ នៃមនុស្សលោក ដោយខ្វះលក្ខណៈ ដែលកើតឡើង បណ្ដា អ្នកទាំងនោះ គ្រោះមោហ៍ក្នុងការបរិភោគប្រៀបបែបយ៉ាង ។

បណ្តាក្រុមគូរ៉ៃស القريش

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ៤ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ التين ។
ឈ្មោះ قريش មានន័យថា ក្រុមគូរ៉ៃស ។
គេយកមកតាំងពីពាក្យសំដី ដែលមាននៅក្នុងបន្ទាត់ដំបូងបង្អស់ ។
ការបញ្ជាក់ ៖ បណ្តាក្រុមគូរ៉ៃស គឺក្រុមដែលគេលើកដំកើង ហើយគេ ឧបត្ថម្ភសំណាង ដោយទឹកព្រះហស្ត ភាក់ព្វាស់ (مكة)

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ការរំឭកទៅបណ្តាក្រុមគូរ៉ៃស អំពីគុណនិងអំណោយ (نعمة) ដែលអល់ឡោះម្ចាស់ បានប្រទានទៅឲ្យដល់ពួកគេទាំងនោះ ដូចនេះហើយ គេបានបញ្ជា ឲ្យក្រុមគូរ៉ៃសនេះឯង សំពះគោរពទៅដល់អល់ឡោះម្ចាស់ ។

القريش

បណ្តាក្រុមគូរ៉ៃស

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ
សប្បុរសធំធេង ទ្រង់មហាលើសលប់ ។

១. ហេតុការណ៍ របស់ក្រុមគូរ៉ៃស បានចុះសម្រុងគ្នា ។ لِإِيلَافِ قُرَيْشٍ ١

២. ពីក្រុមទាំងនោះ បានចុះសម្រុងគ្នាក្នុងការធ្វើ إِيلَافِهِمْ رِحْلَةَ الشِّتَاءِ وَالصَّيْفِ ٢
ដំណើរ នារដូវត្រជាក់ និងរដូវក្តៅ

៣ ទើប ចូរពួកទាំងអស់នោះ គោរពចុះ ទៅម្ចាស់នៃផ្ទះនេះ (كعبة) فَلْيَعْبُدُوا رَبَّ هَٰذَا الْبَيْتِ ٣

៤ ទ្រង់ដែលបានប្រទាន ចំណីអាហារទៅ ជូនពួកគេទាំងអស់នោះ ដើម្បីបំបាត់ នូវការស្រេកឃ្លាន ហើយទ្រង់បានប្រទាន ពីសុខក្សេមក្សាន្ត ទៅលើពួកគេទាំងនោះ ដើម្បីនឹងបំបាត់ នូវការខ្លាចគោកក្រង់ ។ الَّذِي أَطْعَمَهُم مِّن جُوعٍ وَآمَنَهُم مِّنْ خَوْفٍ ٤

ចំណាំ កំណត់ចិត្ត ចិត្ត قريش បានបញ្ជាក់ អំពីជីវភាពរស់នៅ នៃក្រុមគូរ៉ៃស ព្រោះនាមួយនេះ គេនិងធ្វើជំនួញ នូវការចាំបាច់ខាត ទៅមកទៅ បណ្ដាអ្នកទាំងនោះ ដើម្បីនឹងបានយកប្រយោជន៍ ទាម ។

ដំរី　　الْفِيلْ

កប៉ាវិត្ត វិត្តនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ៥ ឃ្លា ។

គេបានបញ្ចុះវិត្តនេះ ក្រោយពីពេលដែលគេបានបញ្ចុះវិត្ត الكافرون ឈ្មោះ الفيل មានន័យថា ដំរី ។

គេយកមកធ្វើជាពាក្យសំដី الفيل ដែលមាននៅក្នុងឃ្លាទីមួយបង្អស់ នៃវិត្តនេះ ។

ការបញ្ជាក់ វិត្តនេះបានបើកឆាក ការនិទានដោយពិស្តារអំពី កងទ័ព ដំរី មកពីប្រទេសយេម៉ែន ដែលមានមេបញ្ជាការឈ្មោះ អ៊ីប្រហ៊ាំ ដោយមានគោលបំណងចង់មកវាយ កាក់ហ្ពាស់ នៅម៉ិកកាស់ ។

ព្រឹត្តិហេតុកើតឡើងនេះ នៅក្នុងឆ្នាំកំណើតរបស់ ណាពី (ណាពី) មូហាំម៉ាត់ ស៊ូលឡលឡហ៊ូ អាឡៃហ៊ីវ៉ាសាល់ឡាំ នេះឯង ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វិត្ត

ការនិទាន អំពីកងទ័ព ដំរី ដែល អល់ឡោះ បានបញ្ចុះ ទារុណកម្ម យ៉ាងធ្ងន់ធ្ងរ ។

ដោយទ្រង់បានបញ្ជា ហ្វូងកងទ័ពសត្វស្លាប ពាំគ្រាប់ក្រួសដែលធ្វើពីឋាននរក យកមកទម្លាក់ប្រហារ និងកងទ័ពអ្នកនោះ ក្រោយមកកងទ័ពវិនាស អន្តរាយ ហើយដូចជា ស្លឹកឈើដែល និង្គរ ក ស៊ី អស់ហើយដែរ ។

الْفِيلْ
ដំរី

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា សប្បុរស ទ្រង់មហា មេត្តាប្រណី ។　　بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

أَلَمْ تَرَ كَيْفَ فَعَلَ رَبُّكَ بِأَصْحَابِ الْفِيلِ

១. តើអ្នកពុំបានឃើញពីរបៀប ហើយតើអ្នកយល់ទេ ?
របៀបដែលព្រះជាម្ចាស់ ម្ចាស់អ្នក ដែលបានធ្វើ
ទៅលើពួកនោះ ជិះដំរី នោះ ។

أَلَمْ يَجْعَلْ كَيْدَهُمْ فِي تَضْلِيلٍ ١

២ តើគ្មានទេឬ ? ម្ចាស់បានធ្វើ ឲ្យឧបាយកល
ល្បិចរបស់ពួកគេ ក្លាយជាការបោកប្រាស់
និងត្រឡប់បរាជ័យ ។

وَأَرْسَلَ عَلَيْهِمْ طَيْرًا أَبَابِيلَ ٢

៣ ហើយ ម្ចាស់ បានបញ្ជូនសត្វចាប ជាហ្វូង
ដ៏ច្រើនដ៏ស្រួច ទៅវាយប្រហារពួកគេ ។

تَرْمِيهِمْ بِحِجَارَةٍ مِنْ سِجِّيلٍ ٤

៤ ដែលវាបានទម្លាក់ទៅ លើពួកនោះ នូវ
ថ្ម (ក្រួសដី) មកពីដីឥដ្ឋដុត ដែលមក
ពីនរកភ្លើង

فَجَعَلَهُمْ كَعَصْفٍ مَأْكُولٍ ٥

៥ ដូច្នេះទ្រង់បានធ្វើឲ្យពួកគេ ម្ចាស់បានធ្វើ
ឲ្យពួកគេ ដូចស្លឹកឈើ ដែលសត្វល្អិតស៊ី
ស្លឹកនោះអស់ ។

ចំណាំ ៖ ព្រះ الفيل បានបញ្ជាក់ពីការបរាជ័យ ពាក្យនៃ របស់ ១.
ពួកទ័ព និង ដំរីរបស់ស្តេច ឈ្មោះ អាប្រាហាម ។
ដោយសារ ពួកគេ ចង់ វាយកំទេច (កាបះ) ពោះលើ ឬកណ្តាល ២.
ជាម្ចាស់របស់ព្រះអល់ឡោះ ។

អ្នកនិយាយដើមគេ الهمزة

ការបំភ្លឺវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៩ ឃ្លា ។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបញ្ចុះវគ្គ القيامة ឈ្មោះ الهمزة មានន័យថា អ្នកនិយាយដើមគេ ។

គេយកមកកំណត់ពាក្យសំដីថា الهمزة ដែលមាននៅក្នុងឃ្លាដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អុលឡោះ បានគំរាមកំហែង ទៅដល់ អ្នកចូលចិត្តប្រមាថ មើលងាយគេ និងអ្នកដែលនិយាយដើមគេ ហើយមានចិត្តលោភលន់ ប្រមែប្រមូល ទ្រព្យសម្បត្តិ ក៏ប៉ុន្តែ មិនព្រមចូលចិត្តបរិច្ចាគទាន សំរាប់ នៅក្នុងផ្លូវ របស់ អុលឡោះ ជាម្ចាស់ ។

الهمزة
អ្នកនិយាយដើមគេ

ដោយព្រះនាម អុលឡោះ ម្ចាស់ដ៏មហា ករុណាទៀតដ៏មហាមេត្តាប្រណី ។ — بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. គ្រោះកម្មដ៏ធ្ងន់ធ្ងរ សំរាប់ រាល់ៗអ្នក ដែល បន្តុះបង្អាប់គេ និងអ្នកដែលនិយាយ ដើមគេ ។ — وَيْلٌ لِّكُلِّ هُمَزَةٍ لُّمَزَةٍ ١

២. អ្នកដែលប្រមែប្រមូលទ្រព្យសម្បត្តិ ហើយ — ٱلَّذِى جَمَعَ مَالًا وَعَدَّدَهُۥ ٢

រវល់តែ និងរាប់ទ្រព្យសម្បត្តិរបស់វា ។

៣. វាសង្ឃឹមតែថា ពិតប្រាកដ ទ្រព្យសម្បត្តិ
របស់វានេះ នាំអោយវាបានគង់វង់ជាប់ជានិច្ច — يَحْسَبُ أَنَّ مَالَهُۥٓ أَخْلَدَهُۥ ٣

៤ កុំស្មានដូចនោះអី ពិតប្រាកដ គេនឹងបោះ
បញ្ចូលទៅក្នុង ហ៊ូតម៉ាស់(الحطمة) — كَلَّا لَيُنۢبَذَنَّ فِى ٱلْحُطَمَةِ ٤

៥ តើអ្នកដឹងថាបានដឹងដែរឬទេ? ថាតើ
ហ៊ូតម៉ាស់នោះ ។ — وَمَآ أَدْرَىٰكَ مَا ٱلْحُطَمَةُ ٥

៦ នោះគឺ ភ្លើងរបស់ អល់ឡោះ ដែលគេបាន
បញ្ឆេះឡើងគ្រលោម ។ — نَارُ ٱللَّهِ ٱلْمُوقَدَةُ ٦

៧. ភ្លើងដែលកំដៅនោះ គាបឡើងដល់បេះដូង
ក្ដៅ ទៅដល់ក្នុងចិត្ត ។ — ٱلَّتِى تَطَّلِعُ عَلَى ٱلْأَفْـِٔدَةِ ٧

៨. ពិតប្រាកដ ភ្លើងនោះហើយ ដែលគេបាន
គ្របដណ្ដប់ ទៅលើអ្នកទាំងអស់នោះ ។ — إِنَّهَا عَلَيْهِم مُّؤْصَدَةٌ ٨

៩ ក្នុងពេលនោះ គេបាន ចងភ្ជាប់ អ្នក
ទាំងនោះ ទៅនឹងសសរដ៏វែង ។ — فِى عَمَدٍ مُّمَدَّدَةٍۭ ٩

ឯក ការជាវិត្ត វាត្រូវបានបញ្ជាក់ ពាំនាំបណ្ដាអ្នកដែលចូលចិត្ត
ប្រមាថ មើលងាយគេ និងចូលចិត្តនិយាយដើមគេ ហើយ
លៀនមានចិត្ត លោភលន់ប្រមូល ប្រមូលទ្រព្យសម្បត្តិ ដោយមិនសល់ខា

ក្រឡាសម្បុត្រនោះឯងហើយ ដែលនាំមកឲ្យនូវ បានចិត្តដល់ពេល-
កាល ។ ក្រោយមកទៀតនេះ បានដាក់ក្នុងក្រុម ធ្វើការតាមការតាមស្ថិតរបស់
ក្រុមគ្រួសារទៀត ។ ដែលនេះហើយ ក្រុមជាជាតិតាម ម្ចាស់ ...
និងបានសម្បុត្រ ក្រោមការ ដែលមានក្បួនច្បាប់ មិនបានទៀត ។

ពេលវេលា العصر

កថាវិគ្គ វិគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣ ឃ្លា ។
គេបានបញ្ចុះវិគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវិគ្គ
الم نشرح

ឈ្មោះ: العصر មានន័យថា ពេលវេលា

គេបានយកពាក្យសំដីថា العصر ដែលមាននៅក្នុងឃ្លាទីមួយធ្វើ
ឈ្មោះនៃវិគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វិគ្គ

បណ្ដាមនុស្សដែលរស់នៅក្នុងលោកនេះ ស្ថិតនៅក្នុងការខាតបង់នៃផលប្រយោជន៍ រឿយៗ គឺនៅពេលណាអ្នកទាំងនោះ គ្មានបានបំពេញទេ ពេលវេលា និងប្រព្រឹត្តការល្អសុចរិត ។

العصر

ពេលវេលា

ដោយព្រះនាម អុលឡោះ ម្ចាស់ដ៏មហា ករុណាទៀតដ៏មហា មេត្តាប្រណី ។ بِسْمِ اللّٰهِ الرَّحْمَنِ الرَّحِيمِ

១ អុលឡោះដ៏បានស្បថ នឹងពេលវេលា ។ وَالْعَصْرِ ١

២ ពិតប្រាកដ មនុស្សលោក ទាំងអស់គង់តែ إِنَّ الْإِنسَانَ لَفِي خُسْرٍ ٢
ស្ថិតនៅក្នុងការ ខាតបង់ជានិច្ច ។

៣ វៀរលែងតែបណ្ដាអ្នកទាំងនោះណាមាន
សេចក្ដីជឿជាក់ ហើយបានប្រព្រឹត្តការ
ដ៏ល្អប្រពៃ ទៀតសោតទាំងនោះផងហើយ
បានដាស់តឿនគ្នា ទូន្មានការពិតប្រាកដ ហើយទៀត
បានដាស់តឿនគ្នា ទូន្មានការអត់ធ្មត់ ។

إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ وَتَوَاصَوْا بِالْحَقِّ وَتَوَاصَوْا بِالصَّبْرِ ٣

បើតាមខគម្ពីរ វគ្គនេះបានបញ្ជាក់ថា មនុស្សណាៗក៏ដោយដែល
មិនបានប្រើពេល ដោយអ្នកនោះមិនបានបំពេញករណីយកិច្ច
ល្អៗនោះ គេចាត់ទុកថា អ្នកនោះខាតហើយ គឺអ្នកដែលខាតបង់
ពេលប្រយោជន៍ធំក្រៃលែងឡើយ ។

ការលើកដំកើងខ្លួន   التكاثر

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅ មក្កាស់ ដែលមាន ៨ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الكوثر ។

ឈ្មោះ تكاثر ប្រែមកខ្មែរថា ការលើកដំកើងខ្លួន ។

គេយកមកតាំងពីពាក្យសំដី التكاثر ដែលមាននៅក្នុងឃ្លាទីមួយបង្អស់នៃ វគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

មនុស្សលោកដែលរស់នៅ ស្លុងក្នុងការលើកដំកើងខ្លួន ដោយខ្លួនឯង និងគេឯង នៅក្នុងសង្គមមនុស្សក្នុងលោកនេះ រហូតភ្លេចខ្លួនដែលនៅ- ដោយ អ្នកនោះឯងវង្វេងខ្លួន រហូតនៅពេលដែលមនុស្សគ្រប់ថ្ងៃដំណើរ ទៅ ដោយបាត់ជីវិតរបស់មនុស្សលោក គង់ចាកចិញ្ចឹមខ្លួននេះ គឺនៅ ពេលណាដែល មច្ចុរាជ(ملك عزرائيل) មកដកយកវិញ្ញាណខ្លួននោះ បានមកទល់ ។

គេចង់និងគាប នៅថ្ងៃបរលោក(الآخرة) នោះ គេនឹងសួរនៅរឿង នោះឯង ទំពី ក្តី សុខនីមួយៗ(نعيم) ដែលម្ចាស់ទ្រង់បានប្រទានដោយទាត រួចហើយក្នុងលោកិយ(الدنيا) នេះ ។ ដែលនៅមកយកការប្រទាន ក្តី សុខនីមួយៗនោះ ទៅប្រើក្នុងការលើកដំកើងខ្លួន ដែលនាំដោយរវល់វង្វេង ភ្លេចខ្លួន ពីព្រះជីវិត របស់អល់ឡោះ ។

التكاثر

ការលើកដំកើងខ្លួន

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា   بسم الله الرحمن الرحيم

សាតាវាត់ទៀតសូរ៉ះមួយបាកមេឌាក្របញ្ចៅ ។

១. ការលើកដំកើងខ្លួនគេ៖ នាំអោយបណ្ដា អ្នកឯងភ្លេចប្រហែស (ក្នុងការគោរពអុលឡោះ)	١ أَلْهَاكُمُ التَّكَاثُرُ
២. រហូតដល់តែបណ្ដាអ្នកឯង ចូលទៅក្នុង រណ្ដៅផ្នូរ ។	٢ حَتَّى زُرْتُمُ الْمَقَابِرَ
៣ ចូរកុំប្រព្រឹត្តដូចនោះអី បណ្ដាអ្នកឯងគង់តែ- នឹងបានដឹងទេ ។	٣ كَلَّا سَوْفَ تَعْلَمُونَ
៤ បន្ទាប់មក ចូរបណ្ដាអ្នកឯងកុំប្រព្រឹត្តដូចនោះ ទៀតអី អ្នកឯងគង់តែនឹងបានដឹងទេ ។	٤ ثُمَّ كَلَّا سَوْفَ تَعْلَمُونَ
៥ ចូរកុំប្រព្រឹត្តដូចនោះអី បើប្រសិនណា បណ្ដា អ្នកឯងបានដឹង ដោយវិជ្ជាយ៉ាងច្បាស់លាស់ ។	٥ كَلَّا لَوْ تَعْلَمُونَ عِلْمَ الْيَقِينِ
៦. ពិតប្រាកដណាស់ បណ្ដាអ្នកឯងនឹងបានឃើញ ឋាននរក ជាមិនខានឡើយ ។	٦ لَتَرَوُنَّ الْجَحِيمَ
៧. បន្ទាប់មក ពិតប្រាកដ បណ្ដាអ្នកឯងនឹងបាន ឃើញវា ដោយច្បាស់លាស់ និងជាក់ច្បាស់	٧ ثُمَّ لَتَرَوُنَّهَا عَيْنَ الْيَقِينِ
៨. បន្ទាប់មក ពិតប្រាកដដែល បណ្ដាអ្នកឯងនេះ គេនឹងសួរ នៅថ្ងៃនោះ អំពីការពេញចិត្តដែល ពីអុលឡោះ ទ្រង់បានប្រទានអោយមក ហើយនោះ ។	٨ ثُمَّ لَتُسْأَلُنَّ يَوْمَئِذٍ عَنِ النَّعِيمِ

បិត តំបរិវត្ត វគ្គនេះ បានតាំងមក បញ្ជាក់នូវការ បន្ទុះ បង្អាប់ និងការ
គ្រោះ គិតសង្ស័យ ទៅចំពោះអ្នកដែលលើកដំកើងខ្លួន ហើយ
និង ក្តីសុខទុក្ខរបស់គេ ដែលគ្រប់គ្រងប្រមាថមើលងាយគេ ហើយរក
ក្រាងរាយរាប់រៀបរាប់សម្បត្តិនោះ ទៅ ទីពោះផ្លូវ របស់អ្នកលោភៈ ។
ហេតុដូចនេះ អ្នកទាំងអស់នោះ ថ្កោងដីហាគេជឿតាមពាក្យ ហើយ
ធៀតក្រោកឈរហាក់កេនិងស្លូវ មិនមានធៀរ សំដីការលើកដំកើងខ្លួនរបស់ពួកនោះ ។

ថ្ងៃគោះកាល الْقَارِعَةُ

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅ ម៉ាក្កាស់ ដែលមាន ១១ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ قريش ។ ឈ្មោះ ស៊ូរ៉ោះនេះមានន័យថា ថ្ងៃគោះកាល ។

គេយកមកដាក់ពីពាក្យសំដី ស៊ូរ៉ោះ ដែលនៅក្នុងឃ្លាដំបូងបង្អស់ នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

វគ្គនេះ គេបានបញ្ជាក់ អំពីព្រឹត្តិការណ៍ នៅនាថ្ងៃគោះកាល ។

ថ្ងៃនោះហើយ បណ្ដាមនុស្សលោក ដែលនឹងកញ្ជ្រោលព្រោងព្រាត ហើយបណ្ដា ភ្នំ (ជុំ) នឹងរសាត់ អណ្ដែតព្រោងព្រាត តាមសាកសពរបាត់ ពេលនោះ ហើយ ដែលថាថ្ងៃ ដែលគេថ្លឹងទម្ងន់នូវអំពើប្រព្រឹត្ត របស់មនុស្សលោកហើយ ដែលបាន អនុវត្តរួចមកហើយ គឺថារយៈពេលនោះដែរ គេក៏បានកត់សំគាល់ ឃើញសមហេតុសមផល អំពី អំពើដែល មនុស្សលោកបានប្រព្រឹត្តរួចពី ជានលោកិយ រួចមកហើយនោះ ។

الْقَارِعَةُ

ថ្ងៃគោះកាល

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា សប្បុរសទ្រង់មហា មេត្តាបំផុត ។

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១. ថ្ងៃគោះកាល ។ ١ الْقَارِعَةُ

٢ مَا الْقَارِعَةُ

២ អ្វីទៅ ថ្ងៃគោះកាលនោះ ?

٣ وَمَا أَدْرَاكَ مَا الْقَارِعَةُ

៣. តើអ្នកឯង ដឹងដែរឬទេ. អ្វីទៅថ្ងៃគោះ
កាលនោះ ?

٤ يَوْمَ يَكُونُ النَّاسُ كَالْفَرَاشِ الْمَبْثُوثِ

៤. គឺថ្ងៃនោះឯង មនុស្សលោក ហាក់បីដូចជា
មេអំបៅដែលសណ្តាត់ខ្ចាត់ខ្ចាយ ហើយ ។

٥ وَتَكُونُ الْجِبَالُ كَالْعِهْنِ الْمَنْفُوشِ

៥ ហើយភ្នំនឹងត្រូវ ប្រៀបដូចជារោម
ដែលគេត្បិចបែក រសាត់តាមខ្យល់ ។

٦ فَأَمَّا مَنْ ثَقُلَتْ مَوَازِينُهُ

៦. ដើម្បីនោះ អ៊ីណែកតនណា មានទម្ងន់ធ្ងន់
នាថ្លឹងរបស់អ្នកនោះ (អំពើសុចរិត)

٧ فَهُوَ فِي عِيشَةٍ رَاضِيَةٍ

៧. ទើបបានជីវិតនោះ អ្នកនោះឯង នឹងបានរស់
នៅក្នុងភាពពេញចិត្ត ។

٨ وَأَمَّا مَنْ خَفَّتْ مَوَازِينُهُ

៨. ហើយរីឯចំណែកឯណា មានទម្ងន់ស្រាលក្នុង
ការថ្លឹងរបស់អ្នកនោះ (អំពើទុច្ចរិត)

٩ فَأُمُّهُ هَاوِيَةٌ

៩. ទីលំនៅ អ្នកនោះ គឺក្នុងរណ្តៅនោះឯងគឺ
ឋាននរក ហៅថាហាវីយ៉ាស់ (هاوية) ។

١٠ وَمَا أَدْرَاكَ مَا هِيَهْ

១០ តើអ្នកឯង បានដឹងដែរឬទេ អ្វីទៅឋាននរក
ហៅហាវីយ៉ាស់ (ماهية) នោះ ?

១១. នោះគឺកន្លែងភ្លើង ដែលសម្បូរនៃកំដៅ។ نَارٌ حَامِيَةٌ ١١

ចប់ ការិអាវគ្គ វគ្គនេះបានបញ្ចប់អំពីហេតុការណ៍ដែលនឹងកើតមានឡើងនៅថ្ងៃនោះ ។

ហ្វូងសត្វសេះដែលមានល្បឿនក្នុងសង្គ្រាម العاديات

គម្ពីរទី ១០០ វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កះ ដែលមាន ១១ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ العصر ។

ឈ្មោះ العاديات មានន័យថា : ហ្វូងសេះដែលមានល្បឿនលឿនក្នុងសង្គ្រាម ។

គេយកមកដាក់ពីពាក្យដំបូង العاديات ដែលមាននៅក្នុងឃ្លាទីមួយនៃ វគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

បញ្ជាក់អំពីការគ្រោះថ្នាក់ និងការគម្រាមកំហែងរបស់អល់ឡោះជាម្ចាស់ ទៅដល់ពួកបណ្ដាមនុស្សលោក ដែលជាអ្នកប្រឆាំង និងមិនព្រមអនុវត្តតាម ក្បួនច្បាប់ ពួកអ្នកទាំងនោះ មានចិត្តលោភលន់ ស្រឡាញ់ទ្រព្យសម្បត្តិ ហួសហេតុ ។ ពិតប្រាកដណាស់ អ្នកទាំងនោះឯង នឹងត្រូវតែបានទទួលលទ្ធផល យ៉ាងសមហេតុសមផល នៅពេលណាគេបានបញ្ចេញ អ្នកទាំងអស់នោះ អំពីផ្នូររបស់គេ ហើយពេលនោះទៀត អ្វីៗដែលនៅក្នុងទ្រូងរបស់អ្នកទាំងនោះ គេនឹងបញ្ចេញ ដោយអ្នកនោះឯង ឃើញមិនខានឡើយ ។

العاديات

ហ្វូងសត្វសេះដែលមានល្បឿនលឿនក្នុងសង្គ្រាម

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា សាការុណ្យ ទៀតដ៏មហា មេត្តាប្រណី ។

وَالْعٰدِيٰتِ ضَبْحًا ١

១ បានស្បថហើយ (អល់ឡោះ) ទៅនឹងពពួក សត្វសេះចម្បាំងដែលបញ្ចេញសម្លេង

ដកដង្ហើមលឿន ។

២ ជាពេលនោះ បានចេញហើយ ផ្កាភ្លើង
(សំពៀកជើងរបស់វា)

۲ فَالْمُورِيَاتِ قَدْحًا

៣ សេះទាំងនោះ វាបានបោល សំរុក ដោយស្ទាក់
ទាំងយកពេញទំហឹង ជាពេលទៀបភ្លឺ ។

۳ فَالْمُغِيرَاتِ صُبْحًا

៤ ទន្ទឹមនឹងនោះទៀតផង វាបានបញ្ចេញធូលា
ធ្វើអោយដី ហុយឡើងពេញ ។

٤ فَأَثَرْنَ بِهِ نَقْعًا

៥. ទើបជាពេលនោះនឹង វាបានសំរុកចូល
ទៅដល់ កណ្ដាលទីលានប្រយុទ្ធ របស់ពួកវា ។

٥ فَوَسَطْنَ بِهِ جَمْعًا

៦. ពិតប្រាកដ មនុស្សលោកនោះឯង បានប្រ
ព្រឹត្ត អំពើទុច្ចរិត ចំពោះម្ចាស់ ។

٦ إِنَّ الْإِنْسَانَ لِرَبِّهِ لَكَنُودٌ

៧. ហើយពិតប្រាកដណាស់ លើអំពើប្រព្រឹត្តដូច
នោះឯងប្រាកដជា មុខងារវានឹងបានឃើញជា
មិនខានឡើយ ។

٧ وَإِنَّهُ عَلَى ذَٰلِكَ لَشَهِيدٌ

៨ ហើយទៀត ពិតប្រាកដ មនុស្សលោកនោះ
ឯង ជាអ្នកមហាកំណាញ់ ដោយ
ហេតុតែមាំអំពើស្រលាញ់ទ្រព្យសម្បត្តិ
ហួសហេតុពេក ។

٨ وَإِنَّهُ لِحُبِّ الْخَيْرِ لَشَدِيدٌ

៩. តើវាពុំដឹងទេឬ? ពេលណាគេបាន បញ្ចេញចេញ របស់ដែលនៅក្នុងផ្នូរ ។ — أَفَلَا يَعْلَمُ إِذَا بُعْثِرَ مَا فِي الْقُبُورِ

១០ ហើយគេបានលាតត្រដាង របស់ដែលលាក់ជាប់ នៅក្នុងទ្រូង ។ — وَحُصِّلَ مَا فِي الصُّدُورِ

១១ ពិតប្រាកដ ម្ចាស់អ្នកទាំងអស់នោះ នៅក្នុង
ថ្ងៃនោះហើយ ទ្រង់ដែលដឹងច្បាស់បំផុត
រឿងដែលអ្នកទាំងនោះ បានប្រព្រឹត្ត — إِنَّ رَبَّهُم بِهِمْ يَوْمَئِذٍ لَّخَبِيرٌ

បំភ្លឺ ករណីវគ្គ វគ្គនេះបានបញ្ជាក់ អំពី លក្ខណៈ ទឹកចិត្ត របស់ មនុស្សលោក និងការបញ្ចេញ អំពើ ព្រមទាំងនិង ការតបស្នង នូវលទ្ធផល នៅថ្ងៃនោះ មនុស្សលោក នាពេលថ្ងៃនេះ ការ-នេះ ផង ។

ការរំជួយ الزَّلْزَلَة

កំណើតវគ្គ វគ្គនេះពោលបញ្ចុះនៅម៉ាឌីណាស់ ដែលមាន ៨ ឃ្លា។ ពោលបញ្ចុះវគ្គនេះ ក្រោយពីពេលដែលពោលបញ្ចុះវគ្គ النساء
ឈ្មោះ៖ ង الزلزال មានន័យថា ការរំជួយ
ដោយយកមកសំដៅពាក្យសំដី زلزل ដែលនៅក្នុងឃ្លាដំបូងបង្អស់ នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

បញ្ជាក់ពីការកក្រើករំជួយផែនដី នៅថ្ងៃនេះកាល (ថ្ងៃ القيامة) នោះ ខ្លាំង មហាកក្រើករំជួយខ្លាំងបំផុត ។ នៅថ្ងៃនោះឯង បណ្ដាមនុស្សលោកទាំងអស់គ្នា មានសភាពស្ញើស្ញើ គិតនឹងឆ្ងល់ចំពោះអ្វីៗ ដោយសារតែមកពីមានការភិតភ័យ តក់ស្លុត សំពីសភាពការណ៍ថ្ងៃនេះកាលនោះឯង ។ ថ្ងៃនោះហើយពោលប្រមូលផ្តុំ ទាំងអស់ពីបណ្ដាមនុស្សទាំងពីរប្រភេទ ដើម្បីនឹងវិនិច្ឆ័យ កាត់សេចក្ដី ទៅតាមកិច្ចប្រតិបត្តិ របស់ពួកគេទាំងអស់នោះ ។

الزَّلْزَلَة

ការរំជួយ

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា
ករុណាក្រៃលែង ដ៏មហាមេត្តាប្រណី ។

١ إِذَا زُلْزِلَتِ الْأَرْضُ زِلْزَالَهَا

១ ពេលណាគេបានរំជួយ ហើយផែនដី
ទៅបរំជួយញ័រៗ (ផែនដី) ។

២. ហើយផែនដី បានបញ្ចេញហើយ អ្វីៗ
ដែលនៅក្នុងវានោះ ។

وَأَخْرَجَتِ الْأَرْضُ أَثْقَالَهَا ٢

៣ បានពោលថា ហើយមនុស្សលោក
ហេតុដូចម្តេច បានជាផែនដី កើតមាន
រឿងដូច្នេះ? ។

وَقَالَ الْإِنسَانُ مَا لَهَا ٣

៤. នាថ្ងៃនោះ ផែនដីនឹងនិទានរឿងរ៉ាវៗដែល
កកើតមានរឿងនៅលើវានោះ ។

يَوْمَئِذٍ تُحَدِّثُ أَخْبَارَهَا ٤

៥. ដោយហេតុថាព្រះអង្គ ម្ចាស់អ្នកបាន
បញ្ជាទៅលើវា ។

بِأَنَّ رَبَّكَ أَوْحَىٰ لَهَا ٥

៦. នាថ្ងៃនោះ មនុស្សលោកនឹងបានចេញ
(ពីផ្នូររបស់គេ) ជាពួកជាក្រុម ក្នុង
លក្ខណៈគ្រប់បែបគ្រប់យ៉ាង ដើម្បីគេ
នឹងបង្ហាញអ្នកទាំងអស់នោះ អំពើខ្លួន
ដែលអ្នកទាំងនោះ បានប្រព្រឹត្តរួចមក ។

يَوْمَئِذٍ يَصْدُرُ النَّاسُ أَشْتَاتًا لِّيُرَوْا
أَعْمَالَهُمْ ٦

៧. ទើបដូចនោះ អ្នកណាៗ ហើយដែលបាន
ប្រព្រឹត្ត ការល្អ ទោះបីស្មើនឹងទម្ងន់
ញ៉ូក្លែស (ធូះ , ធូលីដ៏ល្អិត) ក៏នឹងបាន
ឃើញហើយ ការល្អរបស់គេ ។

فَمَن يَعْمَلْ مِثْقَالَ ذَرَّةٍ خَيْرًا يَرَهُ ٧

៨. ហើយអ្នកណាៗហើយ ដែលបានប្រព្រឹត្ត
ការអាក្រក់ ទោះបីស្មើនឹងទម្ងន់ ញ៉ូក្លែស(ធូះ)

وَمَن يَعْمَلْ مِثْقَالَ ذَرَّةٍ
شَرًّا يَرَهُ ٨

ទូលីនីស្លូតតានិងបានឃើញការ អាក្រក់របស់
អ៊ំនោះ ។

បឋមកប៉ាវិគ្គ វិគ្គនេះបានបញ្ជាក់សំដៅ ប៉ុន្មានៗ អន្តរាយ ស្រុក
និព្វានបង្អស់ នៅក្នុង លោកកាលនោះ ។
នៅក្នុងនោះហើយ មនុស្សលោកទាំងអស់បាន ឃើញដោយផ្ទាល់
នូវសង្វ សំដៅលើដែលស្លាក់ទាំងអស់នោះ បានប្រព្រឹត្តឡើងរួចមកហើយ
នោះ ល្អ ឬ អាក្រក់ ខ្លួននៅនឹងគ្រប់សំអស់ខ្លួលីនោះក៏ដោយ ។

ភស្តុតាងដ៏ច្បាស់លាស់ البينة

កប្រវត្តិ វគ្គនេះគេបានបញ្ចុះនៅមិកកាស់ ដែលមាន ៨ បន្ទាត់ ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបញ្ចុះវគ្គ الطلاق ។
ឈ្មោះ البينة មានន័យថា ភស្តុតាងដ៏ច្បាស់លាស់
គេយកមកសំដៅពាក្យសំដី البينة ដែលនៅក្នុងបន្ទាត់ទីមួយបង្អស់ នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

គេបញ្ជាក់ សំដីការអាក់ខ្ពង់នៃសាសនាស្ត្រាបណ្ឌិតគម្ពីរ ហើយនិងបណ្ដា អ្នកដែលវង្វេង (មូសរិគីន) ។ ដោយហេតុថាអ្នកទាំងនោះ ពុំព្រមលះបង់ចាកចេញសំពីសាសនារបស់គេ ទៀងៗខ្លួនឡើយ ។ រហូតទាល់តែ សារ:(ណាប្ពី) បានមកដល់អ្នកទាំងនោះ ដែលអូលគេឈ្មោះ បានលម្អៀង រួចមកហើយ ។ រួចពីពេល សារ:(ណាប្ពី) បានដល់មក អ្នកទាំងអស់នោះ ក៏បែកបាក់ជាច់ជំលោះចេញពីគ្នា ។ មានពួកខ្លះក៏មានជំនឿជឿតាម សារ:(ណាប្ពី) ពួកខ្លះទៀតក៏បែរចេញគ្មានជំនឿនឹងសារ:(ណាប្ពី) នេះ ។

នឹកលើកការណ៍នៃលក្ខណៈ របស់សារ:(ណាប្ពី) ដែលបានដល់មកនោះ ដោយសមហេតុសមផល តៅតាមលក្ខណៈអ្នកទាំងអស់នោះ បានដឹងស្គាល់ តាមគម្ពីររបស់គេរួចស្រេចមកហើយ ។ ហើយទៀតសារ:(ណាប្ពី) បាននាំមក នូវការខ្នាត ដ៏ពិសុទ្ធកត់ ការខ្នាតនោះឯង គឺគឺលោះសរសេង ការគោរពប្រណិប័តន៍ និងបញ្ចេញការគោរពសំពះថ្វាយបង្គំ(الصلاة) ហើយនិងការបរិច្ចាគទាន

البينة

ភស្តុតាងដ៏ច្បាស់លាស់

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហា
សាការុណ ទៀតទ្រង់មហាមេត្តាប្រណី ។

١ لَمْ يَكُنِ الَّذِينَ كَفَرُوا مِنْ أَهْلِ الْكِتَابِ
وَالْمُشْرِكِينَ مُنفَكِّينَ حَتَّىٰ تَأْتِيَهُمُ الْبَيِّنَةُ

១ បណ្ដាអ្នកគ្មានជំនឿ ពីអ្នកសាស្ត្រាបណ្ឌិត
គម្ពីរ (ដែលគេក្រើស្តសាសនា និងយ៉ាហ៊ូទី និងពួកស-
នីវ៍) ហើយនិងអ្នកដែលរាប់ស្ទើ/មុសរីគីន)
អ្នកទាំងនោះ ហើយ ដែលមិនព្រមបោះបង់
ចោលសាសនារបស់គេឡើយ លុះត្រាតែ
បានដល់មក អ្នកទាំងនោះនូវភស្តុតាងដ៏ជាក់
ស្តែង ។

٢ رَسُولٌ مِّنَ اللَّهِ يَتْلُو صُحُفًا مُّطَهَّرَةً

២ នោះគឺ (មូហាំម៉ាត់) ជាអ្នកនាំសារ របស់
អល់ឡោះ ដែលបានសូត្រ មហាគម្ពីរ ដ៏មហា
ប្រិះស្អាត (អំពីការទៀងផ្ដាត់, ការបោះបង់ ហើយ
និងការក្រោកបញ្ចោត) ។

٣ فِيهَا كُتُبٌ قَيِّمَةٌ

៣. នៅក្នុងវានោះ មានក្រឹត្យសិក្ខាបទនៃច្បាប់
ដ៏មហាបរិសុទ្ធ (គីតាប) ។

٤ وَمَا تَفَرَّقَ الَّذِينَ أُوتُوا الْكِتَابَ إِلَّا
مِن بَعْدِ مَا جَاءَتْهُمُ الْبَيِّنَةُ

៤ ហើយគ្មានបែកញែកសាមគ្គីគ្នាទេ បណ្ដាអ្នក
ដែលគេ (អល់ឡោះ) បានឲ្យគីតាបទៅលើ
អ្នកទាំងនោះ លើកលែងតែក្រោយពីបាន
ដល់មក នូវភស្តុតាងដ៏មហាជាក់ស្តែង ។

٥ وَمَا أُمِرُوا إِلَّا لِيَعْبُدُوا اللَّهَ مُخْلِصِينَ
لَهُ الدِّينَ

៥ ហើយគេបានប្រើអ្នកទាំងអស់នោះទេ
ក្រៅពីលែងតែដើម្បីគោរពអ្នកទាំងអស់នោះ ធ្វើ

ការគោរពសំពះទៅចំពោះអុលឡោះ
ដោយស្មោះត្រង់ ហើយតែងតែការរក្សាមាន
សាឡាត និងបង់ហ្សាកាត់ និងជឿអ្នកទាំង
របស់គេ៖ បញ្ញើការគោរពសំពះដោយ
បរិសុទ្ធ ទៀតនិងជឿអ្នកទាំងរបស់គេ៖ ជឿ
វិភាគទាន(الزكوة)ដល់គេ៖ ហើយ ធ្វើសាឡាត
និងបង់ហ្សាកាត់ ។

حنفاء ويقيموا الصلوة ويؤتوا الزكوة وذلك
دين القيمة

៦ ពិតប្រាកដ បណ្ដាអ្នកដែលមិនជឿ ពី
សាសនាបណ្ឌិតគម្ពីរ ហើយនិងបណ្ដាអ្នក
ដែលមានជំនឿជឿថា មានមហាទ្រឹស្ដីច្រើន
ទៀត មកក្រៅពីអុលឡោះ និងមហាទ្រឹស្ដីរបស់
អុលឡោះ ទៀតគេ គង់តែនឹងចូលទៅ
ក្នុងភ្លើង នរកអវិជ្ជា យ៉ាងហិនហោច ជាប់
ជានិច្ច នៅក្នុងនោះ អ្នកទាំងនោះ
ជាពពួក ដែលសែនអាក្រក់ អាក្រក់ជាទីបំផុត
ក្នុងលោកិយ ។

إن الذين كفروا من أهل الكتب ٦
والمشركين في نار جهنم خلدين
فيها أولئك هم شر البرية

៧. ពិតប្រាកដ បណ្ដាអ្នកមានជំនឿ ហើយ
ប្រព្រឹត្តអំពើល្អ អ្នកទាំង
នោះ ហើយ ជាពពួក មនុស្សដែលសែន
ល្អ ក្នុងលោកិយនេះ ។

إن الذين آمنوا وعملوا الصلحت ٧
أولئك هم خير البرية .

៨ ការតបស្នងរបស់ ចំពោះបណ្ដាអ្នកទាំង
នោះហើយ សំពីម្ចាស់របស់អ្នកទាំងនោះ
គឺ ឋានសួគ៌ អាត់និង(عدن) ដែល

جزاؤهم عند ربهم جنت عدن تجري ٨
من تحتها الأنهر خلدين فيها

أَبَدًا رَضِيَ اللَّهُ عَنْهُمْ وَرَضُوا عَنْهُ ذَٰلِكَ لِمَنْ خَشِيَ رَبَّهُ

មានហូរពីក្រោមវា ជានិរន្តរ៍
ពួកទាំងអស់នោះ ស្ថិតនៅជាប់ជានិរន្តរ៍
ដោយ អល់ឡោះ ម្ចាស់ទ្រង់បានទទួល
យល់ព្រម ចំពោះពួកទាំងអស់នោះ
(ពីព្រោះខិតខំធ្វើនូវដែលនៅក្នុងលោកីយពីមុនមក)
ហើយ ទើប ពួកទាំងអស់នោះ បានទទួល
ផលកម្មដ៏ល្អ ចំពោះទ្រង់ ដូចនោះឯង
គឺសំរាប់ពួកកោតខ្លាច ម្ចាស់របស់គេ ។

បរិគតប៉ាវិត្ត ខ្លួននេះ បានបញ្ជាក់ ចំពោះការបញ្ជារបស់ អល់ឡោះ ។

អល់ឡោះ បានបញ្ជាក់ដោយច្បាស់លាស់ពីគម្ពីរតូរ៉ាត នូវការទូន្មានរបស់ ណាពី(ណាព្វី) មូហាំម៉ាត់ នេះ គឺការទូន្មាន ដ៏ពិតប្រាកដឥតខ្ចោះឡើយ ហើយនិងសាសនា ដែល ណាពី(ណាព្វី) មូហាំម៉ាត់ បាននាំមកនោះ គឺសាសនាដ៏ត្រឹមត្រូវ ជាទីបំផុត ដែលពេញលក្ខណៈ នូវគោលការណ៍ទូន្មាន ដោយមានសញ្ញាគ្រប់នៃច្បាប់ទំលាប់ទូន្មានរបស់ ណាពី(ណាព្វី) ពីមុនៗមក ។

រាត្រីដ៏មហាថ្កុំថ្កើង القدر

កំបូវគ្គ វគ្គនេះបានបញ្ចុះនៅម៉ាក្កាស់ និងមាន ៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ عبس
ឈ្មោះ القدر មានន័យថា រាត្រីដ៏មហាថ្កុំថ្កើង
គេយកមកអំពីពាក្យសំដី القدر ដែលមាននៅក្នុងឃ្លាមា
ដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អាល់គួរអាន (القرآن) ដ៏មហាថ្កុំថ្កើងនេះ គេបានបញ្ចុះនៅពេលរាត្រីដ៏មហាថ្កុំថ្កើង ដោយមានការល្អលើសលប់ជាងរាប់ពាន់ខែទៅទៀត ។ រាត្រីនោះពពួកទេវៈ(ម៉ាឡាអ៊ីកាត់) ជាមួយនឹងទេវៈជីព្រីអិល បានចុះមកលើលោកីយនេះ ដើម្បីរៀបចំកិច្ចការនានា ។

القدر
រាត្រីដ៏មហាថ្កុំថ្កើង

ដោយព្រះនាមអុលឡោះ ម្ចាស់ទ្រង់មហាសប្បុរស សាធារណ៍ទូទៅ ទ្រង់មហាមេត្តាប្រណី ។ بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. ពិតប្រាកដណាស់យើង (អុលឡោះ) បានបញ្ចុះ ហើយវា [អាល់គួរអាន (القرآن)] នាពេលរាត្រីដ៏មហាថ្កុំថ្កើង ។ إِنَّا أَنزَلْنَاهُ فِي لَيْلَةِ الْقَدْرِ ١

២. ហើយ អ្នកឯង បានដឹងដែរ ឬទេ ថាតើ រាត្រីលីឡាតុលកទើរនោះ ? — ٢ وَمَا أَدْرَىٰكَ مَا لَيْلَةُ الْقَدْرِ

៣ រាត្រីលីឡាតុលកទើរនោះ ល្អវិសេសបំផុត លើសជាង មួយពាន់ខែ — ٣ لَيْلَةُ الْقَدْرِ خَيْرٌ مِّنْ أَلْفِ شَهْرٍ

៤ បានចុះហើយ ពពួកទេវតា [ម៉ាឡាអ៊ីកាត់ (ملائكة)] ជាមួយទេវតា បរិសុទ្ធ (ملائكة جبريل) នាពេលរាត្រីនោះ ដោយ ការយល់ស្រប អំពីម្ចាស់របស់ វា (ពពួក ម៉ាឡាអ៊ីកាត់) សំរាប់រៀបចំ កិច្ចការទាំងអស់ នោះ ។ — ٤ تَنَزَّلُ الْمَلَٰٓئِكَةُ وَالرُّوحُ فِيهَا بِإِذْنِ رَبِّهِم مِّن كُلِّ أَمْرٍ

៥. នាពេលរាត្រីនោះហើយ ពោរពេញ ទៅដោយ ប្រិយភាពសុខសាន្ត រហូតដល់ តែចេញរស្មី ហ្វាជើរ [الفجر (រស្មីព្រាង ព្រលឹមជិតភ្លឺ ។ — ٥ سَلَٰمٌ هِيَ حَتَّىٰ مَطْلَعِ الْفَجْرِ

បរិកថាវគ្គ វគ្គនេះបានបញ្ជាក់ យ៉ាងច្បាស់លាស់ អំពី និមិត្តការណ៍ ដែលគេបញ្ចុះ អាល់គួរអាន (القرآن) នៅវេលាយប់ ដែលគេហៅថាលកទើរ (ليلة القدر) ហើយគេបានបញ្ជាក់ អំពីសភាពរុងរឿង ដ៏ឧត្តុង្គឧត្តម នៃវេលារាត្រីនោះ ។

ឈ្មោះជំពូក العلق

កឋាវិត្ត វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន១៩ឃ្លា ។ ចាប់ពីឃ្លាទី១ ទៅដល់ឃ្លាទី៥ ក្នុងវគ្គនេះ គេបាន បញ្ចុះជាដំបូងបង្អស់ នៅក្នុងគម្ពីរ អាល់គួរអាន(القران) ។ គឺពេលនោះ ហើយ គឺជាពេលដែល ណាពី(ណាពី) មូហាំម៉ាត់ បានសាកខ្លួន សំណាក់ នៅភ្នំ ហ៊ីរ៉ក

ឈ្មោះ العلق មានន័យថា ឈាមមួយដុំ

គេយកមកពីពាក្យសំដី العلق ដែលមាននៅក្នុងឃ្លាទី២ នៃវគ្គនេះ ។

គេហៅឈ្មោះទៀត اقرأ ឬ القلم

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

គេបញ្ជាក់ :

- បញ្ជាអោយសូត្រ គួរអាន
- មនុស្សលោក គេបានបង្កើតមកពីឈាមមួយដុំ
- ហើយអល់ឡោះ បានបង្កើត កាល់ កន្សោម (القلم) ដើម្បីជាប៉ាកា សំរាប់សរសេរ ដើម្បីជាប្រយោជន៍ សំរាប់ ពង្រីកមនោគមន៍វិជ្ជា ដែលទៅតាមមនុស្សប្រព្រឹត្តពីលើលោក ហើយយល់ឃើញ ហេតុមក ពីហេតុផលបើទោះបីជា ខ្លួនរបស់គេនោះ មានបានសព្វគ្រប់គ្រប់គ្រាន់ក៏ ដោយ ។

អល់ឡោះ បានធ្វើនូវបុគ្គលម្នាក់ៗ ទៅនៃពោះបណ្តាស្មាក់ដែលបាន ពីពេលនោះ រហូតដល់ពេល បានប្រឆាំងតាំងពី ទៅសំបណ្តាក្រុមសុំស្លាប ដែលបានអនុវត្ត តាមប្រតិបត្តិ តាមបញ្ជារបស់អល់ឡោះជាម្ចាស់ ។

ឈាមមួយដុំ اَلْعَلَق

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហាសាណាណិតទៀតទ្រង់មហាមេត្តាបំផុត។

١ اِقْرَأْ بِاسْمِ رَبِّكَ الَّذِىْ خَلَقَ

១. ចូរសូត្រចុះ (ឱមូហាំម៉ាត់) និងព្រះនាមម្ចាស់ឯង ដែលបានបង្កើត វត្ថុនានា ក្រោយស្ញាត សព្វសារពើ ។

٢ خَلَقَ الْاِنْسَانَ مِنْ عَلَقٍ

២. ទ្រង់នោះហើយ បានបង្កើតមនុស្សលោក អំពីឈាមមួយដុំលោហិត ។

٣ اِقْرَأْ وَرَبُّكَ الْأَكْرَمُ

៣ ចូរសូត្រចុះ (ឱមូហាំម៉ាត់) និងព្រះនាមម្ចាស់ឯង ដ៏មហាឧត្តុង្គ ។

٤ اَلَّذِىْ عَلَّمَ بِالْقَلَمِ

៤ ទ្រង់នោះហើយបានបង្រៀន(សរសេរ) និងស្លាបប៉ាកា ។

٥ عَلَّمَ الْاِنْسَانَ مَالَمْ يَعْلَمْ

៥ ទ្រង់បានបង្រៀនមនុស្សលោក នូវរឿងដែលគេពុំបានដឹង ។

٦ كَلَّا اِنَّ الْاِنْسَانَ لَيَطْغٰى

៦. និងពុំ: ពិតប្រាកដ មនុស្សលោកនោះ ហើយរំលងមហាក្ដួតក ។

៧. ពីព្រោះគាត់បានឃើញខ្លួនគាត់នោះ
បរិបូណ៌គ្រប់បែបយ៉ាង ។

أَن رَّآهُ اسْتَغْنَىٰ ٧

៨ ពិតប្រាកដ ទៅកាន់ព្រះម្ចាស់របស់អ្នកនោះ
ហើយ ដែលអ្នកនឹងវិលត្រឡប់ ។

إِنَّ إِلَىٰ رَبِّكَ الرُّجْعَىٰ ٨

៩. តើអ្នកឯងបានឃើញដឹងអ្វីទេ?
អ្នកដែលហាមឃាត់ ។

أَرَأَيْتَ الَّذِي يَنْهَىٰ ٩

១០. ខ្ញុំរបស់អល់ឡោះ ពេលណាដែលគាត់
សំពះគោរពប្រតិបត្តិ (صلاة = ...)

عَبْدًا إِذَا صَلَّىٰ ١٠

១១ តើអ្នកឯងបានឃើញដូចម្តេចដែរ?
បើប្រសិនណាជា អ្នកដែលត្រូវគេហាម
ឃាត់នោះ នៅលើផ្លូវដែលត្រឹមត្រូវ?

أَرَأَيْتَ إِن كَانَ عَلَى الْهُدَىٰ ١١

១២. ឬក៏ដោយជាគាត់ បានបញ្ជាឲ្យប្រតិបត្តិ
ការណាដែលកោតខ្លាច ។

أَوْ أَمَرَ بِالتَّقْوَىٰ ١١

១៣. តើអ្នកឯងបានឃើញដូចម្តេចដែរ
បើប្រសិនណា អ្នកហាមឃាត់គេនោះ
ជាអ្នកដែលភូតភរកុហក ហើយបែរខ្នង
ទៅជាក្បត់ទេ

أَرَأَيْتَ إِن كَذَّبَ وَتَوَلَّىٰ ١٢

១៤ តើគាត់បានដឹងទេឬ? ថាពិតប្រាកដ
អល់ឡោះនោះ ហើយជាម្ចាស់ដែល
មើលឃើញ (នូវពើដែលគាត់បានប្រព្រឹត្ត)

أَلَمْ يَعْلَم بِأَنَّ اللَّهَ يَرَىٰ ١

១៥ កុំដូច្នោះ ប្រាកដណាស់ទៅហើយ
បើប្រសិនណាជាវា ពុំព្រមលះបង់លទ្ធ
នោះ ប្រាកដជាយើងនឹងទាញយក
បង្ហើយសក់ក្បាលរបស់វា ។

كَلَّا لَئِن لَّمْ يَنتَهِ لَنَسْفَعًا بِالنَّاصِيَةِ ١٥

១៦ នោះគឺ គឺបង្ហើយក្បាលអ្នកដែលភូត
ភរ កុហក ទៀតអ្នកដែលមានកំហុស ។

نَاصِيَةٍ كَاذِبَةٍ خَاطِئَةٍ ١٦

១៧ ហើយចូរ ឲ្យវាហៅគាំទ្រទៅក្រុមគណៈ
បក្សរបស់វា (សំរាប់ជួយស្រោចស្រង់វា)

فَلْيَدْعُ نَادِيَهُ ١٧

១៨ គង់តែយើងនឹងហៅ ពួកមលាអ៊ីកាត់ហ្សាបានីយ៉ះ
(ملئكة الزبانية) (ពួកឆ្មាំអ្នកដែល
យាមឋាននរក) ។

سَنَدْعُ الزَّبَانِيَةَ ١٨

១៩. ចូរអ្នកឯង (មូហាំម៉ាត់) កុំប្រណិប័តន៍
តាមវាអោយសោះ ទៀតចូរអ្នកឯង
គោរពចុះ (ចំពោះអល់ឡោះ)
ហើយ ភ្ជិតខ្លួនអ្នកឯងចុះ (ចំពោះ
អល់ឡោះ) ។

كَلَّا لَا تُطِعْهُ وَاسْجُدْ وَاقْتَرِب ١٩

បិតកាប៉ាវត្ថុ

វគ្គនេះបានបញ្ជាក់ថា:
អល់ឡោះ បានបង្កើតមនុស្សលោក ពីដុំឈាមដែល
សមរាល្យ ជុំគ្នា ។
បន្ទាប់មកគេបានលើកកំពស់ មនុស្សលោកនោះ និងបង្រៀន

ដោយដោះ ទាន , ដោះសារសោ ហើយនឹងធ្វើទោបដិសន្ធិ មកកោគមន៍
វិញ្ញាណខ្សៀង ។ ក៏ប៉ុន្តែមនុស្សលោកនេះ គ្មាននរណាដឹង ឃើញទេ អំពីមើល
កំណើត របស់ខ្លួនទេនោះ ដោយហេតុមកពីអ្នកទាំងនោះគ្មាននរណាដឹង
ពីឫសគល់នៃការសាវគុណ ជីពោះកាប្បបាន ដោយគាំមរ របស់ព្រះគុណម្ចាស់
ម្ចាស់ ។ ដូយទៅវិញ អ្នកទាំងនោះគ្រូបប៉ំ ទៅជាប្រព្រឹត្តិ អំពើ
យង់ឃ្លង់ក្រៀបយកខេះទៅវិញ ដោយហេតុមកពី ឃើញទៀតផង :
ខ្លួនគេនោះ ស្ថិតនៅក្នុងការគ្រប់ប្រាកដ ពិតប្រាកដ ។

ផ្លែទីន   التين

អំពីវគ្គ វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន ៨ បន្ទូល ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ بروج ។
ឈ្មោះ التين មានន័យថា ផ្លែទីន ។
គេយកមកហៅជាឈ្មោះនៃ التين ដែលមាននៅក្នុងបន្ទូលទីមួយបង្អស់នៃវគ្គនេះ

គោលការណ៍ដ៏សំខាន់ក្នុងន័យរបស់វគ្គ

មនុស្សនេះជាសត្វលោក ដែលទ្រង់បានបង្កើត អោយមានមនោសញ្ចេតនា និងកាយវិការល្អជាទីបំផុត ក៏ប៉ុន្តែគង់តែគេនឹងបង្កើត អ្នកណានឹងអោយទៅជា អ្នកដែលថោកទាបជាទីបំផុតវិញ លើកលែងតែអ្នកទាំងនោះ ដែលមានជំនឿស៊ប់ ហើយនិងបាន អនុវត្តកិច្ចប្រតិបត្តិ ដ៏ល្អនោះ ទៅដំណោះកុសលល្អ ។

التين
ផ្លែទីន

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់ មហាសប្បុរស ទៀតទ្រង់មហាមេត្តាប្រណី ។   بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១ (អល់ឡោះ) បានស្បថថា ហើយ និងផ្លែទីន (التين) និងផ្លែហ្សៃទូន (الزيتون) ។   ١ وَالتِّيْنِ وَالزَّيْتُوْنِ

២ ហើយនិងភ្នំ ទួរស៊ីនីន (طور سنين)   ٢ وَطُوْرِ سِيْنِيْنَ

៣. ហើយនិងស្រុកម៉ាក្កាស់ (مكة) ដែល
សុខ ក្សេមក្សាន្ត ។ وَهَٰذَا الْبَلَدِ الْأَمِينِ ٣

៤ ពិតប្រាកដ យើងបានបង្កើត មនុស្សលោក
ក្នុងសភាព រាងកាយដ៏ល្អប្រពៃ ។ لَقَدْ خَلَقْنَا الْإِنْسَانَ فِي أَحْسَنِ تَقْوِيمٍ ٤

៥. បន្ទាប់មកយើងបាន បង្វិលត្រឡប់ វាទៅជា
កន្លែងដែលទាបជាងគេបំផុត (ឋាននរក) ។ ثُمَّ رَدَدْنَاهُ أَسْفَلَ سَافِلِينَ ٥

៦ វៀរលែងតែ បណ្ដាអ្នកដែលមានជំនឿជឿហើយ
ហើយ ក៏ព្រមទាំងបានប្រព្រឹត្តិ អំពើល្អដ៏ប្រសើរ
ស្អាត ។ ដូច្នោះហើយ ទើបបានជា សំរាប់អ្នក
ទាំងអស់នោះ បានផលបុណ្យ ជាប់ជានិច្ច
គ្មានដាច់ឡើយ ។ إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ فَلَهُمْ أَجْرٌ غَيْرُ مَمْنُونٍ ٦

៧ ទើបបានជា ស្អីទៅ ដែលនាំឲ្យពួកអ្នក
សិស ភូតកុហក នឹងថ្ងៃបរលោក នោះ ។ فَمَا يُكَذِّبُكَ بَعْدُ بِالدِّينِ ٧

៨ តើពុំមែនទេឬ? អល់ឡោះជាម្ចាស់ មហាអស្ចារ្យ
ដ៏លើសបណ្ដាអ្នកកាត់សេចក្ដីទាំងឡាយ ។ أَلَيْسَ اللَّهُ بِأَحْكَمِ الْحَاكِمِينَ ٨

ឋិតិភាពវត្ត វគ្គនេះ គេបានបញ្ជាក់ អំពីដំណើរការកើតនៃសភាពរស់នៅ របស់មនុស្សលោក ហើយនិងការដឹងពីយុត្តិធម៌ របស់អល់ឡោះជាម្ចាស់ ។

ការទូលំទូលាយ الانشراح

កបិតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៨ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الضحى ឈ្មោះ الشرح មានន័យថា ការទូលំទូលាយ
គេយកមកអំពីពាក្យសំដី الشرح ដែលមាននៅក្នុងឃ្លាជាដំបូងបង្អស់ក្នុងវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗ ក្នុងន័យរបស់វគ្គ

វគ្គនេះបញ្ជាក់ អំពីការសោកសិយរបស់អល់ឡោះ ដែលទ្រង់បានប្រទានទៅចំពោះ សាវ័ក(ណាពី) មូហាំម៉ាត់ ហើយអល់ឡោះ បានបញ្ជាក់អំពីទុបសុគ លំបាកវេទនានោះ រឿងដែលគេដែលបានប្រមាណនឹងដល់ ស្រណុកសុខសប្បាយមិនខានឡើយ ។ ទៀត អល់ឡោះទ្រង់បានបញ្ជាទៅចំពោះ សាវ័ក(ណាពី) ដើម្បីអោយសាវ័ក(ណាពី) មានចិត្តរឹងប៉ឹង ប្រកបកិច្ចការ ដ៏ល្អោះត្រង់ ល្អបរិសុទ្ធ ហើយប្រគល់ទោតភាស្នា ការតាំងអស់ ទៅចំពោះអល់ឡោះជាម្ចាស់ ។

الانشراح
ការទូលំទូលាយ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាមអល់ឡោះម្ចាស់ទ្រង់មហាសាណាណិតៀតទ្រង់មហាមេត្តាប្រណី ។

١ أَلَمْ نَشْرَحْ لَكَ صَدْرَكَ

១. តើគ្មានទេឬ ? យើងបានពង្រីកយើងទូលំទូលាយ សំរាប់អ្នកឯងដ៏ទ្រូងរបស់អ្នកឯង ។

២ យើងបានបន្ធូរបន្ថយ អំពីអ្នកឯង នូវ
ទោសពៃរ៍ដ៏ធ្ងន់ធ្ងរ របស់អ្នកឯង ។ | ووضعنا عنك وزرك ٢

៣. វានោះ ហើយដែលសង្កត់ធ្ងន់ធ្ងរ នៅ
លើខ្នងអ្នកឯង | الذي أنقض ظهرك ٣

៤ ហើយយើងបានលើកតំកើងចំពោះអ្នក
ឯង និងកិត្តិយស នាមរបស់អ្នកឯង ។ | ورفعنا لك ذكرك ٤

៥. ដើម្បីបានដឹង ពិតប្រាកដ ជាមួយនឹងការវេទនា
នោះ រមែងតែងតែ ជួបប្រទះនឹងការងាយ
ស្រណុកស្រួល ។ | فإن مع العسر يسرا ٥

៦ ពិតប្រាកដ ជាមួយនឹងការវេទនានោះរមែង
តែងតែ ជួបប្រទះនឹងការងាយស្រណុកស្រួល ។ | إن مع العسر يسرا ٦

៧. ហើយពេលណាដែលឯងបានរួចស្រឡះ
អំពីកិច្ចការរបស់ឯងរួច ចូរឯងខិតខំ និងកិច្ច
ការដែលល្អៗទៀត ។ | فإذا فرغت فانصب ٧

៨. ចំពោះម្ចាស់ឯងនោះ ហើយ ដើម្បីឯង
សង្ឃឹមចុះ ។ | وإلى ربك فارغب ٨

បិទ កថាវិត្ត វគ្គនេះ បានបញ្ជាក់បង្ហាញ អំពីការផ្ដល់នូវការសប្បាយ
រីករាយ ទៅចំពោះណាពី (ណាព្ពី) មូហាំម៉ាត់ សូលឡល់ឡហ៊ូអាឡៃហ៊ីវ៉ា-
សាល់ឡាំ ។

ពេលព្រឹកពេញពន្លឺ الضحى

ការវិវត្តវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាកាស់ ដែលមាន ១១ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الفجر ។ ឈ្មោះ الضحى មានន័យថា ពេលព្រឹកពេញពន្លឺ

គេបានយកសំពីពាក្យសំដី الضحى ដែលមាននៅក្នុងឃ្លាទីមួយ.

បង្ហាញនៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អល់ឡោះទ្រង់មិនដែលបោះបង់ចោលឆ្ងាយពីសាវ៉ា(ណាពី) មូហាំម៉ាត់ ម្តងណាឡើយ ។

- ការជម្រុលបង្ហាញរបស់ អល់ឡោះនោះ គឺពីការរស់នៅរបស់ សាវ៉ា(ណាពី) មូហាំម៉ាត់ អល់ឡោះជ្រើសរើសហើយទាំងសាលល្អ ដោយទីកន្លែងរីកចម្រើនល្អៗ ។
- ការហាមឃាត់ គឺកុំអោយធ្វើបាបដល់កូនកំព្រាឪពុក ហើយនិងកុំអោយកំហែងកំហែងទៅដល់ពួកអ្នកដែលសុំទាន ហើយគេត្រូវតែ ដោយលើង ចំពោះក្នុងការនិយាយស្តីពីសេចក្តីសុខសប្បាយ ដែលអល់ឡោះទ្រង់បានដោយមកលើគេនោះ នេះជាការតម្កល់នូវក្តីសរសើរ សារទ នៃគុណបំណាច់របស់ អល់ឡោះ ជាម្ចាស់ ។

الضحى
ពេលព្រឹកពេញពន្លឺ

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហាសប្បុរស ទៀតទ្រង់មហាមេត្តាប្រណី ។ 	بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១. (អល់ឡោះ) បានស្បថហើយតាមពេលព្រឹកពេញពន្លឺ ។ 	وَالضُّحٰى ١

២. ហើយទៀត ទ្រង់បានស្បថនឹងពេលរាត្រី
ដ៏ស្ងប់ស្ងាត់ ។

٢ وَالَّيْلِ إِذَا سَجَىٰ

៣ ម្ចាស់អ្នក ទ្រង់ពុំបានបោះបង់ចោលអ្នក
ឡើយ (ឱ មូហាំម៉ាត់) ហើយទ្រង់ពុំបាន
ស្អប់ខ្ពើមអ្នកឡើយ ។

٣ مَا وَدَّعَكَ رَبُّكَ وَمَا قَلَىٰ

៤ ហើយ ពិតប្រាកដ ថ្ងៃបរលោកនោះ
លើសល្អ សំរាប់អ្នក ជាងលោកិយ ។

٤ وَلَلْآخِرَةُ خَيْرٌ لَّكَ مِنَ الْأُولَىٰ

៥ ហើយពិតប្រាកដទៀត ម្ចាស់អ្នកនឹងទ្រង់
នឹងប្រទាន ចំពោះអ្នក ហើយអ្នកនឹងនឹង
ទទួលយល់ព្រម ។

٥ وَلَسَوْفَ يُعْطِيكَ رَبُّكَ فَتَرْضَىٰ

៦. តើគ្មានទេឬ? ទ្រង់បានជួបប្រទះនឹងអ្នក
ស្ថិតនៅលក្ខណៈកំព្រា ហើយទៀតទ្រង់បាន
ជួយសង្គ្រោះអ្នកនៅពេលនោះ ។

٦ أَلَمْ يَجِدْكَ يَتِيمًا فَآوَىٰ

៧. ហើយទ្រង់បានជួបប្រទះនឹងអ្នកគង់
កាលនៅវង្វេង: អ្នកកំពុងតែវង្វេង ហើយទើប
ទ្រង់បានចង្អុលបង្ហាញ អ្នក ។

٧ وَوَجَدَكَ ضَالًّا فَهَدَىٰ

៨. ហើយទ្រង់បានជួបប្រទះនឹងអ្នកគង់
កាលអ្នកនៅក្រ: អ្នកកំពុងតែក្រីក្រ ហើយ
ទ្រង់បានប្រទាន នូវភាពបរិបូណ៌គ្រប់បែប
យ៉ាងចំពោះអ្នក ។

٨ وَوَجَدَكَ عَائِلًا فَأَغْنَىٰ

៩. ដូចនោះហើយ ចំពោះកូនកំព្រា ចូរអ្នក
កុំសង្កត់សង្កិន (បង្ខះបង្ខាប់) ។ — فَأَمَّا الْيَتِيمَ فَلَا تَقْهَرْ ٩

១០ ហើយនឹងចំពោះអ្នកដែលសុំទាន
ចូរអ្នកកុំគំហកកំហែង — وَأَمَّا السَّائِلَ فَلَا تَنْهَرْ ١٠

១១ ដូចនោះហើយ នឹងក្ដីសុខសប្បាយ អំពី
ម្ចាស់របស់អ្នកវិញ ចូរអ្នកសំដែងនិទានទៅចុះ។ — وَأَمَّا بِنِعْمَةِ رَبِّكَ فَحَدِّثْ ١١

បរិកថាវិគ្គ វគ្គនេះបានបញ្ជាក់ អំពីការមិនទុកចិត្ត ហើយនិងការ
ដៃទវក្កុរបស់ អល់ឡោះ ទៅចំពោះសាវ៉ះ(ណាពី) មូហាំម៉ាត់ សុល.
ឡលឡហ៊ុអាឡៃហ៊ិវ៉សាល់ឡាំ ដោយបណ្ដាលអោយមានជឿយ។
ហើយបន្ទាត់នេះបានបញ្ជាក់ទៅចំពោះសាវ៉ះ(ណាពី) ដើម្បីអោយ
សាវ៉ះ(ណាពី) មូហាំម៉ាត់ មានក្ដីមេត្តាករុណា និងមានចិត្តជួយទ្រោមទ្រង
អំពីបុគ្គលទាំង ក្ដីសុខសប្បាយ ។

៩២ ពេលរាត្រី الليل

កថាវិត្ត វគ្គនេះគេបានបញ្ចុះនៅ ម៉ិកកាស់ ដែលមាន ២១ឃ្លា។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الأعلى ឈ្មោះ الليل មានន័យថា ពេលរាត្រី

គេយកមកសំដៅពាក្យសំដី الليل ដែលមាននៅក្នុងឃ្លាទីមួយ បង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ការប្រឹងប្រែងរបស់មនុស្សលោកនេះ រមែងតែងតែ មានពុំស្មើគ្នាឡើយ ហេតុដូចនេះ ការទទួលនូវការតបស្នងសងរបស់គេនោះ ក៏មានលក្ខណៈប្លែកៗគ្នាដែរ ។

អ្នកដែលចូលចិត្តធ្វើសំណាបទាន ហើយមានចិត្តកោតខ្លាច ទៀត និងមានជំនឿជឿជាក់យ៉ាងប្រាកដ នូវការល្អៗដែលល្អនោះ គង់តែម្ចាស់ ទ្រង់ផ្តល់អោយយ៉ាងងាយ ចំពោះអ្នកនោះ ដើម្បីអោយបានប្រកប ការល្អ ដែលនាំអោយមានសេចក្តីរុងរឿង នៅអាខិរ៉ូ បរលោក ។ ផ្ទុយទៅវិញ អ្នកល្មោភ ទ្រង់បានផ្តល់អោយ យ៉ាងងាយ ចំពោះអ្នកនោះវិញ ដែលបានប្រព្រឹត្តនៅលើដែលអាក្រក់ និងនាំអោយអ្នក មានទុក្ខវេទនា នៅអាខិរ៉ូបរលោក ពេលនោះ ហើយទ្រព្យសម្បត្តិរបស់ គេ ក៏គ្មានបានផ្តល់ផលអ្វីទៅអោយចំពោះគេនោះដែរ ។

អ្នកដែលកំណាញ់ញញើតព្រហ្មា វាបានយល់ថា ខ្លួនគេនោះឯង មានគ្រប់គ្រាន់រស់ហើយ ហើយទៀតអ្នកនោះវាគ្មានជំនឿជឿជាក់ថា គ្មានផលប្រយោជន៍អ្វីទេ ។

الليل

ពេលរាត្រី

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

និងព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា
សាការុណ ទៀតដ៏មហាមេត្តាប្រណី ។

١ وَاللَّيْلِ إِذَا يَغْشَىٰ

១. (អល់ឡោះ) បានស្បថ ហើយនៅនាពេល
រាត្រី ពេលណាដែលរស្មីនៃព្រះអាទិត្យ
មករួបដណ្តប់លើផែនដី ។

٢ وَالنَّهَارِ إِذَا تَجَلَّىٰ

២. ហើយ(ទ្រង់) ស្បថទៀតនឹងពេលថ្ងៃ
ពេលណាដែលបានបញ្ចេញហើយពន្លឺរស្មី
(រស្មីព្រះអាទិត្យ) ។

٣ وَمَا خَلَقَ الذَّكَرَ وَالْأُنثَىٰ

៣ ហើយ(ទ្រង់)បានបង្កើតភេទប្រុសនិងភេទស្រី

٤ إِنَّ سَعْيَكُمْ لَشَتَّىٰ

៤ ពិតប្រាកដ កិច្ចការដែលអ្នកទាំងអស់គ្នា
ក្នុងលោកនេះ មានលក្ខណៈផ្សេងៗគ្នា ។

٥ فَأَمَّا مَنْ أَعْطَىٰ وَاتَّقَىٰ

៥ ទើបអ្នកណាដែល ឱ្យទានហើយដែលបាន
ដល់(ទាំងដែលអល់ឡោះទ្រង់បានប្រើនោះ)
ទៀតអ្នកនោះបានកោតខ្លាចហើយជឿព្រះត្រា

٦ وَصَدَّقَ بِالْحُسْنَىٰ

៦ ហើយគេបានជឿជាក់នឹងការនឹងទទួលល្អ ។

៧. ទើបបានជាយើង (អល់ឡោះ) គង់តែនឹង
ទំនុកបំរុង វា ទៅផ្លូវងាយស្រួល ។

فَسَنُيَسِّرُهُ لِلْيُسْرَىٰ ٧

៨. ហើយរីឯជននោះ នរណាហើយដែលកំណា-
-ញ់ ទៀតគិតនឹកស្មានថា លើខ្លួនគេនោះ មាន
គ្រប់គ្រាន់ បរិបូណ៌ហើយ ។

وَأَمَّا مَنْ بَخِلَ وَاسْتَغْنَىٰ ٨

៩. ហើយវាភូតភរ កុហក នឹងការដែលល្អប្រសើរ

وَكَذَّبَ بِالْحُسْنَىٰ ٩

១០ ទើបបានជាយើង (អល់ឡោះ) គង់តែទំនុក-
បំរុង វានោះ ទៅលើផ្លូវលំបាកវេទនា ។

فَسَنُيَسِّرُهُ لِلْعُسْرَىٰ ١٠

១១- និងទ្រព្យសម្បត្តិរបស់វាដែលពុំមានផលប្រយោ-
-ជន៍ សំរាប់វានោះទេ ពេលណាវាបានចូល
មរណភាព ។

وَمَا يُغْنِي عَنْهُ مَالُهُ إِذَا تَرَدَّىٰ ١١

១២ ពិតប្រាកដ នៅលើយើងនោះសំរាប់ចង្អុល
បង្ហាញ ។

إِنَّ عَلَيْنَا لَلْهُدَىٰ ١٢

១៣. ហើយពិតប្រាកដ. បានបរលោក និង
លោកីយនេះ ជាកម្មសិទ្ធិ របស់យើង ។

وَإِنَّ لَنَا لَلْآخِرَةَ وَالْأُولَىٰ ١٣

១៤ ទើបដូចនោះហើយ យើងបានហាម
ប្រាម ចំពោះអ្នកទាំងអស់គ្នា នឹងឋាននរក
ដែលកំពុងតែឆេះរលោង ។

فَأَنْذَرْتُكُمْ نَارًا تَلَظَّىٰ ١٤

១៥. [illegible]	١٥ لَا يَصْلَاهَا إِلَّا الْأَشْقَى
១៦ [illegible]	١٦ الَّذِي كَذَّبَ وَتَوَلَّى
១៧. [illegible]	١٧ وَسَيُجَنَّبُهَا الْأَتْقَى
១៨. [illegible]	١٨ الَّذِي يُؤْتِي مَالَهُ يَتَزَكَّى
១៩. [illegible]	١٩ وَمَا لِأَحَدٍ عِنْدَهُ مِنْ نِعْمَةٍ تُجْزَى
២០. [illegible]	٢٠ إِلَّا ابْتِغَاءَ وَجْهِ رَبِّهِ الْأَعْلَى
២១. [illegible]	٢١ وَلَسَوْفَ يَرْضَى

[illegible]

ដោយគ្រោះទោសគាត់ឫស្សីពេញវៀសមាឡៃ បរលោកគោះ ។

ព្រះអាទិត្យ الشمس

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅ ម៉ាក្កាស់ ដែលមាន១៥ឃ្លា គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ القدر

ឈ្មោះ الشمس មានន័យថា ព្រះអាទិត្យ

គេយកមកអំពីពាក្យសំដីថា الشمس ដែលមាននៅក្នុងឃ្លាដំបូង បង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អុលឡោះបានបំផ្លាញដោយរលាយសាបសូន្យអស់ហើយក្រុមរបស់ (សាមូដ) ដោយសារតែការប្រឆាំងរបស់វា ។

ទ្រង់បានបង្ហាញប្រាប់ថា ហេតុការណ៍ដែលសម្លាប់វិនាសនោះ ជាការងាយជាទីបំផុតសំរាប់ទ្រង់ ។

ក្រៅពីនោះដែរ ទ្រង់គឺជាអ្នកបង្កើតទៀត វត្ថុធាតុប្លែកៗ ដែលនៅក្នុងលោកនេះ ថ្ងៃ និងយប់ ហើយទ្រង់បានបង្កើតវិញ្ញាណ ដែលទ្រង់បានរៀប ក្នុងសណ្ឋានរបស់ទ្រង់ជួមគល់ហើយស្រេច ។

អុលឡោះទ្រង់បានដោយពន្យល់ទៅចំពោះមនុស្សលោក ថាមាន ផ្លូវពីរ៖

១. ផ្លូវដែលនាំទៅរក មានការគោរពកោតខ្លាច និងជឿស៊ប់ចំពោះទ្រង់
២. ផ្លូវដែលវង្វេងប្រឆាំងនឹងទ្រង់ ។

ឯមនុស្សលោកយើង មានសិទ្ធិសេរីភាពពេញបរិបូណ៌ ដែលអាចជ្រើសរើស រកផ្លូវដែលគេយល់ត្រូវ អំពីផ្លូវទាំងពីរនោះ គឺផ្លូវសុចរិត និងផ្លូវទុច្ចរិត ។

الشمس

ព្រះអាទិត្យ

នឹងព្រះនាម អុលឡោះ ជាម្ចាស់ទ្រង់មហា ករុណាករ ទៀតទ្រង់មហា មេត្តាប្រណី ។	بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ
១. (អុលឡោះ) បានស្បថនឹងព្រះអាទិត្យហើយ នឹងពន្លឺរស្មីរបស់វា ។	١ وَالشَّمْسِ وَضُحَاهَا
២. ហើយ (ទ្រង់) បានស្បថទៀត នឹងព្រះចន្ទ កាលបើចេញមុខ បន្ទាប់ពីរស្មីនៃព្រះអាទិត្យ លិច ។	٢ وَالْقَمَرِ إِذَا تَلَاهَا
៣ ហើយ (ទ្រង់) បានស្បថទៀត នឹងពេលថ្ងៃ ពេលណា វាបានបញ្ចេញរស្មីវា (ព្រះអាទិត្យ) ។	٣ وَالنَّهَارِ إِذَا جَلَّاهَا
៤ ហើយ (ទ្រង់) បានស្បថទៀត នឹងពេលយប់ ពេលណាវាងងឹត ពន្លឺងងឹតមកគ្របដណ្តប់ លើវា ។	٤ وَاللَّيْلِ إِذَا يَغْشَاهَا
៥ ហើយ (ទ្រង់) បានស្បថនឹង មេឃ ជាមួយនឹង អ្នកកសាងវា	٥ وَالسَّمَاءِ وَمَا بَنَاهَا
៦. ហើយ (ទ្រង់) បានស្បថនឹងផែនដី ជាមួយ នឹង អ្នកលាតត្រដាងវា ។	٦ وَالْأَرْضِ وَمَا طَحَاهَا
៧. ហើយ (ទ្រង់) បានស្បថ នឹងរូបរាងកាយ នឹង អ្នកបំពេញលក្ខណៈវា	٧ وَنَفْسٍ وَمَا سَوَّاهَا

៨. ហើយព្រះអង្គ (អល់ឡោះ) បានចង្អុលបង្ហាញ
ចំពោះរូបកាយនោះ នូវអំពើទុច្ចរិត
របស់វា ហើយនិងអំពើសុចរិតរបស់វា ។

٨ فَأَلْهَمَهَا فُجُورَهَا وَتَقْوَاهَا

៩. ពិតប្រាកដ បានជោគជ័យហើយ អ្នក
ដែលសំអាតកាយរបស់វា (ឬវិញ្ញាណរបស់វា)

٩ قَدْ أَفْلَحَ مَن زَكَّاهَا

១០. ហើយពិតប្រាកដ បានបរាជ័យហើយ
អ្នកដែល ស្មោកគ្រោក វា (វិញ្ញាណ) ។

١٠ وَقَدْ خَابَ مَن دَسَّاهَا

១១. បានភូតកុហក ហើយ ពួក ថាមូដនោះ
ដោយសារការរំលោភច្បាប់របស់គេឯង ។

١١ كَذَّبَتْ ثَمُودُ بِطَغْوَاهَا

១២. ពេលដែលបានងើប ចេញឡើង អ្នកដែលកាច
សាហាវនោះ នៅក្នុងចំណោមអ្នកទាំងអស់នោះ ។

١٢ إِذِ انبَعَثَ أَشْقَاهَا

១៣. បានប្រកាស ហើយ រ៉សូលុលឡោះ ទៅ
ចំពោះពួកទាំងអស់នោះ (ចូរអ្នកទាំងអស់គ្នា) សូម
ការពារអូដ្ឋនេះរបស់ អល់ឡោះ ហើយចូរទុកឲ្យ
វា ការស្រេកទឹករបស់វា ។

١٣ فَقَالَ لَهُمْ رَسُولُ اللَّهِ نَاقَةَ اللَّهِ وَسُقْيَاهَا

១៤ ហើយអ្នកទាំងអស់នោះ បានភូតកុហក រ៉សូលុល
ឡោះ (ពោលគឺ សច្ចធម៌ ការប្រៀនប្រដៅ)
ហើយ ពួកទាំងអស់នោះ បានសម្លាប់វា (អូដ្ឋ)
ហើយ ព្រះម្ចាស់ពួកទាំងអស់នោះ ក៏បានធ្វើឲ្យ
វិនាស សព្វគ្រប់ ហើយ ទៅលើពួកទាំងអស់

١٤ فَكَذَّبُوهُ فَعَقَرُوهَا فَدَمْدَمَ عَلَيْهِمْ رَبُّهُم بِذَنبِهِمْ فَسَوَّاهَا

-នោះ ដោយសារតែការ បាបកម្ម របស់ពួកទាំង
នោះ ហើយម្ចាស់ទ្រង់បាន រំលាយ ក្រុមទាំង
អស់នោះ ទៅជារាបស្មើ (ដំរីងី) ។

١٥. ហើយ (អល់ឡោះ) មិនកោតខ្លាចទេ អំពី ការសងសឹក ពួកទាំងអស់នោះ ។ وَلَا يَخَافُ عُقْبَاهَا 10

ឋិត កថាវត្ថុ វគ្គនេះបានបញ្ជាក់ អំពីគោលការណ៍ដ៏សំខាន់ សំរាប់ ទំនុកបំរុង មនុស្សលោក ដើម្បីខិតខំរក្សាអាត្មាវិញ្ញាណ របស់គេ នោះ សំរាប់និងបាននូវសុខ ការចំណេញ ជោគជ័យ នៅក្នុងលោកនិងនៅ បរលោកផង ។

ទៀតបានបញ្ជាក់ អំពី អល់ឡោះ បាននិយាយ អនុគ្រោះ ទៅដល់ពួក បណ្ដាអ្នក ដែលធ្វើឲ្យវិញ្ញាណខ្លួន របស់គេនៅជាកន្លែង ដូចជាបណ្ដា ក្រុមរបស់ពួក ស៊ើមូដ ដូចគ្នាដែរ ។

ស៊ូរ៉ោះ البلد

កឋាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ២០ឃ្លា ។

គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ ទី ។

ឈ្មោះ البلد មានន័យថា ស្រុក (ម៉ិកកាស់)

គេយកមកពីពាក្យសំដី البلد ដែលមាននៅក្នុងឃ្លាទី ដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

អុលឡោះបានបង្កើតមនុស្សលោក ដើម្បីសាកល្បងមើលការតស៊ូ ក្នុងជីវិតជាមួយនឹងគ្រប់បញ្ហាទាំងអស់ដែលមាននៅក្នុងលោក ។ តើមនុស្សនឹងគិតថា មនុស្សលោកអើយ! ត្រូវសាកល្បងមើលចាក់ឬជ្រងនឹង បញ្ហាសង្គមដ៏ស្មុគស្មាញ ហើយនឹងគ្រោះថ្នាក់ ដែលកើតឡើង ដោយអ្នកទាំងនោះ បានធ្វើការបូជារួចមកហើយនោះ ។

ការរៀបរាប់ផ្លូវទាំងពីរ រួចមកហើយនោះ ទៅដល់ពោះមនុស្សលោក ទៅលើ ជីវិតមនុស្សលោក ដែលទ្រង់បានរៀបរាប់រួច ទៅលើអ្នកទាំងនោះ ។

ទ្រង់បានដាស់តឿនដែលសាដ្ឋី នឹងតាំងពីអ្នកទាំងនោះបានទទួលការ ជោគជ័យ ហើយនឹងសិរីសួស្តីដែល នឹងទៅលើអ្នកទាំងនោះស្ថិតនៅក្នុងជីវិតនៃ ម៉ាហាឆ្លាចក្ដុ ។

البلد

ស៊ូរ៉ោះ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

នឹងព្រះនាម អុលឡោះ ម្ចាស់ទ្រង់មហា ករុណាធិគុណទ្រង់មហាមេត្តាប្រណី

١ لَا أُقْسِمُ بِهَٰذَا الْبَلَدِ

១. ពិតប្រាកដ អញបានស្បថនឹងស្រុក នេះ (ម៉ិកកាស)

٢ وَأَنتَ حِلٌّ بِهَٰذَا الْبَلَدِ

២ ហើយឯង (ឱនៈ! មូហាំម៉ាត់) មានសិទ្ធិ សេរីភាពនៅក្នុងស្រុកនេះ (ម៉ិកកាស់)

٣ وَوَالِدٍ وَمَا وَلَدَ

៣. ហើយ (ស្រលឡោះ) បានស្បថនឹងឪពុក ហើយនឹងកូន (អាដាំ ហើយនឹងកូនចៅរបស់ គាត់)

٤ لَقَدْ خَلَقْنَا الْإِنسَانَ فِي كَبَدٍ

៤. ពិតប្រាកដ យើងបានបង្កើតមនុស្សលោក (រស់នៅ) ក្នុងការមាន ទុក្ខ សោក ។

٥ أَيَحْسَبُ أَن لَّن يَقْدِرَ عَلَيْهِ أَحَدٌ

៥. តើពួកវាមានគិតរឺ? ការគាត់ស្មានរបស់ វាគោះថា ពិតប្រាកដ គ្មាននរណា ម្នាក់ឡើយ មានអំណាចនៅលើវា

٦ يَقُولُ أَهْلَكْتُ مَالًا لُّبَدًا

៦. វាពោលថា អញបានចំណាយទ្រព្យ សម្បត្តិ យ៉ាងច្រើន

٧ أَيَحْسَبُ أَن لَّمْ يَرَهُ أَحَدٌ

៧. តើពួកវាមានគិតរឺ? ការគាត់ស្មានរបស់ វា ថា ពិតប្រាកដជាគ្មាននរណា ម្នាក់ឃើញ វាទេ

٨ أَلَمْ نَجْعَل لَّهُ عَيْنَيْنِ

៨. តើពុំមានទេឬ! យើងបានប្រទានចំពោះ វា ពីរចក្ខុ

៩. ហើយនិងអណ្តាតទៀតនិងបបូរមាត់ ទាំងពីរ | ٩ وَلِسَانًا وَشَفَتَيْنِ

១០. ហើយយើងបានចង្អុលបង្ហាញចំពោះគេ នោះ: ផ្លូវពីរ (ល្អនិងអាក្រក់) | ١٠ وَهَدَيْنَـٰهُ ٱلنَّجْدَيْنِ

១១ ក៏ប៉ុន្តែគេមិនបានព្យាយាមនៅលើផ្លូវដ៏លំបាក នោះ។ | ١١ فَلَا ٱقْتَحَمَ ٱلْعَقَبَةَ

១២. តើអ្នកឯងបានដឹងដែរឬទេ? ផ្លូវដ៏លំបាក នោះ? | ١٢ وَمَآ أَدْرَىٰكَ مَا ٱلْعَقَبَةُ

១៣ នោះហើយ គឺលែងសេរីភាពទៅអោយទាសបំរើ។ | ١٣ فَكُّ رَقَبَةٍ

១៤ ឬផ្តល់ចំណីអាហារនៅក្នុងថ្ងៃដែលស្រេកឃ្លាន។ | ١٤ أَوْ إِطْعَـٰمٌ فِى يَوْمٍ ذِى مَسْغَبَةٍ

១៥. ចំពោះកូនកំព្រាដែលជាសាច់ញាតិណាមួយ។ | ١٥ يَتِيمًا ذَا مَقْرَبَةٍ

១៦. ឬ (ចំពោះ) អ្នកក្រីក្រគោកយាក។ | ١٦ أَوْ مِسْكِينًا ذَا مَتْرَبَةٍ

១៧. ហើយបន្ទាប់មក នរណាម្នាក់ មានជំនឿ ជឿ (ចំពោះអល់ឡោះ) ហើយបានដាស់តឿននូវការអត់ធ្មត់ ហើយបានដាស់តឿននូវការអាណិតស្រឡាញ់ | ١٧ ثُمَّ كَانَ مِنَ ٱلَّذِينَ ءَامَنُوا۟ وَتَوَاصَوْا۟ بِٱلصَّبْرِ وَتَوَاصَوْا۟ بِٱلْمَرْحَمَةِ

១៨. អ្នកទាំងអស់នោះ ហើយ ជាក្រុមខាងស្តាំ។ | ١٨ أُو۟لَـٰٓئِكَ أَصْحَـٰبُ ٱلْمَيْمَنَةِ

១៩. ហើយរាល់ៗហើយដែលគ្មានជំនឿជឿ
នឹងគម្ពីរ (ប្រយោគនៃ គួរអាន) របស់យើង
ពួកទាំងអស់នោះហើយជាពួកអមខាងឆ្វេង ។ وَالَّذِينَ كَفَرُوا بِآيَاتِنَا هُمْ أَصْحَابُ الْمَشْأَمَةِ ١٩

២០. នៅលើពួកទាំងអស់នោះ ភ្លើងនរកគ្របដណ្ដប់ជា عَلَيْهِمْ نَارٌ مُؤْصَدَةٌ ٢٠

ឋិតក្រោមវគ្គ ទិសគតនេះបានបញ្ជាក់ អំពីមនុស្សលោក ដែលនឹងនៅដែល
ពោរពេញដោយការវេទនាខ្លះៗ មិនមានទៀបរ នៅក្នុងការ ស្វះស្វែងរក
ផ្លូវត្រូវសម្រាប់ខ្លួននោះ ។

អ្នកល្អៈ បានទទួលហៅយកដោល់ អំពីដំណឹងល្អដែលមានក្តីសុខក្សេម
ក្សាន្ត និងក្តីរីករាយទៀត ដែលនាំមកយមានការប្រោះប្រាក់ ។

អ្នកអាក្រក់ៈ បានទទួលបញ្ជាំង អំពីដំណឹងលំបាកតែម៉ោងរកតក្តីសុខដំរើង
នោះឯង ព្រោះគេមិនមានការលំបាក និង ទុក្ខ សត្វធាត មកឡើងធ្វើឲ្យក្លាំង
ដំណើរទៅដល់គោលដៅ ដឹកនាំខ្លួនដោយផ្ដែងក្តីសុខដំរើងនោះ គឺមានមិនមានទៀប
ហើយដំណើរខ្លះទៅកាន់ ការបង្រៀប សម្រេចយ៉ាងក្រាស់ អ្នកមាន
នោះ ពិតជាមិនស្រួលក្នុងដំណើរជាថ្មីបំផុត ដោយគ្មានអ្វីៗ ដែលទាំង
អស់ឡើយ ។

ពេលពន្លឺព្រះអាទិត្យជៀបនឹងរះ الفجر

កថាវគ្គ វគ្គនេះ គេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣០ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الليل

ឈ្មោះ الفجر មានន័យថា ពេលពន្លឺព្រះអាទិត្យជៀបនឹងរះ

គេយកមកអំពីពាក្យសំដី الفجر ដែលមាននៅក្នុងបន្ទាត់ដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អុលឡោះ បានស្បថ ដោយប្រាកដថា ទារុណកម្ម នៅចំពោះបណ្ដាអ្នកគ្មានជំនឿនោះឯង ពុំអាចនឹងរួចខ្លួនបានទេ គឺគង់អាក់ខានឡើយ ។

- ប៉ុន្មានរឿង អំពីបណ្ដាក្រុមៗ ដែលត្រូវវិនាសហិនហោចរួចទៅហើយ ។

- ការដោតន័យនៃទ្រព្យ សុខចំរើន ក្នុងការរស់នៅ ម្ដងម្កាលគ្រោះថ្នាក់ ដែលបានរួចប្រសេះ ប្រែមកហើយនោះ គឺជាការសាកល្បងទៅលើអ្នកទាំងនោះឯង ។

- ការគ្មោះនិងសញ្ចើល នៅចំពោះបណ្ដាអ្នកដែលគ្មានជំលាងចង់បំបាត់ដំណក្សត្រ ក្មេងកំព្រា ហើយថែមទៀតគ្មានអំណោយ ដោយចំណីអាហារ នៅចំពោះជនក្រីក្រ លំបាកគោកយាក ។

- ការស្នើសុំបុគ្គលិកញ នៅចំពោះអ្នកដែលគេបង្រៀនហ៊ាក់ញ សុំគេឲ្យមកដែក ហៅថា និងមានការលោភលន់ស្រលាញ់ទ្រព្យសម្បត្តិ ។

- ការគ្រោះថ្នាក់នៅពេលមុននោះ ប្រាកដ ហើយដែលនឹងរួចប្រសេះទេ ចំពោះបណ្ដាអ្នកដែលគ្មានជំនឿនោះ គឺនៅនាពេលថ្ងៃបរលោក ។

- បណ្ដាអ្នកដែលមានសន្តិភាពព្រលឹង និងអំ អ្នកនោះនឹងត្រូវបានគេដាក់នឹង ព្រលឹង ការគាប់ប្រសើរដ៏ខ្ពង់ខ្ពស់ អំពី អុលឡោះជាម្ចាស់គេ ឥតខានឡើយ

الفجر

ពេលពន្លឺព្រះអាទិត្យទៀបភ្លឺ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់
មហាសាធុករុណ៍ទៀតទ្រង់មហាមេត្តាប្រណី។

١ وَالْفَجْرِ

១. (អល់ឡោះ) បានស្បថនឹងពេលពន្លឺព្រះអាទិ
ត្យទៀបនឹងរះ ។

٢ وَلَيَالٍ عَشْرٍ

២ ហើយនៅពេលយប់ដ៏ដំបូងទាំងដប់(១០)
(នៅដំបូងក្នុងខែ ហ្ស៊ុលហាជ្ជះ ذوالحجة)

٣ وَالشَّفْعِ وَالْوَتْرِ

៣. ហើយវត្ថុដែលគត់គូ ហើយនិងវត្ថុដែល
សេសគូ ។

٤ وَالَّيْلِ إِذَا يَسْرِ

៤. ហើយ(អល់ឡោះ) បានស្បថនឹងយប់ទៀត
ពេលយប់ ពេលណាដែលកន្លងផុតទៅ។

٥ هَلْ فِي ذٰلِكَ قَسَمٌ لِّذِي حِجْرٍ

៥ តើក្នុងការស្បថនោះជាសច្ចាសម្រាប់អ្នកដែល
មានប្រាជ្ញាឬ?

٦ أَلَمْ تَرَ كَيْفَ فَعَلَ رَبُّكَ بِعَادٍ

៦. តើអ្នកឯងមិនបានឃើញទេឬ? ដូចម្តេចទៅ
ម្ចាស់អ្នកឯងបានធ្វើ(ទារុណកម្ម)ដល់ពួក
អាដ (عاد) ។

៧. ក្រុមអ៊ីរ៉ាម (ប្រទេសអ៊ីរ៉ាម) ដែលមានដំណាក់សសរខ្ពស់ និងស្អាតស្អំ ។ — ٧ إِرَمَ ذَاتِ الْعِمَادِ

៨. ដែលគ្មានគេកសាងទេ ដូចប្រទេសអ៊ីរ៉ាម នៅក្នុងពិភពលោក ។ — ٨ الَّتِي لَمْ يُخْلَقْ مِثْلُهَا فِي الْبِلَادِ

៩. ហើយក្រុមសាមូដ ដែលបានឆ្លាក់ខ្ទម ផ្ទាំងថ្មនិងដីភ្នំ (ជ្រលង) នៅកន្លែងទំនាប (الواد) — ٩ وَثَمُودَ الَّذِينَ جَابُوا الصَّخْرَ بِالْوَادِ

១០. ហើយក្រុមហ្វៀរអ៊ូន ដែលមានស្នឹងដ៏រឹងប៉ឹង (គល់ជ័ត និងជ្រនិង) — ١٠ وَفِرْعَوْنَ ذِي الْأَوْتَادِ

១១. អ្នកទាំងអស់នោះ បានឈ្លានពាន នៅក្នុងប្រទេស — ١١ الَّذِينَ طَغَوْا فِي الْبِلَادِ

១២ ហើយបានធ្វើ. ភាពចលាចល អ្នកទាំងអស់នោះ ធ្វើអំពើអាក្រក់នៅក្នុងប្រទេសនោះ ។ — ١٢ فَأَكْثَرُوا فِيهَا الْفَسَادَ

១៣. យើងនឹងនោះ ហើយ ម្ចាស់របស់ឯង បាន ទម្លាក់ នៅលើអ្នកទាំងអស់នោះ នូវរំពាត់នៃទារុណកម្ម ដ៏ខ្លោចផ្សា — ١٣ فَصَبَّ عَلَيْهِمْ رَبُّكَ سَوْطَ عَذَابٍ

១៤ ពិតប្រាកដ ម្ចាស់ឯង អ្នកដែលតាមឃ្លាំ ។ — ١٤ إِنَّ رَبَّكَ لَبِالْمِرْصَادِ

១៥. ដើបបានជា មួយដំពូកមនុស្សលោក — ١٥ فَأَمَّا الْإِنْسَانُ إِذَا مَا ابْتَلَاهُ

ពេលណាម្ចាស់របស់វា បានសាកល្បងវា ហើយ ដោយបានលើកដំកើងវា ហើយ បានប្រទានគុណ សុខស្រួលសប្បាយទៅវា ទើបបាននាំពោលថា ម្ចាស់របស់អញ បាន លើកដំកើងអញហើយ ។

رَبُّهُ فَأَكْرَمَهُ وَنَعَّمَهُ فَيَقُولُ رَبِّي أَكْرَمَنِ

១៦. ហើយឯចំណែកមនុស្សនោះទៀតផង ពេល ណាម្ចាស់របស់វា បានសាកល្បងវាហើយ ដោយបានកំរិត ការប្រទាន រីស្គី (رزق) ទៅលើវា. ទើបវានាំពោលថា ម្ចាស់អញ បានបន្ទាបបន្ថោកអញហើយ ។

١٦ وَأَمَّا إِذَا مَا ابْتَلَاهُ فَقَدَرَ عَلَيْهِ رِزْقَهُ فَيَقُولُ رَبِّي أَهَانَنِ

១៧. ពិតប្រាកដ មិនមែនដូច្នោះទេ ? ផ្ទុយទៅវិញ អ្នកទាំងអស់នោះ គ្មានអើពើ ដល់កូនកំព្រាទៀតឡើយ ។

١٧ كَلَّا بَل لَّا تُكْرِمُونَ الْيَتِيمَ

១៨. ហើយអ្នកឯងទាំងអស់គ្នា គ្មានការជំរុញគ្នា ផ្តល់ចំណីអាហារ ទៅលើអ្នកក្រីក្រទេ ។

١٨ وَلَا تَحَاضُّونَ عَلَىٰ طَعَامِ الْمِسْكِينِ

១៩. ហើយអ្នកឯងទាំងអស់គ្នា បានស៊ីកេរ្តិ៍ មរតក ស៊ីច្រើនឥតគួបមា

١٩ وَتَأْكُلُونَ التُّرَاثَ أَكْلًا لَّمًّا

២០ ហើយអ្នកឯងទាំងអស់គ្នា ស្រឡាញ់ ទ្រព្យសម្បត្តិ ដោយលើសលុបហួស ហេតុពេក ។

٢٠ وَتُحِبُّونَ الْمَالَ حُبًّا جَمًّا

២១ កុំដើម្បីទោះអី ពេលណាគេរំងួល ផែនដី ដោយរញ្ជួយញ័ររង្គើ ។ | كَلَّا إِذَا دُكَّتِ الْأَرْضُ دَكًّا دَكًّا 21

២២. ហើយបានមកដល់ម្ចាស់នៃអ្នក(មូហាំម៉ាត់) និងពពួកទេវៈ(ملك)ដែលស្ថិតរៀបជាជួរៗ ។ | وَجَاءَ رَبُّكَ وَالْمَلَكُ صَفًّا صَفًّا 22

២៣. ហើយគេបានបង្ហាញនរកនៅថ្ងៃនោះហើយ ឃើញនរក ហើយនៅថ្ងៃនោះទៀត មនុស្សលោកបានសញ្ជឹងគិតហើយ តើនៅពេលណា ការសញ្ជឹងគិតរបស់វានោះ ។ | وَجِايْءَ يَوْمَئِذٍ بِجَهَنَّمَ يَوْمَئِذٍ يَتَذَكَّرُ الْإِنْسَانُ وَأَنَّىٰ لَهُ الذِّكْرَىٰ 23

២៤ វាបានពោលថា ឱ ប្រសិនណា អញ បានធ្វើការ ល្អដើម្បីរួចសព្វមុនមក សំរាប់ ការរស់នៅរបស់អញ ។ | يَقُولُ يَالَيْتَنِي قَدَّمْتُ لِحَيَاتِي 24

២៥. ដើម្បីបាន នៅក្នុងថ្ងៃនោះ គ្មាននរណា ម្នាក់ឡើយ ដែលធ្វើទារុណកម្ម ដូចជា ទារុណកម្ម របស់ទ្រង់នោះទេ | فَيَوْمَئِذٍ لَا يُعَذِّبُ عَذَابَهُ أَحَدٌ

២៦. ហើយគ្មាននរណា ម្នាក់ឡើយ ចងខ្នោះ សង្វារ ដូចចងខ្នោះសង្វារ របស់ទ្រង់នោះទេ. | وَلَا يُوثِقُ وَثَاقَهُ أَحَدٌ

២៧. ឱ វិញ្ញាណ (النفس) ដ៏ នឹងនរហើយ! | يَا أَيَّتُهَا النَّفْسُ الْمُطْمَئِنَّةُ

២៨. វិលត្រឡប់ទៅវិញ ទៅចំពោះម្ចាស់របស់ អ្នកវិញដោយស្ម័គ្រស្រឡាញ់ព្រមទទួលការយល់ព្រម | ارْجِعِي إِلَىٰ رَبِّكِ رَاضِيَةً مَرْضِيَّةً

របស់ ព្រលឹងនោះ ។

២៩. ទើបបានជា ចូរខ្លួនឯងចូលចុះនៅក្រុម ខ្ញុំរបស់យើង ។ فَادْخُلِي فِي عِبَادِي ٢٩

៣០ ហើយ ចូរឯងចូលចុះក្នុងឋានសួគ៌ របស់ យើង ។ وَادْخُلِي جَنَّتِي ٣٠

បិតកាបវគ្គ វគ្គនេះបានបញ្ជាក់ បង្ហាញ អាកប្ប អំពីបណ្ដាក្រុម និងលទ្ធផលទាំងលោកខ្លួន ។

. ហើយនិងប៉ុន្មានឲ្យ លក្ខណៈ របស់មនុស្សលោក ដែល ក្រៀវបណ្ដាសារ ។

- ឡើងឥតឈប់ឈរ និងមិនញ៉ាក់ ទទឹកការត្អូញត្អែរ ដែលព្រលឹងនោះ ម្ចាស់ខ្លួន បានប្រទានហើយនោះ បណ្ដាអ្នកណាហើយ ដែលវិញ្ញាណ និងវិនិ ។

ថ្ងៃបរលោក الغاشية

កប្បាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក់កាស់ ដែលមាន២៦ឃ្លា
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ
الذاريات

ឈ្មោះ الغاشية មានន័យថា ថ្ងៃបរលោក

គេយកមកពីពាក្យសំដី الغاشية ដែលមាននៅក្នុងឃ្លាអាដំបូងបង្អស់នៃវគ្គនេះ ។

វគ្គនេះ រំលឹករ៉ស៊ូលុលឡោះ បានសួរគេសាវនវត្តន៍នៅក្នុងរឿងទាំង២ នៃថ្ងៃទំលៃ និងថ្ងៃឃុំឃាត់

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

វគ្គនេះបញ្ជាក់ អំពីបណ្តាអ្នកដែលគ្មានជំនឿជឿនៅថ្ងៃបរលោក និង ការដាក់ទារុណកម្ម ទៅលើបណ្តាអ្នកទាំងអស់នោះ ។

- បញ្ជាក់អំពីបណ្តាអ្នកមានជំនឿជឿ ជាមួយនឹងលក្ខណៈឋានសួគ៌ ដែលគេបានប្រទាន ទៅអោយចំពោះ អ្នកទាំងអស់នោះ ដើម្បីជួលអោយជារង្វាន់ក្នុងការតបស្នង ។

- បញ្ជា ដើម្បីអោយយកចិត្តទុកដាក់ អំពីវត្ថុធាតុផ្សេងៗ ក្នុងនិស្ស័យ ដែលអល់ឡោះស៊ុបហាណាហ៊ូវ៉ាតាអាឡា បានបង្កើតមកហើយនោះ ។

បញ្ជាទៅរ៉ស៊ូលុលឡោះ ដើម្បីអោយគាត់ជួយរំលឹកដាស់តឿនក្រុមរបស់គាត់ ដោយយកតាមគន្លងព្រះបន្ទូលរបស់អល់ឡោះ ។
គឺដោយហេតុមកអំពីរ៉ស៊ូលនោះ ជាម្នាក់ដែលគ្រាន់តែជួយក្តួលក្តីរំឭកតែប៉ុណ្ណោះ ហើយគាត់ពុំមែន មានបុគ្គលិកលក្ខណៈទៅលើសេចក្តីជំនឿជឿរបស់អ្នកទាំងអស់នោះទេ ។

الغاشية

វិបត្តិបរលោក

នឹងព្រះនាម អល់ឡោះ ម្ចាស់ប្រកបដោយមហា ករុណាទៀតប្រកបដោយមហា មេត្តាប្រណី	بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ
១. តើបានមកដល់ឯងហើយ ឬទេ ពត៌មានវិបត្តិបរលោកនោះ ។	١ هَلْ أَتٰىكَ حَدِيْثُ الْغٰشِيَةِ
២. បណ្ដាមុខទាំងឡាយនោះ នៅថ្ងៃនោះ អោនដោយការកោតខ្លាច ។	٢ وُجُوْهٌ يَّوْمَئِذٍ خٰشِعَةٌ
៣. ដែលបានធ្វើការបន្ទុកលើហត់នឿយនិងឯង. ព្រាកទេក ។	٣ عَامِلَةٌ نَّاصِبَةٌ
៤. វានឹងចូលទៅក្នុងឋាននរកដ៏មហាដែន ក្ដៅ ។	٤ تَصْلٰى نَارًا حَامِيَةً
៥. គេបានអោយផឹកអំពីរន្ធទឹកដ៏មហា ដែនក្ដៅ ។	٥ تُسْقٰى مِنْ عَيْنٍ اٰنِيَةٍ
៦. គ្មានចំណីអាហាររបស់ពួកវាទាំងអស់នោះ ជាដំណើ អាហារ ក្រៅតែដែលមានក្នុងបន្លា ។	٦ لَيْسَ لَهُمْ طَعَامٌ إِلَّا مِنْ ضَرِيْعٍ
៧. ដែលគ្មានផ្ដល់អោយធាត់ សាច់ឈាមហើយ ឃ្លាន	٧ لَّا يُسْمِنُ وَلَا يُغْنِيْ مِنْ جُوْعٍ

ហើយគ្មានបំបាត់បានទេ នូវការស្រេកឃ្លាន
នោះ ។

៨. បណ្ដាមុខទាំងអស់នោះ នៅថ្ងៃនោះ
សប្បាយរីករាយ ។ — وُجُوهٌ يَوْمَئِذٍ نَّاعِمَةٌ ٨

៩. ដោយសារការប្រឹងប្រែងរបស់វា ព្រោះ
សប្បាយចំពោះការប្រព្រឹត្ត ។ — لِّسَعْيِهَا رَاضِيَةٌ ٩

១០ ស្ថិតក្នុងឧទ្យានឋានសួគ៌ នៅក្នុងឋានសួគ៌ ដ៏មហា
ខ្ពង់ខ្ពស់ ។ — فِي جَنَّةٍ عَالِيَةٍ ١٠

១១. គេមិនឮពាក្យ នៅក្នុងវា (ឋានសួគ៌)
ពាក្យសំដីដែលគ្មានផលប្រយោជន៍ ។ — لَّا تَسْمَعُ فِيهَا لَاغِيَةً ١١

១២ នៅក្នុងវា (ឋានសួគ៌) មានប្រភពទឹកហូរ ។ — فِيهَا عَيْنٌ جَارِيَةٌ ١٢

១៣. នៅក្នុងវា (ឋានសួគ៌) មានគ្រែលម្អខ្ពស់ៗ បន្ទុំ
នឹងពូកខ្នើយតូចៗ ។ — فِيهَا سُرُرٌ مَّرْفُوعَةٌ ١٣

១៤. និងពែងទាំងឡាយ ដាក់ដែលគេរៀប
ដ៏ស្រស់ប្រណិត ។ — وَأَكْوَابٌ مَّوْضُوعَةٌ ١٤

១៥. ខ្នើយនិងពូកទាំងឡាយ ដែលគេតម្រៀប
ជាស្ទួនៗ — وَنَمَارِقُ مَصْفُوفَةٌ ١٥

១៦. ហើយនិងប៉ុន្មានកំរាលដែលគេក្រាលរា។ وَزَرَابِيُّ مَبْثُوثَةٌ 16

១៧. តើអ្នកទាំងអស់នោះពុំបានមើលមើល أَفَلَا يَنظُرُونَ إِلَى الْإِبِلِ 17
ដែរឬ? ទៅដំណោះសត្វអូដ្ឋ ដូចម្ដេចទៅ كَيْفَ خُلِقَتْ
ដែលគេបង្កើតវានោះ ។

១៨. ហើយទៅដំណោះមេឃ ដូចម្ដេចទៅ وَإِلَى السَّمَاءِ كَيْفَ رُفِعَتْ 18
ដែលគេកសាងឡើង ។

១៩. ហើយទៅដំណោះ បណ្ដាភ្នំដ៏ធំ ដូចម្ដេចទៅ وَإِلَى الْجِبَالِ كَيْفَ نُصِبَتْ 19
ដែលគេបាន ដោតភ្ជាប់នៅនឹងនឹងប៉ុង ។

២០. ហើយទៅដំណោះផែនដី ដូចម្ដេច وَإِلَى الْأَرْضِ كَيْفَ سُطِحَتْ 20
ទៅដែលគេលាតត្រដាងវានោះ ។

២១. ដើម្បីបាន ចូរអ្នកឯងរំឭកទៅចុះ فَذَكِّرْ إِنَّمَا أَنتَ مُذَكِّرٌ 21
ពិតប្រាកដ ឯងជាអ្នករំឭក

២២ អ្នកឯងគ្មានអំណាចត្រួតត្រា ទៅ لَّسْتَ عَلَيْهِم بِمُصَيْطِرٍ 22
លើអ្នកទាំងអស់នោះទេ

២៣ ក៏ប៉ុន្តែ អ្នកណាដែលបែរខ្នង (រំលោភ إِلَّا مَن تَوَلَّىٰ وَكَفَرَ 23
រំឭក) ហើយគ្មានជំនឿ

២៤ ដើម្បីបាន អល់ឡោះនឹងធ្វើទារុណកម្មវា فَيُعَذِّبُهُ اللَّهُ الْعَذَابَ الْأَكْبَرَ 24
នោះ ទារុណកម្ម ដ៏បរមាធ្ងន់ធ្ងរជាទីបំផុត

២៥. ពិតប្រាកដ ចំពោះយើងហើយ إِنَّ إِلَيْنَا إِيَابَهُمْ ២៥
អ្នកទាំងអស់នោះ ត្រូវវិលត្រឡប់ ។

២៦. បន្ទាប់មកពិតប្រាកដ លើយើងហើយ ثُمَّ إِنَّ عَلَيْنَا حِسَابَهُمْ ២៦
ដែលហៅអ្នកកាត់ទោស ជំនុំជំរះ អ្នកទាំងអស់នោះ ។

បិតកថាវគ្គ វគ្គនេះ ព្រះជាម្ចាស់បង្ហាញ អំពីដំណើរការណ៍ ផល យល់ឃើញ អំពីបណ្ដាអ្នកដែលគ្មានជំនឿ ហើយនិងបង្ហាញ អំពី ជោគជ័យនៃផ្លូវសុខ របស់បណ្ដាអ្នកដែលមានជំនឿជឿ នៅថ្ងៃបរលោក។

ម្ចាស់ដ៏មហាខ្ពង់ខ្ពស់ الأعلى

កប៉ិវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ឹកកាស់ ដែលមាន ១៩ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ التكوير ឈ្មោះ الأعلى មានន័យថា ម្ចាស់ដ៏មហាខ្ពង់ខ្ពស់

ដោយគេយកពាក្យសំដី الأعلى ដែលមាននៅក្នុងឃ្លាដំបូងបង្អស់នៃវគ្គនេះ ។

សហីហ៍មូស្លីម បាននិទានឡើងក្នុងគីតាប الجمعة

គេនិទានរ៉ាវីពី អ្នកដែលអនុវត្តតាមផ្លូវរបស់ សាវ័ក (ណាពី) សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ រ៉ាវីនូកម៉ានប៊ិនបាស៊ៀរ គាត់មានប្រសាសន៍ថា ក្នុងការគោរពសំពះថ្វាយបង្គំ (——— = صلاة) នៅថ្ងៃរ៉ាយ៉ាទាំងពីរ (الفطر និង الأضحى) និងថ្ងៃយ៉ូមអាត់ជុំមូអះ រ៉ស៊ូលុលឡោះ បានសូត្រវគ្គ الأعلى នៅក្នុងរ៉ក្អាត់ទី១. ហើយសូត្រវគ្គ الغاشية នៅក្នុងរ៉ក្អាត់ទី២ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

- បញ្ជារបស់អល់ឡោះ អោយសូត្រសិរីសាធរ និងរំឭកព្រះនាមរបស់ទ្រង់ ។
- សាវ័ក (ណាពី) មូហាំម៉ាត់ សុលឡលឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ប្រាកដជាមិនភ្លេចឡើយ នូវឃ្លាណានៃគួរអាន ដែលគេបានសូត្រនៅចំពោះគាត់ ។
- មាគ៌ាដែលនាំអោយមនុស្សលោក បានទទួលជោគជ័យបរិសុទ្ធដំរៃ នៅក្នុងលោកនិងបរលោក ។
- អល់ឡោះបានបង្កើត ហើយបានបំពេញគ្រប់លក្ខណៈក្នុងការបង្កើតរបស់ទ្រង់ ; ហើយកំណត់នូវការរីកចម្រើនរបស់ទ្រង់ ។
- ហើយបានដឹកនាំបង្ហាញ ទៀតបានបំពេញការចាំបាច់របស់មនុស្សលោក រហូតទាល់តែដល់នូវគោលបំណងរបស់វា (មនុស្សលោក) ។ ។

الاعلى

ម្ចាស់ដ៏មហាខ្ពង់ខ្ពស់

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា
សាធារណ៍ ទៀតដ៏មហា មេត្តាប្រណី ។

١ سَبِّحِ اسْمَ رَبِّكَ الْأَعْلَى

១. សំអាតចុះព្រះនាមម្ចាស់របស់ឯងដ៏មហា
ខ្ពង់ខ្ពស់ ។

٢ الَّذِي خَلَقَ فَسَوَّى

២ ទ្រង់បានបង្កើត ហើយទ្រង់បានបំពេញ
ស្វ័លក្ខណៈ (និងទាំងអស់ពិភពលោក)

٣ وَالَّذِي قَدَّرَ فَهَدَى

៣. ហើយទ្រង់ជាអ្នកដែលបានដាក់កំរិត ហើយ
និងបានចង្អុលបង្ហាញ ។

٤ وَالَّذِي أَخْرَجَ الْمَرْعَى

៤. ហើយទៀតទ្រង់ជាអ្នកបណ្ដុះរុក្ខជាតិ ។

٥ فَجَعَلَهُ غُثَاءً أَحْوَى

៥ ហើយទ្រង់បានធ្វើអោយរុក្ខជាតិនោះ
ក្លាយទៅជា ស្មៅស្ងួត ។

٦ سَنُقْرِئُكَ فَلَا تَنْسَى

៦ យើងនឹងឲ្យគេសូត្រអល់គួរអាន ចំពោះឯង ហើយ
បានជា កុំអោយឯងភ្លេច ។

٧ إِلَّا مَا شَاءَ اللَّهُ إِنَّهُ يَعْلَمُ الْجَهْرَ وَمَا يَخْفَى

៧. លើកលែងតែអ្វីដែលអល់ឡោះបានចង់ តែ-
ប៉ុណ្ណោះ ទ្រង់ជ្រាបនូវការចាស់ស្ទែង ហើយនិងរៀង

ដែលលាក់ជាទីពុំរាំង ។

៨. ហើយយើងនឹងសម្រួលអោយឯងទៅ
ចំពោះផ្លូវដែលងាយស្រួល ។ — وَنُيَسِّرُكَ لِلْيُسْرَىٰ 8

៩. ដូច្នេះ ចូរឯងរំឭកចុះ ពេលប្រការ
ការរំឭកនោះនឹង មានផលប្រយោជន៍ណាស់។ — فَذَكِّرْ إِن نَّفَعَتِ الذِّكْرَىٰ 9

១០. គេនឹងរំឭកខ្លួនគេ អ្នកដែលមានលក្ខណៈកោត
ខ្លាចគេ ។ — سَيَذَّكَّرُ مَن يَخْشَىٰ 10

១១. ហើយនឹងជៀសវាងវាពីវា(ការរំឭក) អ្នកដែល
ទុច្ចរិតគេនោះ ។ — وَيَتَجَنَّبُهَا الْأَشْقَى 11

១២. អ្នកនោះ ហើយនឹង ចូលក្នុងឋាននរកដ៏ធំបំផុត — الَّذِي يَصْلَى النَّارَ الْكُبْرَىٰ 12

១៣. បន្ទាប់មកទៀតនោះ គាត់ស្លាប់ក៏ទេ ហើយគ្មានរស់
ទេ ក្នុងវា (ឋាននរក) — ثُمَّ لَا يَمُوتُ فِيهَا وَلَا يَحْيَىٰ 13

១៤ ពិតប្រាកដ បានជោគជ័យហើយ អ្នកដែល
បានសំអាត (កាយនឹងចិត្តអំពីការល្មើសនឹងការ
ទុច្ចរិត) — قَدْ أَفْلَحَ مَن تَزَكَّىٰ 14

១៥. ហើយបានរំឭកព្រះនាមម្ចាស់របស់គាត់ ហើយ
ទៀតគាត់បាន គោរពសំពះថ្វាយបង្គំ (صلى)
(ចំពោះ អល់ឡោះម្ចាស់របស់គាត់) — وَذَكَرَ اسْمَ رَبِّهِ فَصَلَّىٰ 15

១៦ ក៏ប៉ុន្តែ ពួកឯងទាំងអស់គ្នា ស្រឡាញ់ការរស់ នៅក្នុងលោកិយនេះ ។ — بَلْ تُؤْثِرُونَ الْحَيَوٰةَ الدُّنْيَا ١٦

១៧. ការពិត ថ្ងៃបរលោកនោះហើយ ដែលល្អ មហាលើសលុប ទៀត ឋិតថេរជាងលោកិយ ។ — وَالْآخِرَةُ خَيْرٌ وَأَبْقَىٰ ١٧

១៨. ពិតប្រាកដ ពាក្យទាំងនេះ មាននៅក្នុងបណ្ដា គម្ពីរ ដែលពីមុនៗមក ។ — إِنَّ هَٰذَا لَفِي الصُّحُفِ الْأُولَىٰ ١٨

១៩. គឺគម្ពីររបស់ អ៊ីប្រាហ៊ីម ហើយនិងមូសា ។ — صُحُفِ إِبْرَاهِيمَ وَمُوسَىٰ ١٩

ចំពោះកជំពូក ខគម្ពីរនេះ បានបង្ហាញអោយឃើញ អំពីលក្ខណៈរបស់ មូស្លីម ហើយទៀតបានបញ្ជាក់ឲ្យ ឃើញលក្ខណៈរបស់ សារ:(ពាក្យ) មួយចំនួន ក្នុងគម្ពីរ ដែលមានមកពីមុនៗ ។
ហើយនិងបណ្ដាអ្នកដែលបានសំរេចដោយសេចក្ដីល្អ ក្នុងលោកិយ នៅថ្ងៃបរលោក ។

ផ្កាយដែលមានពន្លឺនាពេលរាត្រី الطارق

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ១៧ បន្ទូល ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ البلد
ឈ្មោះ الطارق មានន័យថា ផ្កាយដែលមានពន្លឺនាពេលរាត្រី
គេយកមកអំពីពាក្យសំដី الطارق នៅក្នុងបន្ទូលដំបូងបង្អស់នៃវគ្គនេះ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

អល់ឡោះបានដាក់ រក្សា ការពារ គ្រប់ព្រលឹង វិញ្ញាណ ។

សញ្ជឹងគិតដោយបានដឹងឥតឈប់ឈរចុះ អំពីដើមកំណើតកើតរបស់អ្នកឯង ។ អ្នកឯងនោះ គេបានបង្កើតអំពីដំណក់ទឹកកាម (ماء) របស់ជាតិប្រុសនិងស្ត្រីលាយឡំគ្នាតែប៉ុណ្ណោះទេ ដើម្បីអ្នកឯងគិតឃើញដើមកំណើតរបស់អ្នកឯងដូចម្តេះហើយ ព្រោះថាអ្នកឯងនិងបំបាត់នូវលក្ខណៈដែលធ្វើឫកពារធំ ហើយនិងអាកប្បកិរិយាក្អេងក្អាងនោះ ចោលចេញជាមិនខានឡើយ ។

អល់ឡោះមានឫទ្ធិអំណាចបង្កើតមនុស្សឡើងវិញ នៅថ្ងៃបរលោក ។
នៅពេលនោះហើយ គ្មានអំណាចអ្វីផ្សេងៗ ក្រៅពីអល់ឡោះជាម្ចាស់នោះ និងមកជួយមនុស្សលោកនេះបានឡើយ ។
អាល់គួរអាន (القرآن) ជាបន្ទូលដែលវែកញែករកយុត្តិធម៌ រវាងការពិតប្រាកដ ហើយនិងការលេងសើច ។

الطارق

ផ្កាយដែលមានពន្លឺនាពេលរាត្រី

និងព្រះនាម អល់ឡោះ ម្ចាស់ប្រណីមហា بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

សារសារណ៍ទៀតគ្រប់យ៉ាងពេញប្រណី ។

១. (អុលឡោះ) ទ្រង់ស្បថនឹងមេឃ ហើយនឹងផ្កាយ ។ — وَالسَّمَاءِ وَالطَّارِقِ ١

២. ហើយ តើអ្នកឯងបានដឹងដែរឬទេ រឿងទៅយ៉ាងណាថា ផ្កាយនោះ ? — وَمَا أَدْرَاكَ مَا الطَّارِقُ ٢

៣. គឺនោះ ផ្កាយ មានពន្លឺបញ្ចេញត្រចះត្រចង់ — النَّجْمُ الثَّاقِبُ ٣

៤. មិនមានទេ រាល់រស់ជីវិតនោះ លើកលែងតែ នៅលើវានោះ មានអ្នកត្រួតត្រា — إِنْ كُلُّ نَفْسٍ لَمَّا عَلَيْهَا حَافِظٌ ٤

៥. ដើម្បីបានជូនសញ្ញឹងគិតចុះ មនុស្សលោក កើតឡើងមកដែលសេចក្ដីអ្វី — فَلْيَنْظُرِ الْإِنْسَانُ مِمَّ خُلِقَ ٥

៦ គេបង្កើតវា កើតពីទឹក កាមតណ្ហាដែល បាញ់ចេញ (ចេញមកពីបុរស ហើយនិងស្ត្រី) — خُلِقَ مِنْ مَاءٍ دَافِقٍ ٦

៧. វាចេញមកពីរវាងឆ្អឹងខ្នងរបស់បុរស និងឆ្អឹងទ្រូងរបស់ស្ត្រី ។ — يَخْرُجُ مِنْ بَيْنِ الصُّلْبِ وَالتَّرَائِبِ ٧

៨. ពិតប្រាកដ (អុលឡោះ) ទ្រង់មានអំណាច បង្កើតគេឡើងវិញ (ក្រោយគេស្លាប់) — إِنَّهُ عَلَى رَجْعِهِ لَقَادِرٌ ٨

៩. នៅថ្ងៃនោះ គេបានបញ្ចេញទាំងរាល់
ការលាក់ចិត្តទាំង ។

يَوْمَ تُبْلَى السَّرَائِرُ 9

១០ ហើយពុំមានជា គ្មានទេ សំរាប់វា (មនុស្ស
លោក) នូវកំលាំង ហើយគ្មាននរណា
ម្នាក់ទៀតនឹងជួយវា ។

فَمَا لَهُ مِنْ قُوَّةٍ وَلَا نَاصِرٍ 10

១១. (សូមស្បថ) ខ្ញុំស្បថនឹងមេឃដែល
មានទឹកភ្លៀង ដែលវិលត្រឡប់មក
ជានិច្ច ។

وَالسَّمَاءِ ذَاتِ الرَّجْعِ 11

១២. ហើយនឹងផែនដីដែលមានប្រេះឡើង
ពោរពេញទៅដោយរុក្ខជាតិ ។

وَالْأَرْضِ ذَاتِ الصَّدْعِ 12

១៣ ពិតប្រាកដ គម្ពីរគួរអាន (القرآن) នោះ
ប្រាកដជាមាន ព្រះបន្ទូល ដែលធ្វើការញែក
ពាក្យសំដី (ការពិត ហើយនិងការខុស
ឆ្គង:) ។

إِنَّهُ لَقَوْلٌ فَصْلٌ 13

១៤. ហើយគ្មានទេ នៅក្នុងវា (គម្ពីរគួរអាន)
ការដែលកំប្លុកលេងសើច (ការនិយាយ
លេងសើច) ។

وَمَا هُوَ بِالْهَزْلِ 14

១៥. ពិតប្រាកដ ពួកទាំងអស់នោះ (ពួកគ្មាន
ជំនឿ) បានធ្វើឧបាយកល មិនល្អ ក៏ខ្លាំង
បំផុត ។

إِنَّهُمْ يَكِيدُونَ كَيْدًا 15

១៦ ហើយយើងវិញ (អល់ឡោះ) បានធ្វើឧបាយ កលដ៏ពិតប្រាកដដែលសមស្របលោកុសមគល وَأَكِيدُ كَيْدًا ١٦

១៧. ហេតុដូចនេះហើយ ចូរអ្នកកុំប្រញាប់ ប្រញាល់អ្វី ដល់ពួកបណ្ដា អ្នកគ្មានជំនឿ នោះ ។ ពន្យាពេលចុះ អ្នកទាំងអស់គ្នា នោះ: ឲ្យបន្តិចសិន فَمَهِّلِ الْكَافِرِينَ أَمْهِلْهُمْ رُوَيْدًا ١٧

បិតាកថាវគ្គ វគ្គនេះបានបញ្ជាក់ អំពីមនុស្សលោកគ្រប់រូប គឺនៅក្នុងការគ្រប់គ្រង របស់ អល់ឡោះជាម្ចាស់ ។

ដូចនោះដែរ អល់ឡោះ បានបង្កើតជាគ្រាដំបូង ហើយទៀត ទ្រង់បានបង្កើត ក្រោយទៀតពីពេលស្លាប់រួចមកហើយនោះ ។

- ការបញ្ជាក់ អំពី អាល់គួរអាន (القرآن)

អាល់គួរអាន (القرآن) បានស្លូរលោកអាត់ពាក្យដិត្តសារ: (ណាក្តី) មួយហាំងអ័រ សុលឡូលុវូហ៊ិកាដៃឡូអ៊ីអ៊ីស៊ាល់ល្ហាំ កុំអោយចាញ់កលល្បិច របស់ បណ្ដាអ្នកដែលគ្មានជំនឿក្នុងសាសនា ។

គន្លងផ្កាយ البروج

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ឹកកាស់ ដែលមាន២២បន្ទូល ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الشمس
ឈ្មោះ البروج មានន័យថា គន្លងផ្កាយ
គេយកមកអំពីពាក្យសំដី البروج ដែលមាននៅក្នុងបន្ទូលទីមួយ
បង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ឫកពា និងការអនុវត្តន៍ របស់បណ្ដាអ្នកគ្មានជំនឿទៅចំពោះ
បណ្ដាអ្នកដែលបានតាម ការអំពាវនាវ របស់ ប៉ុន្មានៗ សត្តការរងទុក្ខ
មកពី អល់ឡោះ (رسل) ។
ភស្តុតាងនានាក្នុងការគ្រប់គ្រងរបស់ អល់ឡោះ នោះ ដែលមួយគត់ ។
អំពីសញ្ញាហើយគ្រោះថ្នាក់របស់ អល់ឡោះថា បណ្ដាអ្នកដែល
គ្មានជំនឿនៅម៉ឹកកាស់នោះ គង់តែនឹងទទួល ទារុណកម្មទៅលើបណ្ដា
អ្នកទាំងនោះ ដូចដែលគេបានធ្វើទារុណកម្មទៅលើក្រុម ហ្វៀរ៉ូន
និងក្រុមសាមូដ ដូចនេះដែរ ។
អល់ឡោះ ទ្រង់បានដឹង រក្សា ការពារ និងលើកដំកើងដ៏ខ្ពង់ខ្ពស់
លើសាល់គួរអាន (القرآن) នេះជានិរន្តន៍រហូតទៅ ។

البروج

គន្លងផ្កាយ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា
សប្បុរសទៀតទ្រង់មហាមេត្តាប្រណី ។

១. (អល់ឡោះ) បានស្បថនឹងមេឃដែល មានកន្លែងផ្កាយ ។	وَالسَّمَاءِ ذَاتِ الْبُرُوجِ	١
២ ហើយនឹងថ្ងៃដែលបាន ចុះ កិច្ចសន្យា ។	وَالْيَوْمِ الْمَوْعُودِ	٢
៣. ហើយអ្នកដែលធ្វើសាក្សី និងអ្នកដែល ត្រូវគេធ្វើសាក្សី ។	وَشَاهِدٍ وَمَشْهُودٍ	٣
៤. គេបានធ្វើការសាបសូន្យទៅលើពួកដែលខ្ចប់ ក្រុង លើរណ្ដៅ ពាន់យោជន៍ ។	قُتِلَ أَصْحَابُ الْأُخْدُودِ	٤
៥. ភ្លើង ឆេះឡើង រលើសន្ធក់ ធូស ។	النَّارِ ذَاتِ الْوَقُودِ	٥
៦. ពេលនោះ ហើយ អ្នកទាំងអស់នោះបាន អង្គុយ ជុំវិញពីលើវា ។	إِذْ هُمْ عَلَيْهَا قُعُودٌ	٦
៧. ហើយអ្នកទាំងអស់នោះ បានធ្វើសាក្សី ទៅលើអ្វីដែលគេកំពុងតែធ្វើទៅចំពោះ អ្នកដែលមានជំនឿ ។	وَهُمْ عَلَىٰ مَا يَفْعَلُونَ بِالْمُؤْمِنِينَ شُهُودٌ	٧
៨. ហើយអ្នកទាំងអស់នោះ(អ្នកគ្មានជំនឿ) មិន មានគំនុំគុំគួនទេ ទៅលើអ្នកទាំងអស់នោះ (អ្នកដែលមានជំនឿ) លើកលែងតែ អ្នក ទាំងអស់នោះ មានជំនឿជឿ នឹងអល់ឡោះ ដែលមានមហាអំណាច ទៀតនិងមហា សរសើរ ។	وَمَا نَقَمُوا مِنْهُمْ إِلَّا أَنْ يُؤْمِنُوا بِاللَّهِ الْعَزِيزِ الْحَمِيدِ	٨

៩. ជំពោះទ្រង់ហើយជាសេចក្ដីគ្រប់គ្រង
ប៉ុន្មានមេឃ ហើយនិងផែនដី ទ្រង់
អល់ឡោះជាអ្នកធ្វើសាក្សីទៅលើទាំង
អស់វត្ថុនោះ ។

ٱلَّذِى لَهُۥ مُلْكُ ٱلسَّمَٰوَٰتِ وَٱلْأَرْضِ ۚ
وَٱللَّهُ عَلَىٰ كُلِّ شَىْءٍ شَهِيدٌ ٩

១០. ពិតប្រាកដ អ្នកដែលបានបង្កើតចលាចល
ចំពោះបណ្ដាប្រុសគោរព ហើយនិងបណ្ដាស្រី
គោរព ដែលមានជំនឿ (ចំពោះអល់ឡោះ) ក្រោ-
-យមកទៀតទាំងអស់នោះ គ្មានសុំអភ័យ
ទោសទេ ។ ដើម្បីសងនោះវិញ សំរាប់
អ្នកទាំងអស់គេ ទារុណកម្មក្នុងឋាន
នរកអវិជ្ជី. ។ ហើយសំរាប់អ្នកទាំង
អស់នោះ ទារុណកម្មនឹងក្ដៅមហាខ្លោចផ្សា

إِنَّ ٱلَّذِينَ فَتَنُوا۟ ٱلْمُؤْمِنِينَ ١٠
وَٱلْمُؤْمِنَٰتِ ثُمَّ لَمْ يَتُوبُوا۟
فَلَهُمْ عَذَابُ جَهَنَّمَ وَلَهُمْ
عَذَابُ ٱلْحَرِيقِ

១១. ពិតប្រាកដ អ្នកដែលមានជំនឿទាំងអស់
នោះ ហើយប្រព្រឹត្តការល្អ
ល្អៗ ។ សំរាប់អ្នកទាំងអស់នោះ
គឺបានឋានសួគ៌ ដែលហូរទៅពីក្រោមវា
នោះ ប៉ុន្មានទន្លេ នឹងនោះហើយ
ជ័យជំនះដ៏មហាធំបំផុត ។

إِنَّ ٱلَّذِينَ ءَامَنُوا۟ وَعَمِلُوا۟ 11
ٱلصَّٰلِحَٰتِ لَهُمْ جَنَّٰتٌ تَجْرِى
مِن تَحْتِهَا ٱلْأَنْهَٰرُ ۚ ذَٰلِكَ
ٱلْفَوْزُ ٱلْكَبِيرُ

១២. ពិតប្រាកដ ទារុណកម្មរបស់ម្ចាស់អ្នកនោះ
ដ៏មហាខ្លាំងក្លៃ ។

إِنَّ بَطْشَ رَبِّكَ لَشَدِيدٌ 12

១៣. ពិតប្រាកដ ទ្រង់នោះហើយ អ្នកដែលបង្កើត
ហើយដែលបង្វិលត្រឡប់ ។

إِنَّهُۥ هُوَ يُبْدِئُ وَيُعِيدُ 13

១៤ ហើយទ្រង់ ជាអ្នកអភ័យទោសនិង ជាអ្នកស្រឡាញ់ ។	١٤ وهو الغفور الودود
១៥ អ្នកដែលគ្រប់គ្រងអារ៉ស ដ៏មហាថ្កុំថ្កើង ។	١٥ ذو العرش المجيد
១៦ អ្នកដែលមានមហាអំណាច ធ្វើអ្វីៗ តាមដែលទ្រង់ចង់ ។	١٦ فعال لما يريد
១៧ តើបានមកដល់ឯងនូវដំណឹង ពលទាហាន ពីពួកកងទ័ព ។	١٧ هل أتاك حديث الجنود
១៨ ក្រុមហ្វៀរអូន ហើយនិងស៊ើមូដ ។	١٨ فرعون وثمود
១៩ ក៏ប៉ុន្តែ ពួកអ្នកដែលគ្មានជំនឿនោះ តែងតែបដិសេធ នៅក្នុងការភូតកុហក ។	١٩ بل الذين كفروا في تكذيب
២០ ហើយអល់ឡោះ បានឡោមព័ទ្ធពីក្រោយ ពួកគេ អ្នកទាំងអស់នោះ ។	٢٠ والله من ورائهم محيط
២១ តែគម្ពីរនេះ គឺគម្ពីរកុរអាន (قرآن) ដ៏មហាថ្កុំថ្កើង ។	٢١ بل هو قرآن مجيد
២២ នៅក្នុងក្តារខៀន (ល្វូហ៍មើលហ្វូស)ដែលបានរក្សាការពារ ។	٢٢ في لوح محفوظ

ចិតកបាទីគ្គា វគ្គនេះបានធ្ងន់បញ្ជាក់ សំដៅព្រឹកព្រោ របស់អ្នកដែលគ្មាន

ជំនឿ ជឿតក្លាប់បានប្រព្រឹត្ត ទៅលើបណ្ដាអ្នកដែលតាមការ រំពារំពៃរបស់
រ៉សូល ។ ហើយនឹងបញ្ជាក់ រំលឹកគ្រឿងដែលបណ្ដាអ្នកដែលធ្វើស្លូតត្រង់មនា

ញាណយកអុលឡោះ បានអោយកាសញ្ញា នៅលើការលោតដំបងដៃនឹង
សុខដុមរម្យតា របស់បណ្ដាអ្នកមានជំនឿ ហើយនឹងការធ្វើពារការកម្ម ទៅលើ
បណ្ដាអ្នកដែលគ្មានជំនឿនោះ ដើម្បីនឹងល្អងលោង សាវ៉ះ(ណាត្បី) នឹង
សត្តុកគ្គី ហើយនឹងអ្នកដែលតាម រ៉ស៊ូលុលឡោះ ក្នុងការរួបរួមដៃ ទំពៅលោ
លោតរបស់បណ្ដា មូសលីម នៅឯប៉ិកកាស់នោះ ។

ការបាក់បែក الانشقاق

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ុកកាស់ ដែលមាន ២៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الانفطار
ឈ្មោះ الانشقاق មានន័យថា ការបាក់បែក
គេយកមកអំពីពាក្យសំដី انشقت ដែលមាននៅក្នុងឃ្លាដំបូងបង្អស់
នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ពត៌មាននានា ដែលភ្ជាប់មានទៀង នៅថ្ងៃនោះ កាល ។
ការពិត ពិតប្រាកដ មនុស្សយើងប្រឹងប្រែងតែងតែមានទុក្ខ សោក
លំបាក វេទនា ដើម្បីធ្វើដំណើរទៅជួប ម្ចាស់របស់គេនោះ។
ការជួបគាល់ម្ចាស់របស់គេនេះឯង ប្រាកដជាពិតជានឹងជួបមិនខានឡើយ។

- មានអ្នកខ្លះក៏បានទទួលជ័យជំនះ ខ្លះទៀតក៏ទទួលការលំបាកវេទនា
ពីមួយថ្នាក់ទៅមួយថ្នាក់ ក្នុងការបង្កើត ហើយនឹងការរស់នៅក្នុង
លោក ហើយនិងនៅថ្ងៃបរលោក ។

الانشقاق

ការបាក់បែក

بِسْمِ اللّٰهِ الرَّحْمَـٰنِ الرَّحِيْمِ

នឹងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា
សាណាណាស់ទៀតទ្រង់មហា មេត្តាប្រណី ។

١ إِذَا السَّمَاءُ انْشَقَّتْ

១. ពេលណាមេឃបានបាក់បែក

២. ហើយវាបានយល់ព្រមចំពោះម្ចាស់របស់វា ហើយគេបានសន្និញ្ញាតិចំពោះវា ។ وَأَذِنَتْ لِرَبِّهَا وَحُقَّتْ ٢

៣. ហើយពេលណាដែនដី គេត្រូវបានលាតត្រដាង ។ وَإِذَا الْأَرْضُ مُدَّتْ ٣

៤ ហើយវាបានក្រវាត់ក្រឡាប់ចេញ អ្វីៗដែលនៅក្នុងវា ហើយវាបានរុះស្រឡះរលីង ។ وَأَلْقَتْ مَا فِيهَا وَتَخَلَّتْ ٤

៥. ហើយវាបានយល់ព្រមទៅចំពោះម្ចាស់របស់វា ហើយគេបានសន្និញ្ញាតិចំពោះវា وَأَذِنَتْ لِرَبِّهَا وَحُقَّتْ ٥

៦. ឱ មនុស្សលោកអើយ ពិតប្រាកដណាស់ អ្នកពិតជាប្រឹងប្រែងប្រកបកិច្ចការ ទៅចំពោះម្ចាស់អ្នក គឺចុកការនីពិតប្រាកដ ដើម្បីបានជា អ្នកនឹងតែនឹងជួបលទ្ធផល របស់អ្នក ។ يَا أَيُّهَا الْإِنْسَانُ إِنَّكَ كَادِحٌ إِلَىٰ رَبِّكَ كَدْحًا فَمُلَاقِيهِ ٦

៧. ហើយរីឯចំពោះ អ្នកណាដែលគេបានអោយ បញ្ជីកិច្ចប្រតិបត្តិពីស្តាំអោយដល់គេ فَأَمَّا مَنْ أُوتِيَ كِتَابَهُ بِيَمِينِهِ ٧

៨. ដើម្បីបានជា អ្នកនោះគេនឹងជំនុំជម្រះ គឺជំនុំជម្រះ ដោយការងាយស្រួល ។ فَسَوْفَ يُحَاسَبُ حِسَابًا يَسِيرًا ٨

៩. ហើយគេនឹងវិលត្រឡប់ទៅចំពោះក្រុមគ្រួសារ
របស់គេ ដោយសប្បាយរីករាយ ។

وَيَنقَلِبُ إِلَىٰٓ أَهْلِهِۦ مَسْرُورًا ٩

១០ ហើយរីឯជនណាដែល បញ្ជីកំណត់ត្រាដែល
គេហុចឲ្យ ពីខាង(បណ្ដោយដៃឆ្វេងប្រមាត់) គេ ពី
ក្រោយខ្នងគេ ។

وَأَمَّا مَنْ أُوتِيَ كِتَٰبَهُۥ وَرَآءَ ظَهْرِهِۦ ١٠

១១ ពេលនោះ គេនឹងស្រែកហៅ
នូវការវិនាសអន្តរាយ ។

فَسَوْفَ يَدْعُوا۟ ثُبُورًا ١١

១២. ហើយគេនឹងចូលក្នុងភ្លើងដែលកំពុង
ឆេះឆាបឆេះ ។

وَيَصْلَىٰ سَعِيرًا ١٢

១៣. ពិតប្រាកដ កាលដែលគេរស់នៅ(ក្នុងលោកិយ)
ក្នុងក្រុមគ្រួសាររបស់គេ ដោយការសប្បាយរីក
រាយ ។

إِنَّهُۥ كَانَ فِىٓ أَهْلِهِۦ مَسْرُورًا ١٣

១៤. ពិតប្រាកដ គេបានស្មានថា គេនឹង
មិនវិលត្រឡប់ទេ (ទៅចំពោះអល់ឡោះ
ក្រោយពីគេស្លាប់) ។

إِنَّهُۥ ظَنَّ أَن لَّن يَحُورَ ١٤

១៥. ពិតមែនហើយ ពិតប្រាកដ ម្ចាស់របស់
គេបានឃើញច្បាស់បំផុតនូវ ។

بَلَىٰٓ إِنَّ رَبَّهُۥ كَانَ بِهِۦ بَصِيرًا ١٥

១៦. ទើបពិតប្រាកដ អញបានស្បថនឹងពន្លឺ
ក្រហមព្រលប់ចូលពេលល្ងាច ។

فَلَآ أُقْسِمُ بِٱلشَّفَقِ ١٦

១៧. ហើយ (អល់ឡោះ) បានស្បថនឹងពេល
រាត្រី ហើយនិងវត្ថុនានា ទាំងឡាយ ដែលបាន
ប្រមូលផ្តុំ ។

١٧ وَالَّيْلِ وَمَا وَسَقَ

១៨. ហើយ (អល់ឡោះ) បានស្បថនឹងព្រះចន្ទ
ពេលណាវា បានពេញពន្លឺ បូរមី

١٨ وَالْقَمَرِ إِذَا اتَّسَقَ

១៩. ពិតប្រាកដ ពួកឯងនឹងតាំងសភាពនឹងជីវិត
ប្រទាល ឡើងពីមួយជាន់ទៅមួយជាន់
(ក្នុងការរស់នៅ)

١٩ لَتَرْكَبُنَّ طَبَقًا عَن طَبَقٍ

២០ តើហេតុដែលនាំឲ្យពួកគេទាំងអស់នោះ
គ្មានជំនឿ ជឿអ្វីក៏ ។

٢٠ فَمَا لَهُمْ لَا يُؤْمِنُونَ

២១. ហើយនៅពេលណាគេសូត្រគម្ពីរ ទៅលើ
ពួកគេទាំងអស់ គម្ពីរគួរអាន (القرآن) ពួកគេទាំង
អស់នោះ គ្មានគោរពក្រាបសុជូតនោះទេ

٢١ وَإِذَا قُرِئَ عَلَيْهِمُ الْقُرْآنُ
لَا يَسْجُدُونَ

២២. ផ្ទុយទៅវិញ ពួកដែលគ្មានជំនឿ ទាំង
អស់នោះ គឺពួកគេតែងតែ កុហក

٢٢ بَلِ الَّذِينَ كَفَرُوا يُكَذِّبُونَ

២៣. ហើយតាមការពិត អល់ឡោះ ជាអ្នក
ដឹងនឹងដឹងច្បាស់ ក្នុងចិត្តពួកគេទាំងអស់
នោះ គិតលាក់កំបាំង

٢٣ وَاللَّهُ أَعْلَمُ بِمَا يُوعُونَ

២៤ ដូចបានជា ចូរឯង (ផ្សាយអាក្រក់) ផ្តល់ចុះ

٢٤ فَبَشِّرْهُم بِعَذَابٍ أَلِيمٍ

ដាក់មារ សប្បាយរីករាយ សំរាប់អ្នកទាំងអស់
របស់គេ នឹងទារុណកម្មដ៏ឈឺចាប់ ។

២៥ លើកលែងតែ បណ្តាអ្នកដែលមានជំនឿ
ជឿស៊ប់ ហើយបានអនុវត្តទាំងអស់នោះ
តាមរបៀបសច្ចភាព ដ៏ល្អប្រសើរ សំរាប់
អ្នកទាំងនោះហើយ ដែលបុណ្យគ្មានពេល
ដាច់ឡើយ ។

إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ لَهُمْ أَجْرٌ غَيْرُ مَمْنُونٍ ٢٥

[illegible]. ខគម្ពីរនេះ បានបញ្ជាក់ អំពីកំណើតនៃគោលដីឡូវប្រព្រឹត្ត ថ្ងៃ
[illegible] នេះកាល (قيامة) ។
ដូចម្តេចនឹង ការគាបសង្កត់សម្រេចរបស់ រំលោភ សុចរិត និងអំពើ
នូវក្រឹត្យគេនោះ ។ ហើយបរលោកដ៏អាក្រក់មានថ្ងៃ នេះកាល ។
ថ្ងៃនេះកាលនេះប្រាកដជាដាច់ខាតជាមានពិត ។ ចំណែកឯ
អ្នកដែលគ្មានជំនឿក្នុងសាសនា ក្រឡប់ទៅជាថា គ្មានថ្ងៃនោះកាល
(قيامة) នោះទេ ។

អ្នកកេងប្រវ័ញ្ច المطففين

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣៦ បន្ទាត់ គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ العنكبوت ។

ឈ្មោះ المطففين មានន័យថា អ្នកកេងប្រវ័ញ្ច គេយកមកពីពាក្យសំដី المطففين ដែលមាននៅក្នុងបន្ទាត់ទីមួយបង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

អល់ឡោះ បានប្រទេចខ្លាំងណាស់ ទៅចំពោះអ្នកដែលកេងប្រវ័ញ្ច ក្នុងការថ្លឹង ទៀតការវាស់ហើយនិងការវាល់ ។

គេបានដាក់ទុក ការអាក្រក់របស់មនុស្សលោក ដែលគេបានប្រមូលទុកក្នុងស៊ិជជីន (سجين) នៅបញ្ជីអាក្រក់ ។

ផ្ទុយទៅវិញ គេបានដាក់ទុកអំពើល្អបរិសុទ្ធរបស់មនុស្សលោក ដែលគេប្រមូលដាក់ទុកក្នុង អ៊ិលលីយីន (عليين) នៅបញ្ជីល្អ ។

ការតបស្នងវិញដ៏ល្អយ៉ាងគ្រប់បែបប្រភេទយ៉ាង ចំពោះបណ្ដាអ្នកដែលបានប្រព្រឹត្តអំពើល្អ ។

ការចំអកហើយនិងការសើចលេងហើយសើចដៀករបស់បណ្ដាអ្នកដែលគ្មានជំនឿលើសាសនាក្នុងលោក នៅចំពោះបណ្ដាអ្នកដែលមានជំនឿជឿជាក់ក្នុងសាសនា ។

ការចំអកឡកឡឺយរបស់បណ្ដាអ្នកមានជំនឿក្នុងសាសនា នៅថ្ងៃបរលោក ទៅចំពោះបណ្ដាអ្នកដែលគ្មានជំនឿក្នុងសាសនានោះវិញ ។

المطففين

[illegible]

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា
សប្បុរស ទៀតដ៏មហាមេត្តាករុណា

١ وَيْلٌ لِّلْمُطَفِّفِيْنَ

១. វិនាសអន្តរាយហើយសំរាប់អ្នកបោកបញ្ឆោត

٢ الَّذِيْنَ إِذَا اكْتَالُوْا عَلَى
النَّاسِ يَسْتَوْفُوْنَ

២ បណ្ដាអ្នកនោះ ពេលណាវា វាល់យកពី
មនុស្សលោក វាទាំងអស់នោះ ចង់បានគ្រប់

٣ وَإِذَا كَالُوْهُمْ أَوْ وَّزَنُوْهُمْ
يُخْسِرُوْنَ

៣. ហើយពេលណាអ្នកទាំងអស់នោះ បានវាល់
ទៅអោយគេ ឬមួយបានថ្លឹងទៅអោយគេ
វិញ អ្នកទាំងអស់នោះ បានធ្វើអោយខូច
(ក្នុងការវាល់និងថ្លឹង)

٤ أَلَا يَظُنُّ أُولٰٓئِكَ أَنَّهُمْ مَّبْعُوْثُوْنَ

៤. តើ ពុំមែនគេទេឬ? អ្នកទាំងអស់នោះ គ្នា
សង្ឃឹមពិត ពិតប្រាកដ អ្នកទាំងអស់នោះ គេ
នឹងបង្កើតឡើងវិញ

٥ لِيَوْمٍ عَظِيْمٍ

៥. នៅថ្ងៃដ៏មហាធំ

٦ يَوْمَ يَقُوْمُ النَّاسُ لِرَبِّ الْعٰلَمِيْنَ

៦. គឺថ្ងៃ ដែលមនុស្សលោកក្រោកឈរ ១
ឆ្ពោះទៅរកម្ចាស់ ពិភពលោក ។

٧ كَلَّآ إِنَّ كِتٰبَ الْفُجَّارِ لَفِيْ سِجِّيْنٍ

៧. កុំធ្វើដូចនោះឡើយ ពិតប្រាកដ បញ្ជីអ្នក
ទាំងអស់ ដែលបានប្រព្រឹត្តអំពើទុច្ចរិតនោះ

ពិតជាមាននៅក្នុង ស៊ិជជីន (سجين)

៨ ហើយអ្នកដឹងដឹងដែរឬទេ? ថាអ្វីទៅ ស៊ិជជីន (سجين) នោះ | وَمَا أَدْرَٰكَ مَا سِجِّينٌ 8

៩. វាគឺជាបញ្ជីដែលគេបានចារទុក | كِتَٰبٌ مَّرْقُومٌ 9

១០ វិនាសអន្តរាយហើយ នៅថ្ងៃនោះ ចំពោះអ្នកទាំងអស់ ដែលភូតភរ | وَيْلٌ يَوْمَئِذٍ لِّلْمُكَذِّبِينَ 10

១១ បណ្ដាអ្នកដែលភូតភរនឹងថ្ងៃតបស្នង | الَّذِينَ يُكَذِّبُونَ بِيَوْمِ الدِّينِ 11

១២. ហើយគ្មានភូតភរនឹងវាទេ លើកលែង តែពួកបណ្ដាអ្នកដែលបំពានច្បាប់ហើយ ទុច្ចរិតទៀត | وَمَا يُكَذِّبُ بِهِۦٓ إِلَّا كُلُّ مُعْتَدٍ أَثِيمٍ 12

១៣. ពេលណាគេបានសូត្រហើយទៅ លើវា នូវ ប៉ុន្មានអាយ៉ាត់ (آيات) របស់ អល់ឡោះ វាបាននោលថា នេះគឺរឿង ព្រេងរបស់មនុស្សជំនាន់ដើម ដែលគេប្រាប់តៗគ្នាទេ | إِذَا تُتْلَىٰ عَلَيْهِ ءَايَٰتُنَا قَالَ أَسَٰطِيرُ الْأَوَّلِينَ 13

១៤ មិនមែនដូច្នោះទេ ពិតប្រាកដ ទ្រង់បានបិទបាំង ក្របដណ្ដប់ ហើយនៅលើចិត្តអ្នកទាំងអស់ នោះ សាហេតុទុច្ចរិតដែលពួកទាំងអស់នោះ បានប្រព្រឹត្តរួចមកហើយ ॥ | كَلَّا بَلْ رَانَ عَلَىٰ قُلُوبِهِم مَّا كَانُوا يَكْسِبُونَ 14

១៥. កុំជឿដូចនោះឡើយ ពិតប្រាកដ អ្នកទាំងអស់
នោះ នៅថ្ងៃនោះ ច្បាស់ជា អ្នកទាំងអស់
នោះ ត្រូវគេបាំងមិនឲ្យ ឃើញម្ចាស់របស់គេ ។

كَلَّا إِنَّهُمْ عَن رَّبِّهِمْ يَوْمَئِذٍ لَّمَحْجُوبُونَ 15

១៦ បន្ទាប់មក ពិតប្រាកដ អ្នកទាំងអស់នោះ
ច្បាស់ជា ចូលទៅក្នុង ឋាននរក អាល់ជាហ៊ីម
(الجحيم) ។

ثُمَّ إِنَّهُمْ لَصَالُوا الْجَحِيمِ 16

១៧. បន្ទាប់មកគេប្រកាសថា គឺនេះហើយ
កាលពីមុន អ្នកឯងទាំងអស់គ្នា គេះបានកុ
កុហកពីវា (ឋាននរក)

ثُمَّ يُقَالُ هَٰذَا الَّذِي كُنتُم بِهِ تُكَذِّبُونَ 17

១៨. ពុំមែនដូចនេះទេ ពិតប្រាកដបញ្ជី
អ្នកទាំងអស់ដែលបានប្រព្រឹត្ត អំពើល្អទាំង
នោះ ពិតជាបាន ដាក់នៅក្នុង អ៊ីលលី
យីន (កន្លែងដ៏ខ្ពង់ខ្ពស់)

كَلَّا إِنَّ كِتَابَ الْأَبْرَارِ لَفِي عِلِّيِّينَ 18

១៩. តើអ្នកឯងបានដឹងដែរឬទេ? អ្វីទៅ
អ៊ីលលីយូន (عليون) នោះ ?

وَمَا أَدْرَاكَ مَا عِلِّيُّونَ 19

២០ បញ្ជី ដែលគេបានចារទុក

كِتَابٌ مَّرْقُومٌ 20

២១. បានធ្វើសាក្សីហើយដោយពួកទេវតា
([illegible]) ដែលនៅជិត (ជំពោះអល់
ឡោះ) ។

يَشْهَدُهُ الْمُقَرَّبُونَ 21

២២. ពិតប្រាកដ អ្នកដែលប្រព្រឹត្តអំពើ
ល្អទាំង ប្រាកដជាបានចូលទៅក្នុងឋានសួគ៌
ណាអ៊ីម (نعيم)

إِنَّ الْأَبْرَارَ لَفِي نَعِيمٍ 22

២៣. អ្នកទាំងអស់នោះអង្គុយលើគ្រែលំអៀង
ណាណា ក៏ក្រឡេកមើលទៅ

عَلَى الْأَرَائِكِ يَنْظُرُونَ 23

២៤ ឯងនឹងឃើញ នៅលើមុខ អ្នកទាំងអស់
នោះស្រស់ ស្រស់ស្រាយ ពោរពេញទៅ
ដោយសេចក្ដីសប្បាយរីករាយ

تَعْرِفُ فِي وُجُوهِهِمْ نَضْرَةَ النَّعِيمِ 24

២៥ គេ ដោយឲ្យអ្នកទាំងអស់នោះផឹកទឹកស្រា
ដ៏បរិសុទ្ធ

يُسْقَوْنَ مِنْ رَحِيقٍ مَخْتُومٍ 25

២៦. បរិសុទ្ធ វានោះ មានខ្លឹមក្លិនប្រៀបធៀបស្មើ
ដូចជាទឹកអប់ មិស្ក (مسك) ហើយនៅក្នុង
ការនេះនោះ ចើបភាពជា ត្រូវ
ណាស់ប្រកួតប្រជែង អ្នកទាំងអស់ដែលបាន
ប្រណាំងប្រជែងនោះ។

خِتَامُهُ مِسْكٌ وَفِي ذَٰلِكَ فَلْيَتَنَافَسِ الْمُتَنَافِسُونَ 26

២៧. ហើយលាយទៅដោយទឹកស្រានោះមកពី
ទេសនីម (تسنيم)

وَمِزَاجُهُ مِنْ تَسْنِيمٍ 27

២៨. គឺប្រភពទឹកដែលផឹក អំពីវា មនុស្ស
ដែលនៅជិត(ទ្រង់នោះ គឺអល់ឡោះ)

عَيْنًا يَشْرَبُ بِهَا الْمُقَرَّبُونَ 28

២៩. ពិតប្រាកដទាំងអស់អ្នកដែលបានប្រព្រឹត្ត
អំពើទុច្ចរិត កាលពីមុនមក អ្នកទាំង
អស់នោះបានសើចចំអកឡកឡឺយ ចំពោះ
អ្នកដែលមានជំនឿទាំងអស់ ។

إِنَّ الَّذِينَ أَجْرَمُوا كَانُوا ٢٩
مِنَ الَّذِينَ آمَنُوا يَضْحَكُونَ

៣០- ហើយពេលណាបានដើរកាត់ (អ្នកមូមីន)
ពីមុខអ្នកទាំងអស់នោះ អ្នកទាំងនោះ
បានពេបជ្រាយរអោយ ។

وَإِذَا مَرُّوا بِهِمْ يَتَغَامَزُونَ ٣٠

៣១. ហើយពេលណាអ្នកទាំងអស់បានវិល
ត្រឡប់ទៅរកគ្រួសាររបស់គេនោះ
អ្នកទាំងនោះ បានវិលត្រឡប់ទៅដោយក្តី
សប្បាយរីករាយ ។

وَإِذَا انْقَلَبُوا إِلَىٰ أَهْلِهِمُ ٣١
انْقَلَبُوا فَكِهِينَ

៣២ ហើយពេលណាអ្នកទាំងអស់នោះបាន
ឃើញបណ្តាអ្នកដែល (មូមីន) អ្នកទាំងនោះ
ពោលថា ពិតប្រាកដ អ្នក ទាំងអស់នេះ
ពិតជាវង្វេង ។

وَإِذَا رَأَوْهُمْ قَالُوا إِنَّ هَٰؤُلَاءِ ٣٢
لَضَالُّونَ

៣៣. ដែលអ្វីនោះ គេបានបញ្ជូនទេ អ្នកទាំង
អស់. (អ្នកគ្មានជំនឿ) សំរាប់ពិនិត្យមើល
លើអ្នកទាំងអស់នោះ (អ្នកមូមីន) ។

وَمَا أُرْسِلُوا عَلَيْهِمْ حَافِظِينَ ٣٣

៣៤ ដូច្នេះបានជា នៅថ្ងៃនោះ បណ្តាអ្នកមាន
ជំនឿ បានសើចចំអកឡកឡឺយ ទៅចំពោះ
បណ្តាអ្នកដែលគ្មានជំនឿ (الكفار) ។

فَالْيَوْمَ الَّذِينَ آمَنُوا مِنَ الْكُفَّارِ ٣٤
يَضْحَكُونَ

៣៥. អ្នកទាំងអស់នោះ អង្គុយនៅលើពោធិ៍ អាសនា ក៏ក្រឡេកមើលមក — عَلَى ٱلْأَرَآئِكِ يَنظُرُونَ ٣٥

៣៦. តើគេបានតបស្នងទៅលើបណ្ដាអ្នកគ្មាន ជំនឿដែរឬទេ? អ្វីៗដែលអ្នកទាំងអស់ នោះ បានប្រព្រឹត្តរួចមកហើយ ។ — هَلْ ثُوِّبَ ٱلْكُفَّارُ مَا كَانُوا۟ يَفْعَلُونَ ٣٦

បរិកថាវត្ថុ វគ្គនេះបានបង្ហាញប្រយោជន៍ បញ្ជាក់ទៅការតបស្នងដ៏សោះ ទៅចំពោះបណ្ដាអ្នកដែលគ្មានជំនឿក្នុងលោកសា ហើយនិងបណ្ដាអ្នក ដែលបានប្រព្រឹត្ត អំពើទុច្ចរិតក្នុងការលោកិយនេះ ព្រោះអល់ឡោះ ក៏បាន បញ្ជាក់ អំពីកិច្ចសន្យា របស់ អល់ឡោះ ក្នុងការតបតនឹងល្អ ដោយឡែក ចំពោះបណ្ដាអ្នកដែលមានជំនឿ ធ្វើការប្រព្រឹត្តហើយនូវអំពើល្អ និង ស្មោះស ។

ការបែកខ្ទេក الانفطار

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កា ដែលមាន ១៩ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ النازعات ឈ្មោះ الانفطار គេបានដាក់ចំណងជើងនៅក្នុងវគ្គនេះ ដោយសារមានពាក្យកើតឡើងដំបូង انفطرت ដែលមាននៅក្នុងឃ្លាទីមួយបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

- ពត៌មាន ដែលកើតមានឡើង នៅក្នុងថ្ងៃបរលោក ។
- សេចក្តីរំឭកទៅចំពោះមនុស្សលោក ដើម្បីកុំភ្លេចយកចិត្តទុកដាក់ក្នុងការបោកបញ្ឆោតរបស់គេ របៀបទាល់តែខ្លួនអ្នកឯងក្លាយទៅជាអ្នកអកតញ្ញូប្រឆាំងនឹងអល់ឡោះជាម្ចាស់របស់ឯង ព្រោះបណ្តាទេវៈ (ملئكة) ដែលនៅជាប់ជាមួយប្រចាំការថ្ងៃ និងយប់ ការពារនិងកត់ត្រានូវកិច្ចការរបស់មនុស្សលោក ដែលបានប្រព្រឹត្ត ។

នៅថ្ងៃនោះកាល មនុស្សលោកគ្មានសមត្ថភាពអ្វី ១ ជួយសង្គ្រោះទៅចំពោះអ្នកដទៃណាឯទៀតបានឡើយ ។ មានតែឫទ្ធានុភាពរបស់អល់ឡោះជាម្ចាស់ប៉ុណ្ណោះ ដែលអាចជួយគេបានគ្រប់បែបគ្រប់យ៉ាង ។

الانفطار
ការបែកខ្ទេក

នឹងព្រះនាមអល់ឡោះម្ចាស់ដ៏មហាសាធារណ៍ទៀតទាំងមហាមេត្តាប្រណី ។ | بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

ពេលណាមេឃបានបែកខ្ទេក | ١ إِذَا السَّمَاءُ انْفَطَرَتْ

2 وَإِذَا ٱلْكَوَاكِبُ ٱنتَثَرَتْ

២ ហើយបណ្ដាផ្កាយទាំងឡាយធ្លាក់ខ្ចាត់
ខ្ចាយ

3 وَإِذَا ٱلْبِحَارُ فُجِّرَتْ

៣. ហើយពេលណាបណ្ដាសមុទ្រទាំងអស់ ហូរ
បានធ្វើហោយ បានកខ្ចោលលាយឡំ

4 وَإِذَا ٱلْقُبُورُ بُعْثِرَتْ

៤. ហើយពេលណាផ្នូរទាំងអស់គេបានបើះ
ឡើង

5 عَلِمَتْ نَفْسٌ مَّا قَدَّمَتْ وَأَخَّرَتْ

៥. បានដឹងហើយរាល់ៗបណ្ដាជីវិតទាំងឡាយ
ពីអ្វីដែលវាបានធ្វើរួចមកហើយ
ហើយអ្វីដែលវាបានធ្វេសប្រហែស

6 يَٰٓأَيُّهَا ٱلْإِنسَٰنُ مَا غَرَّكَ بِرَبِّكَ ٱلْكَرِيمِ

៦. ឱ! មនុស្សលោកអើយ អ្វីទៅដែលវាបាន
បោកបញ្ឆោតឯង (ទាស់ចិត្តឯងតាមរឿង)
និងម្ចាស់របស់ឯង ដ៏មហាឧត្ដម

7 ٱلَّذِى خَلَقَكَ فَسَوَّىٰكَ فَعَدَلَكَ

៧. ទ្រង់បានបង្កើតឯង ហើយទ្រង់បានបំពេ
-ញលក្ខណៈឯង ហើយទៀតទ្រង់បានពង្រឹង
រាងរលឹងយ៉ាងសមរម្យ

8 فِىٓ أَىِّ صُورَةٍ مَّا شَآءَ رَكَّبَكَ

៨. នៅក្នុងសភាពរូបកាយបែបណា
ក៏ដោយ តាមតែទ្រង់ចង់ ទ្រង់ក៏បាន
រៀបចំរូបឯង

9 كَلَّا بَلْ تُكَذِّبُونَ بِٱلدِّينِ

៩. មិនមែនទេ ព្រោះតែផ្ទុយលោះលេ ក្ដួយទៅវិញ

អ្នកទាំងអស់គ្នានោះ ភូតភរកុហក នឹង
ថ្ងៃជំនុំជំរះ ។

១០ ហើយពិតប្រាកដ លើអ្នកទាំងអស់គ្នា
ពិតជាមាន អ្នកពិនិត្យមើល ។

وَإِنَّ عَلَيْكُمْ لَحَافِظِينَ ١٠

១១. បណ្ដា អ្នកដ៏ថ្លៃថ្នូរ (ដ៏គោរព ស្រឡាញ់)
ដែលបានសរសេរទុក (រឿងដែលអ្នកទាំង
បានប្រព្រឹត្ត) ។

كِرَامًا كَاتِبِينَ ١١

១២. អ្នកទាំងអស់នោះ បានដឹងរឿង ដែលអ្នក
ទាំងអស់គ្នា បានប្រព្រឹត្ត ។

يَعْلَمُونَ مَا تَفْعَلُونَ ١٢

១៣. ពិតប្រាកដ បណ្ដាអ្នកដែលប្រព្រឹត្ត អំពើ
ល្អពិត ប្រាកដជានឹងបានចូលទៅក្នុងឋាន
សួគ៌ ណាអ៊ីម (نعيم) ជាមិនខាន ។

إِنَّ الْأَبْرَارَ لَفِي نَعِيمٍ ١٣

១៤. ហើយពិតប្រាកដ បណ្ដាអ្នកដែលប្រព្រឹត្ត
អំពើទុច្ចរិត ប្រាកដជានឹងបានចូលទៅ
ក្នុងឋាននរក ជហ៊ីម (جحيم) ជាមិនខាន

وَإِنَّ الْفُجَّارَ لَفِي جَحِيمٍ ١٤

១៥. អ្នកទាំងអស់នោះ នឹងចូលទៅក្នុងវា
នៅថ្ងៃជំនុំជំរះ ។

يَصْلَوْنَهَا يَوْمَ الدِّينِ ١٥

១៦. ហើយគ្មានពេលណាដែល អ្នកទាំងអស់
នោះអវត្ត (ឋាននរក) ។

وَمَا هُمْ عَنْهَا بِغَائِبِينَ ١٦

១៧. ហើយ តើអ្នកឯងបានដឹងដែរ ឬទេ ? អ្វីទៅ ថ្ងៃ ជំនុំជំរះនោះ ? وَمَا أَدْرَاكَ مَا يَوْمُ الدِّينِ ١٧

១៨. បន្ទាប់មកទៀត តើអ្នកឯងបានដឹងដែរ ឬទេ ? អ្វីទៅថ្ងៃ ជំនុំជំរះនោះ ។ ثُمَّ مَا أَدْرَاكَ مَا يَوْمُ الدِّينِ ١٨

១៩. គឺថ្ងៃ គ្មាន អ្នកណា ម្នាក់មានសំណាងជួយ ឡើយ ដល់ព្រលឹងដទៃ , ហើយទាំង អស់កិច្ចការ ក្នុងថ្ងៃនោះ ក្នុងការគ្រប់គ្រង របស់ អល់ឡោះ ។ يَوْمَ لَا تَمْلِكُ نَفْسٌ لِنَفْسٍ شَيْئًا وَالْأَمْرُ يَوْمَئِذٍ لِلَّهِ ١٩

បិតកបារ៉ែត្ត វគ្គនេះបានជះបញ្ជាក់ងរតីហេតុការណ៍ ដែលកើតមាន ឡើងនៅក្នុងថ្ងៃ នោះកាល ហើយ បានបញ្ជាក់ ពីលក្ខការ បរិលោក ប្រឆាំង របស់មនុស្សលោក ទៅដល់ការប្រមាទ ដោយអល់ឡោះ ក្តីសុខ និងទុក្ខ របស់ អល់ឡោះ ទៅលើមនុស្សលោកនោះ ។

ដោយឡែកនិងមាន កិច្ចការរបស់អ្នកទាំងអស់ដែលបានប្រព្រឹត្តនោះ គង់តែនឹងបានទទួលការតបស្នងតាមនោះទៀយ ។

ការមូរផ្តុំ التكوير

កប៉ាវិគ្គ វគ្គនេះគេបញ្ចុះនៅម៉ក្កាស់ ដែលមាន ២៩ ឃ្លា
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ اللهب
ឈ្មោះ التكوير មានន័យថា ការមូរផ្តុំ
គេយកមកអំពីពាក្យសំដី كورت ដែលមាននៅក្នុងឃ្លាដំបូង បង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ការវិនាសយ៉ាងបញ្ជូរ ដែលកើតមានឡើង នៅថ្ងៃកេះកាល ។
នាថ្ងៃនោះគ្រប់ៗវិញ្ញាណ គង់តែនឹងដឹងនូវអ្វីៗដែលខ្លួនបានប្រព្រឹត្ត រួចមកហើយ នៅក្នុងលោកនោះ ។
ព្រះគម្ពីរ អាល់គួរអាន (القرآن) គឺពាក្យសំដីរបស់ អុលឡោះ ។
តាមរយៈទេវៈ (جبريل) យឺបព្រៀល ដោយបានបញ្ជាក់យ៉ាងច្បាស់ ថា សាវ៉ះ(ណាពី) មូហាំម៉ាត់នោះ ជាអ្នកនាំដំណឹង ពីអុលឡោះ ។
ព្រះគម្ពីរ អាល់គួរអានជាក្រិត្យក្រម សំរាប់ដោះបញ្ហាំង បង្ហាញនូវបញ្ហា របស់មនុស្សលោក ដែលមានចិត្តចង់រស់នៅក្នុងការស្មោះត្រង់ ។
លោកយ៉ាយនៃភក្តីសុខដុមរម្យនាក្នុងការរស់នៅរបស់មនុស្សលោក កើតមាន ឡើង បានលុះត្រាតែនោះ ក៏ដោយសារមកអំពី ការផ្តល់បង្ហាញពី អុលឡោះជាម្ចាស់ ទិង ។

التكوير
ការមូរផ្តុំ

ដោយព្រះនាមអុលឡោះ ម្ចាស់ប្រណីបរមា بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

សាររាល់ទៀតគួរស៍ បងកា សេចក្ដីប្រណី

១. ពេលណាហើយ ព្រះអាទិត្យ គេបានរុំវា

إِذَا ٱلشَّمْسُ كُوِّرَتْ ١

២ ហើយពេលណាផ្កាយទាំងអស់បានធ្លាក់
(ដោយព្រោកព្រាត) ។

وَإِذَا ٱلنُّجُومُ ٱنكَدَرَتْ ٢

៣. ហើយពេលណាភ្នំទាំងឡាយ គេបាន
បង្ហោះវា (រសាត់តាមខ្យល់) ។

وَإِذَا ٱلْجِبَالُ سُيِّرَتْ ٣

៤ ហើយពេលណាសត្វអូដ្ឋទាំងឡាយ ដែល
ដើង គេគិតរវីរវល់ ។

وَإِذَا ٱلْعِشَارُ عُطِّلَتْ ٤

៥. ហើយពេលណាសត្វសាហាវ ទាំងឡាយ
គេបានប្រមូលផ្ដុំ

وَإِذَا ٱلْوُحُوشُ حُشِرَتْ ٥

៦ ហើយពេលណា សមុទ្រទាំងអស់ គេបានធ្វើ
អោយពុះកញ្ជ្រោលឡើង

وَإِذَا ٱلْبِحَارُ سُجِّرَتْ ٦

៧. ហើយពេលណាវិញ្ញាណទាំងអស់
គេបានបញ្ជូលបញ្ជូលវិញ ។

وَإِذَا ٱلنُّفُوسُ زُوِّجَتْ ٧

៨. ហើយពេលណាទារកភេទស្រីទាំងរស់
ដែលគេកប់ទាំងរស់នោះ គេបានសួរ

وَإِذَا ٱلْمَوْءُۥدَةُ سُئِلَتْ ٨

៩. ដោយសារបាបអ្វី គេសម្លាប់វា ។

بِأَيِّ ذَنۢبٍ قُتِلَتْ ٩

១០ ហើយពេលណា បញ្ជី ទាំងអស់ គេ បានលាតត្រដាង ។	وَإِذَا الصُّحُفُ نُشِرَتْ	١٠
១១ ហើយពេលណាមេឃគេញែកចោល របើកធ្លាក់ធ្លាយឡើង ។	وَإِذَا السَّمَاءُ كُشِطَتْ	١١
១២. ហើយពេលណាឋាននរកគេបាន បញ្ឆេះឡើង ។	وَإِذَا الْجَحِيمُ سُعِّرَتْ	١٢
១៣ ហើយពេលណាឋានសួគ៌គេបានភ្ជិតមក	وَإِذَا الْجَنَّةُ أُزْلِفَتْ	١٣
១៤ ទើបព្រលឹង បានដឹងហើយ ទាំងអស់ នូវកាលណាចំនួន អ្វីដែលវាបានប្រព្រឹត្តមក ហើយនោះ ។	عَلِمَتْ نَفْسٌ مَا أَحْضَرَتْ	١٤
១៥. ពិតប្រាកដ អញបានស្បថនឹងផ្កាយ អាល់ ឃុន្នោស (الخنس) ដែលមានពន្លឺនៅពេល ថ្ងៃ) ។	فَلَا أُقْسِمُ بِالْخُنَّسِ	١٥
១៦. ដែលដើរវិលវិញ ហើយទៀតនឹងផ្កាយ អាល់គុន្នោស (الكنس) ដែលមានពន្លឺនៅ ពេលយប់)	الْجَوَارِ الْكُنَّسِ	١٦
១៧. ហើយបានស្បថនឹងយប់ ពេលណាបាន ដឹកអស់ពន្លឺងងឹតរបស់វា ។	وَاللَّيْلِ إِذَا عَسْعَسَ	١٧

وَالصُّبْحِ إِذَا تَنَفَّسَ ١٨

១៨. ហើយបានស្បថនឹងពេលទៀបភ្លឺ
ពេលណាវាបាន បញ្ចេញរស្មី

إِنَّهُ لَقَوْلُ رَسُولٍ كَرِيمٍ ١٩

១៩ ពិតប្រាកដ អាល់គួរអាន (القرآن) គឺ
ជាពាក្យសំដី របស់អ្នកនាំសារដ៏ថ្លៃថ្នូរ

ذِي قُوَّةٍ عِندَ ذِي الْعَرْشِ ٢٠
مَكِينٍ

២០ អ្នកដែលមានឫទ្ធិនុភាព ដោយមានគតិខ្លួន
ដ៏ខ្ពង់ខ្ពស់ នៅជិតអ្នកដែលគ្រប់គ្រងអារ
-ស (العرش) ដ៏រឹងប៉ឹង។

مُطَاعٍ ثَمَّ أَمِينٍ ٢١

២១. អ្នកដែលគេប្រតិបត្តិតាម នៅទីនោះ
ហើយអ្នកដែលគេមានសេចក្តីទុកចិត្ត។

وَمَا صَاحِبُكُم بِمَجْنُونٍ ٢٢

២២. ហើយសំឡាញ់របស់អ្នកទាំងអស់គ្នា
(មូហាំម៉ាត់) មិនមែនជាមនុស្សឆ្កួតលីលាទេ។

وَلَقَدْ رَآهُ بِالْأُفُقِ الْمُبِينِ ٢٣

២៣. ហើយពិតប្រាកដ (មូហាំម៉ាត់) បានឃើញ
វា [ឈ្មោះជីព្រាអ៊ីល: (جبريل)] នៅឯជើងមេឃ
(ផ្តេក) (លើមេឃ) យ៉ាងច្បាស់លាស់។

وَمَا هُوَ عَلَى الْغَيْبِ ٢٤
بِضَنِينٍ

២៤ ហើយគ្មានទេ (មូហាំម៉ាត់) កំណាញ់ចំពោះ
ការអាថ៌កំបាំង (ដែលវាបានឃើញ)។

وَمَا هُوَ بِقَوْلِ شَيْطَانٍ ٢٥
رَّجِيمٍ

២៥. ហើយគ្មានទេ អាល់គួរអាន (القرآن) នោះ
ជាពាក្យសំដី របស់ពួកបិសាចដែល
ត្រូវគេប្រទេចផ្តាសា

២៦ ដើម្បីបានជា ជីវិតទៅ ពួកឯងដើរទៅឯណា | فَأَيْنَ تَذْهَبُونَ ٢٦
ក្នុង និងផ្លូវនៃសេចក្ដីពោះទៅ ។

២៧. ក្បួននេះ (អាល់គួរអាន) លើកលែងតែ | إِنْ هُوَ إِلَّا ذِكْرٌ لِلْعَالَمِينَ ٢٧
សំរាប់រំឭក ទៅលើពិភពលោក ។

២៨. សំរាប់អ្នកណា ហើយដែលព្រមខ្លួនឯង | لِمَنْ شَاءَ مِنْكُمْ أَنْ يَسْتَقِيمَ ٢٨
អោយពួកឯងដើរតាមគម្ពីរនោះ ទៅលើផ្លូវដែល
ត្រឹមត្រូវ ។

២៩. ហើយពួកបានដូចគោលបំណងល្អណាមួយតាម | وَمَا تَشَاءُونَ إِلَّا أَنْ ٢٩
របស់ពួកឯងនេះ លើកលែងតែ អល់ឡោះ ជា | يَشَاءَ اللَّهُ رَبُّ الْعَالَمِينَ
ម្ចាស់ពិភពលោក មានប្រាថ្នាយល់ព្រម ។

បឹតកថាវិត វគ្គនេះ បានបញ្ជាក់ អំពីហោរាការណ៍ដែលកើតឡើង
នៅថ្ងៃចុងក្រោយ (គិយ៉ាម៉ះ) ។ ហើយការពិតគម្ពីរអាន: គឺការផ្ដល់មកពី
អល់ឡោះ ([illegible]) ហើយនិងអំពីសក្ដានុពលរបស់អល់ឡោះ ដ៏
[illegible] ។

គាត់បានធ្វើមុខជូរ عبس

ការពន្យល់ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កះ ដែលមាន ៤២ បន្ទូល ។
គេបានបញ្ចុះវគ្គនេះ ក្រោយពេលដែលគេបានបញ្ចុះវគ្គ النجم
ឈ្មោះ عبس មានន័យថា គាត់បានធ្វើមុខជូរ
គេយកពាក្យនេះពីពាក្យសំដី عبس ដែលមាននៅក្នុងបន្ទូលទីមួយខាងដើម
នៃវគ្គនេះ ។

តាមការនិទានក្នុងដំណើររឿងដែលនាំមក ថាពេលនោះឯង រ៉សូលុលឡោះ សក្កាធិទូតរបស់អល់ឡោះ បានអង្គុយហើយនិយាយពាក្យជាមួយនឹងអ្នកមុខ ក្រុមការជាតិ គុរ៉ៃស ដោយសារៈ(ហេតុ)សង្ឃឹមថា មុខជាអ្នកទាំងអស់នឹងចូល សាសនា ។ ក្នុងពេលនោះឯង បានដល់មកហើយ អ៊ិបនូម៉ិកទូម (ابن مكتوم) ជាមិត្តសម្លាញ់របស់សក្កាធិទូតរបស់អល់ឡោះ ដែលពិការភ្នែក ហើយគាត់ មានចិត្តសង្ឃឹមថា សក្កាធិទូតរបស់អល់ឡោះ (رسول الله) មុខជានឹង ស្តាប់បញ្ហាខ្លះៗនៃគម្ពីរអាល់គួរអាន នៅពេលនោះ គាត់ដែលអល់ឡោះទ្រង់ បានបញ្ចុះមកនោះ ។ តែថាដូច សក្កាធិទូតរបស់អល់ឡោះ (رسول الله) ស្អប់-ខ្ពើមហើយមិនយកចិត្តទុកដាក់ លោកបានធ្វើមុខជូរ ហើយបែរខ្នងទៅកាន់ ទិសទៀត អ៊ិបនូម៉ិកទូម (ابن مكتوم) ដែលជាអ្នកពិការនោះ ។

បន្ទាប់ពីនេះហើយ អល់ឡោះបានបញ្ចុះវគ្គនេះ (عبس) ដើម្បីរំលឹក ទៅលើការប្រព្រឹត្តិរបស់ សក្កាធិទូតរបស់អល់ឡោះ (رسول الله) ចំពោះ ដំណើរ អ៊ិបនូម៉ិកទូម (ابن مكتوم) នោះឯង ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

១- ការរំលឹកឡើង ÷

ខសូត្រដែលបង្ហាញថា អល់ឡោះ ជាម្ចាស់ ដែលជួយរក្សា នៅគ្រាពេលដែលមនុស្សលោក ស្ថិតនៅក្នុងលក្ខខណ្ឌការណ៍ ជាក់ជូរកោល ។

២) ចលនាបដិវត្តន៍ក្នុងសាសនា ក្រោយពេលមានដំណើរស្ដីបន្ទោស ចំពោះអ្នកដែលលើកតម្កើងតែបញ្ញាល មកក្នុងលក្ខណៈនៃសាសនា ។

រសូលឡោះម្ចាស់ទ្រង់បានបង្គាប់ចំពោះមនុស្សលោក ដោយស្មើគ្នា ដែលមិនគិតពីគុណ ទៅចំពោះការដោះស្រាយបានដោយភ្លាមៗនូវតួនាទីរបស់ទ្រង់ ។

عبس

វាបានធ្វើមុខជូរ

នឹងព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហាករុណាទៀតទ្រង់មហាមេត្តាប្រណី ។	بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ
១. វាធ្វើមុខជូរ ហើយវាបានបែរមុខចេញ ។	عَبَسَ وَتَوَلَّىٰ ١
២ ដោយមនុស្សខ្វាក់ម្នាក់បានមកដល់ហើយ ចំពោះវា ។	أَن جَاءَهُ الْأَعْمَىٰ ٢
៣. ហើយតើអ្នកដឹងនិងដែរឬទេ? ប្រហែលជាវាចង់សំអាតខ្លួនវា ។	وَمَا يُدْرِيكَ لَعَلَّهُ يَزَّكَّىٰ ٣
៤. ឬមួយវាចង់បានការរំឭក ដោយសារការរំឭកនោះនាំអោយមានផលប្រយោ-ជន៍សំរាប់វា ។	أَوْ يَذَّكَّرُ فَتَنفَعَهُ الذِّكْرَىٰ ٤
៥. ចំពោះអ្នកណាគាត់ស្មានខ្លួនវាគ្រប់គ្រាន់	أَمَّا مَنِ اسْتَغْنَىٰ ٥

៦. ទើបបានជាអ្នកឯង ទទួលគាត់ដោយរាក់ទាក់	فَأَنتَ لَهُ تَصَدَّىٰ	٦
៧. ហើយគ្មានចាំបាច់ទេ លើអ្នកឯង សំរាប់ការ ទៅលើអ្នកដែលមិនចង់សំអាតខ្លួន របស់គាត់ ។	وَمَا عَلَيْكَ أَلَّا يَزَّكَّىٰ	٧
៨. ហើយទើបបានជា អ្នកណាបានមកដល់ ឯងដោយប្រញាប់ប្រញាល់ (ដើម្បីស្វែងរក [illegible])	وَأَمَّا مَن جَاءَكَ يَسْعَىٰ	٨
៩. ហើយគាត់នោះ អ្នកដែលកោតខ្លាច ។	وَهُوَ يَخْشَىٰ	٩
១០. ទើបបានជា ឯងគ្មានយកចិត្តទុកដាក់នឹងគាត់ទេ ។	فَأَنتَ عَنْهُ تَلَهَّىٰ	١٠
១១. កុំធ្វើដូចនោះអី ពិតប្រាកដណាស់ [illegible] ការរំលឹកដាស់តឿន ([illegible]) ជាមេរៀនសំរាប់រំឭក ។	كَلَّا إِنَّهَا تَذْكِرَةٌ	١١
១២ ទើបបានជា អ្នកណាដែលមានបំណងចង់ ស្ដាប់ការណ៍ យកចិត្តទុកដាក់នឹងវា ([illegible]) ។	فَمَن شَاءَ ذَكَرَهُ	١٢
១៣. នៅក្នុងព្រះគម្ពីរដែលគេលើកដំកើង ។	فِي صُحُفٍ مُّكَرَّمَةٍ	١٣
១៤ នៅកន្លែងដ៏មហាខ្ពង់ខ្ពស់ដែលស្រស់ស្អាត	مَّرْفُوعَةٍ مُّطَهَّرَةٍ	١٤

១៥. នៅនឹងដៃនៃ (ملئكة) អ្នកនាំសាររបស់ អល់ឡោះ ។	بِأَيْدِي سَفَرَةٍ ١٥
១៦. ដ៏ល្អថ្លៃថ្នូរ ហើយប្រណិប័តន៍ តាម	كِرَامٍ بَرَرَةٍ ١٦
១៧. គេបានជេរតាលាកម្ម មនុស្សលោក ហេតុមកអ្វី វាគ្មានជំនឿជឿ ចំពោះទ្រង់	قُتِلَ الْإِنْسَانُ مَا أَكْفَرَهُ ١٧
១៨. អំពីអ្វីទៅ ដែលអល់ឡោះបានបង្កើតវា នោះ ។	مِنْ أَيِّ شَيْءٍ خَلَقَهُ ١٨
១៩. អំពីមួយដំណក់ទឹកកាម អល់ឡោះ បានបង្កើតវា ហើយបានបំពេញលក្ខណៈរបស់វា ។	مِنْ نُطْفَةٍ خَلَقَهُ فَقَدَّرَهُ ١٩
២០. បន្ទាប់មក អល់ឡោះ បានសម្រួលផ្លូវវា ។	ثُمَّ السَّبِيلَ يَسَّرَهُ ٢٠
២១ បន្ទាប់មកទៀត អល់ឡោះបានបញ្ចូលវា ទៅក្នុង មរណភាព ហើយបានបញ្ចូលវាទៅក្នុងផ្នូរ ។	ثُمَّ أَمَاتَهُ فَأَقْبَرَهُ ٢١
២២. បន្ទាប់មកទៀត ពេលណាហើយទ្រង់ចង់ ដ៏ស្វាស់ទ្រង់បញ្ចេញហើយវា (មនុស្សអំពីផ្នូរ) ។	ثُمَّ إِذَا شَاءَ أَنْشَرَهُ ٢٢
២៣ កុំស្មើម្លឹងនោះអី កាលណាវាគ្មានការសម្រេចន៍-	كَلَّا لَمَّا يَقْضِ مَا أَمَرَهُ ٢٣

កិច្ចប្រតិបត្តិ នូវអ្វីៗដែលរសូលឡោះ ប្រើ
ប្រើគាត់ ។

២៤. ដើម្បីឲ្យមនុស្សលោក សញ្ជឹងគិតខ្លះ ទៅ ‏فَلْيَنظُرِ الْإِنسَانُ إِلَىٰ طَعَامِهِ‎ 24
ចំពោះចំណីអាហាររបស់គាត់ ។

២៥. ពិតប្រាកដ យើងបានបញ្ចុះហើយ ‏أَنَّا صَبَبْنَا الْمَاءَ صَبًّا‎ 25
ទឹកភ្លៀង បញ្ចុះយ៉ាងច្រើនពាសពេញ

២៦. បន្ទាប់មក យើងបានបំបែកដី បំបែក ‏ثُمَّ شَقَقْنَا الْأَرْضَ شَقًّا‎ 26
ដាច់ៗ ។

២៧. ដើម្បីបាន យើងបានបណ្ដុះហើយ ‏فَأَنبَتْنَا فِيهَا حَبًّا‎ 27
បណ្ដាគ្រាប់នានា នៅក្នុងវា ។

២៨. ហើយដើមទំពាំងបាយជូរ ហើយនិងបន្លែ ‏وَعِنَبًا وَقَضْبًا‎ 28
នានា ។

២៩. ហើយដើមហ្សៃតូន ហើយនិងដូង ‏وَزَيْتُونًا وَنَخْلًا‎ 29
(ឥន្ទ្រលាំ) ។

៣០. ហើយដីការ ដែលមានដំណាំដ៏ក្រាស់ និង ‏وَحَدَائِقَ غُلْبًا‎ 30
ខៀវខ្ចី ។

៣១. ហើយផ្លែឈើនានា ហើយនិងតិណ ‏وَفَاكِهَةً وَأَبًّا‎ 31
ស្មៅ ។

៣២. ដើម្បីសោយទាន ពីលោកៈ សុខស្រួល សំរាប់អ្នកឯង ទាំងសត្វ ហើយសំរាប់ សត្វចតុប្បាទ របស់អ្នកឯងទាំងអស់គ្នានោះ ។	مَتَاعًا لَّكُمْ وَلِأَنْعَامِكُمْ	٣٢
៣៣. ហើយពេលណាបានដល់មកហើយសម្លេង គឺត្រែស្នែង ។	فَإِذَا جَاءَتِ الصَّاخَّةُ	٣٣
៣៤. នៅក្នុងថ្ងៃនោះ មនុស្សលោករត់ចេញពីកង្វល់ គេរត់ពីបងប្អូនខ្លួន	يَوْمَ يَفِرُّ الْمَرْءُ مِنْ أَخِيهِ	٣٤
៣៥ ហើយរត់ពីមាតា និងបិតារបស់គាត់ ។	وَأُمِّهِ وَأَبِيهِ	٣٥
៣៦. ហើយរត់ពីភរិយា និងបុត្រធីតា របស់គាត់ ។	وَصَاحِبَتِهِ وَبَنِيهِ	٣٦
៣៧. ដ្បិតនោះ គ្រប់ៗ ម្នាក់ៗ រត់ពីអ្នកទាំងអស់ គេ នៅថ្ងៃនោះនឹង មានកិច្ចការរវល់ រៀងៗខ្លួន	لِكُلِّ امْرِئٍ مِّنْهُمْ يَوْمَئِذٍ شَأْنٌ يُغْنِيهِ	٣٧
៣៨. មុខខ្លះ នៅថ្ងៃនោះ មានពន្លឺស្រឡះ ។	وُجُوهٌ يَوْمَئِذٍ مُّسْفِرَةٌ	٣٨
៣៩. សើចសប្បាយ ពេញចិត្តដោយសារក្ដី សប្បាយរីករាយនឹងបុណ្យ ។	ضَاحِكَةٌ مُّسْتَبْشِرَةٌ	٣٩
៤០ ហើយទៀត មុខខ្លះ នៅថ្ងៃនោះ ប្រឡាក់ដោយធូលី ។	وَوُجُوهٌ يَوْمَئِذٍ عَلَيْهَا غَبَرَةٌ	٤٠

៤១. ហើយគ្របដណ្ដប់ទៅទៀតនិងការងងឹត។ تَرْهَقُهَا قَتَرَةٌ ٤١

៤២ អ្នកទាំងអស់នោះហើយ គឺជាបណ្ដាអ្នក أُولَٰئِكَ هُمُ الْكَفَرَةُ الْفَجَرَةُ ٤٢
គ្មានជំនឿ និងជាអ្នកប្រព្រឹត្តអំពើ
អាក្រក់ល្មើសច្បាប់

បរិកថាបរិវត្ត វគ្គនេះគេបានដង្ហែក្រុងយកមកបញ្ជាក់ នូវការទំនុក របស់អល់ឡោះ ទៅចំពោះអនុភាពនូវរបស់អល់ឡោះ ([illegible]) ដែលបានបង្អែកអ្នកមុខអ្នកការជាតិ គូរៃស ។ ក្នុងគ្រីសឿបរបស់រ៉សូលុល-ឡោះ នេះជាមុខជាអ្នកទាំងនោះ ចូលមកគាល់លោកសាសនា អ៊ីស្លាមនេះធ្វើ ក្នុងការបង្កើតជាតិ គូរៃសនេះ ជាការងារការបង្កើត អ៊ីបនូអ៊ីតនូម ([illegible]) ដែលពិតជាកនេះទៅទៀត ។

គេបានបញ្ជាក់យ៉ាងច្បាស់លាស់ នូវជំនឿជឿរបស់ជាតិ គូរៃសនោះ ។

គឺប៉ុណ្ណោះ គួរអាន ([illegible]) ជាដូចរំឭកដោយតាំងបាច់ ។

ដែលលក្ខណៈរបស់មនុស្សលោក គ្មានជំនឿនិងគិតដល់ការដែលអំណរអរគុណទៅ ចំពោះអល់ឡោះ ដោយការប្រមាទការពេកកើនដែរ ដឹកសូរ្យទ្រព្យសម្បត្តិរបស់ខ្លួន ទៀយ ។

មជ្ឈិមាវ النازعات

ករណីវិត្ត គម្ពីរនេះ គេបានបញ្ចុះនៅម៉ាក្កាស់ដែលមាន ៤៦ ឃ្លា ។
គេបញ្ចុះគម្ពីរនេះក្រោយពេលដែលគេបានបញ្ចុះគម្ពីរ النبأ
ឈ្មោះ النازعات មានន័យថា មរណៈ (អ្នកដកយកជីវិត) ។
គេយកមកដាក់ជាចំណងជើងថា النازعات ដែលមាននៅក្នុងឃ្លាទីមួយ របស់
គម្ពីរនេះ ។
ទៀតគេហៅឈ្មោះថា الساهرة ដែលគេយកមកពីឃ្លាទី ១៤ នៃគម្ពីរនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់គម្ពីរ

១- ជំនឿ: អល់ឡោះបានស្បថថា អស់ដែលកើតល់ទៅថ្ងៃនេះកាល ។
ហើយបដិសេធរបស់បណ្ដាអ្នកដែលបដិសេធទៅ
លើការរស់ឡើងវិញរបស់អល់ឡោះ គឺអ្នកមុស្ររីគីន (مشركين) ។
- ហើយមនុស្សលោកនោះ គេដឹងដែលកើតទុក្ខនៅថ្ងៃបរលោកនោះ ។
- ទៀតមនុស្សលោកមិនដឹងពីថ្ងៃ របស់ហេតុការណ៍ដែលកើតមាន
ឡើងនៃរយៈពេល ថ្ងៃនេះកាល (قيامة) ។
២/ និទានរឿង គេនិទានរឿងរបស់ណាពី (មូសា) ជួបជាមួយ -
ហ្វៀរ៉អ៊ូន (فرعون)

النازعات

មជ្ឈិមាវ

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់ មហា
សាណាណិតទៀតទ្រង់ មហាមេត្តាប្រណី ។

بِسْمِ اللهِ الرَّحْمنِ الرَّحِيمِ

១. (អល់ឡោះ) បានស្បថនឹង ម៉ាឡាអ៊ីកាត់ (ملئكة عزرائيل) ដែលដកវិញ្ញាណ ពួកកាហ្វៀរ ដោយខ្លាំង ។	وَالنَّٰزِعَٰتِ غَرْقًا	١
២. ហើយ (អល់ឡោះ) បានស្បថនឹង ម៉ាឡាអ៊ីកាត់ (ملئكة) ដែលដកវិញ្ញាណហើយ ទន់ភ្លន់ ។	وَالنَّٰشِطَٰتِ نَشْطًا	٢
៣. ទៀតផង បានស្បថនឹង ពពួកទេវៈ (ملئكة) ដែលហោះ អាកាស មេឃ យ៉ាងលឿនបំផុត ។	وَالسَّٰبِحَٰتِ سَبْحًا	٣
៤ ហើយទៀត ខ្ញុំបានស្បថនឹងពពួកទេវៈ (ملئكة) ដែលរត់លឿន នាំគ្នាលឿន (ក្នុងកិច្ចការ) ។	فَالسَّٰبِقَٰتِ سَبْقًا	٤
៥. ហើយទៀត ខ្ញុំបានស្បថនឹងពពួកទេវៈ (ملئكة) ដែលរៀបចំកិច្ចការ (ក្នុងលោក) ។	فَالْمُدَبِّرَٰتِ أَمْرًا	٥
៦. នៅថ្ងៃដែលគេផ្លុំ ស្នែង (الصور ، سنكلا) លើកទី១. បានរំជួយ ហើយ ពិភពលោក ។	يَوْمَ تَرْجُفُ الرَّاجِفَةُ	٦
៧. បន្ទាប់ពីផ្លុំស្នែងលើកទី១.មក បន្ទាប់ផ្លុំស្នែងលើកទី២. ។	تَتْبَعُهَا الرَّادِفَةُ	٧
៨. ចិត្តមនុស្ស នៅក្នុងថ្ងៃនោះ ដែលនឹង ភ័យខ្លាច	قُلُوبٌ يَوْمَئِذٍ وَاجِفَةٌ	٨
៩. ឃើញនឹងភ្នែកចិត្តដោយភ័យញាប់ញ័រ ។	أَبْصَٰرُهَا خَٰشِعَةٌ	٩

១០. ពួកទាំងអស់នោះបាននិយាយថា តើពួកយើងនឹងជីវិតម្ដងទៀតឬទេ? គេនឹងបង្វិលត្រឡប់យើងទៅរកការរស់ឡើងវិញ ក្រោយពីស្លាប់ ។	١٠ يَقُولُونَ أَإِنَّا لَمَرْدُودُونَ فِي الْحَافِرَةِ
១១. តើដូចនោះនឹងឬទេ? ពេលណាយើងត្រូវក្លាយទៅជាឆ្អឹងពុករលួយ (គេនឹងបង្កើតឡើងវិញ) ។	١١ أَإِذَا كُنَّا عِظَامًا نَخِرَةً
១២. ពួកទាំងអស់នោះបាននិយាយថា បើដូច្នេះ វាជារឿងនោះ ការវិលត្រឡប់នោះខ្ញាស់ វាខាតបង់ហើយ ។	١٢ قَالُوا تِلْكَ إِذًا كَرَّةٌ خَاسِرَةٌ
១៣. ដោយហេតុថា ពិតប្រាកដ ការវិលត្រឡប់នោះ គ្រាន់តែការស្រែកឡើងវិញនោះ ដ៏គួរឲ្យតក់ស្លុត ។	١٣ فَإِنَّمَا هِيَ زَجْرَةٌ وَاحِدَةٌ
១៤. ដោយហេតុ នៅពេលនោះ ពួកទាំងអស់នោះ ភ្ញាក់ទៅរស់ម្ដងទៀត (ក្រោយដែលស្លាប់ម្ដង)	١٤ فَإِذَا هُمْ بِالسَّاهِرَةِ
១៥. តើបានមកដល់ឯងឬទេ? (មូហាំម៉ាត់) ប្រវត្តិ របស់ មូសា ។	١٥ هَلْ أَتَاكَ حَدِيثُ مُوسَىٰ
១៦. ពេលណាម្ចាស់វា បានហៅវា នៅលើដីទំនាប (طوى) ដ៏ជ្រះស្អាត ។	١٦ إِذْ نَادَاهُ رَبُّهُ بِالْوَادِ الْمُقَدَّسِ طُوًى
១៧. ចូរទៅឯស្ដេច ដ៏អាក្រក់ ហ្វៀរអ៊ូន ពិតប្រាកដ វាបានបំពានខ្លាំង	١٧ اذْهَبْ إِلَىٰ فِرْعَوْنَ إِنَّهُ طَغَىٰ

១៨. ហើយជាវស់ដោយថា: តើអ្នកឯងចង់ សំអាតខ្លួនដែរឬទេ ? — فَقُلْ هَل لَّكَ إِلَىٰٓ أَن تَزَكَّىٰ ١٨

១៩. ហើយខ្ញុំនឹងចង្អុលបង្ហាញអ្នកឯង ទៅ ចំពោះម្ចាស់របស់ឯង ដើម្បី អោយអ្នកឯង កោតខ្លាច ។ — وَأَهْدِيَكَ إِلَىٰ رَبِّكَ فَتَخْشَىٰ ١٩

២០ បន្ទាប់មក មូសាបានបង្ហាញចំពោះ ហ្វៀរអ៊ូន នូវមហាឫទ្ធិឫទ្ធីមហាធំ ។ — فَأَرَىٰهُ ٱلْءَايَةَ ٱلْكُبْرَىٰ ٢٠

២១. ក៏ប៉ុន្តែ (ហ្វៀរអ៊ូន) បានគិតថាកុហក ហើយវាបានធ្វើទុច្ចរិត ។ — فَكَذَّبَ وَعَصَىٰ ٢١

២២. ក្រោយមកវាបានបែរចេញ ដើម្បីប្រឹងប្រែង (ប្រឆាំងនឹងមូសា) — ثُمَّ أَدْبَرَ يَسْعَىٰ ٢٢

២៣. ទើបវាបានប្រមូល ហើយបាន សំរែកហៅ (ក្រុមនិងទ័ពរបស់វា) — فَحَشَرَ فَنَادَىٰ ٢٣

២៤ ហើយវាបានពោលខ្លាំងៗថា អញ ជាម្ចាស់របស់អ្នកឯងទាំងអស់គ្នា ដ៏មហា ខ្ពង់ខ្ពស់ ។ — فَقَالَ أَنَا۠ رَبُّكُمُ ٱلْأَعْلَىٰ ٢٤

២៥. ដូច្នេះ អល់ឡោះ បានធ្វើទារុណកម្ម វាហើយ នៅថ្ងៃ បរលោក និង លោកីយ ។ — فَأَخَذَهُ ٱللَّهُ نَكَالَ ٱلْءَاخِرَةِ وَٱلْأُولَىٰٓ ٢٥

٢٦. ពិតប្រាកដ ក្នុងដំណើរការណ៍ដែលដូច   إِنَّ فِي ذَٰلِكَ لَعِبْرَةً لِّمَن يَخْشَىٰ ٢٦
នោះ ដើម្បីជាមេរៀនដល់ពួកណា
ដែលកោតខ្លាច ។

٢٧ តើពួកឯងទាំងអស់គ្នា [illegible] លំបាក   أَأَنتُمْ أَشَدُّ خَلْقًا أَمِ السَّمَاءُ ۚ بَنَاهَا ٢٧
ក្នុងការបង្កើត ឬមួយមេឃ ដែលទ្រង់
បានកសាងវា ហើយមកនោះ ។

٢٨ ទ្រង់បានលាបនាវា(មេឃ) ហើយ   رَفَعَ سَمْكَهَا فَسَوَّاهَا ٢٨
ទ្រង់បានបំពេញនូវលក្ខណៈរបស់វា(មេឃ)។

٢٩. ហើយទ្រង់បានបង្កើតនូវពេលយប់   وَأَغْطَشَ لَيْلَهَا وَأَخْرَجَ ضُحَاهَا ٢٩
ងងឹតក្នុងវា(មេឃ) ហើយទ្រង់បាន
បញ្ចេញពន្លឺនៅពេលថ្ងៃក្នុងវា(មេឃ)។

٣٠. ហើយផែនដី ក្រោយពីការដូចនេះ   وَالْأَرْضَ بَعْدَ ذَٰلِكَ دَحَاهَا ٣٠
មក គេបានលាតត្រដាងវា(ផែនដី)

٣١. ទ្រង់បានបញ្ចេញពីផែនដីនោះ   أَخْرَجَ مِنْهَا مَاءَهَا وَمَرْعَاهَا ٣١
ទឹក ហើយនិងដំណាំដាំដុះ ។

٣٢. ហើយបណ្ដា ភ្នំទាំងឡាយ ទ្រង់បានតម្កល់   وَالْجِبَالَ أَرْسَاهَا ٣٢
វាយ៉ាងនឹងនរ ។

٣٣. ដើម្បីអោយមានការប្រើប្រាស់ស្រួល   مَتَاعًا لَّكُمْ وَلِأَنْعَامِكُمْ ٣٣
សំរាប់ពួកឯងទាំងអស់គ្នា ហើយនិងបណ្ដា

សត្វពាហនៈ របស់អ្នកឯងទាំងអស់គ្នា ។

៣៤. ដើបពេលណាបានមកដល់ហើយ
គ្រោះថ្នាក់ មហន្តរាយ ដ៏មហាធំ ។

فَإِذَا جَاءَتِ الطَّامَّةُ الْكُبْرَىٰ ٣٤

៣៥ នៅថ្ងៃនោះ មនុស្សលោក បាននឹកឃើញ
រឿងវិញ នូវអ្វីៗ ដែលគេបានប្រព្រឹត្ត
មកហើយនោះ ។

يَوْمَ يَتَذَكَّرُ الْإِنسَانُ
مَا سَعَىٰ ٣٥

៣៦. ហើយគេបានបង្ហាញឋាននរក សំរាប់
អ្នកណាដែលបានឃើញ ។

وَبُرِّزَتِ الْجَحِيمُ لِمَن يَرَىٰ ٣٦

៣៧. ដើបចំពែក អ្នកណាៗ ហើយដែល
រំលោភ ច្បាប់ ។

فَأَمَّا مَن طَغَىٰ ٣٧

៣៨ ហើយគេបានបន្ទីការរស់នៅក្នុងលោកិយ ។

وَآثَرَ الْحَيَاةَ الدُّنْيَا ٣٨

៣៩. ដើបបានជា ពិតប្រាកដ ឋាននរកនោះ
ជាកន្លែង សំរាប់គេ ។

فَإِنَّ الْجَحِيمَ هِيَ الْمَأْوَىٰ ٣٩

៤០ ហើយចំពែក អ្នកណាៗ ដែលបានកោត
ខ្លាចចំពោះ ម្ចាស់គេ នឹងមហាខ្ពង់ខ្ពស់ ហើយ
គេហាំងគេ ខ្លួនគេ សពីការ តាមតណ្ហា ។

وَأَمَّا مَنْ خَافَ مَقَامَ رَبِّهِ ٤٠
وَنَهَى النَّفْسَ عَنِ الْهَوَىٰ

៤១. ដើបពិតប្រាកដ ឋានសួគ៌នោះជា
កន្លែង សំរាប់គេ ។

فَإِنَّ الْجَنَّةَ هِيَ الْمَأْوَىٰ ٤١

៤២. ពួកទាំងអស់នោះ នឹងសួរឯង (មូហាំម៉ាត់) អំពីថ្ងៃ បរលោក ពេលណាទៅគេ នឹង បង្កើតវា) ។ يسئلونك عن الساعة أيان مرسيها ٤٢

៤៣. តើឯងទៅអ្នកឯង នឹងដឹងអំពីរឿងវា (ថ្ងៃបរលោក, [illegible]) ។ فيم أنت من ذكريها ٤٣

៤៤ ដល់ព្រះម្ចាស់ឯងហើយ ដែលមានការជ្រាប នឹងត្រូវរៀងនេះ ។ إلى ربك منتهيها ٤٤

៤៥. តាមពិតប្រាកដ អ្នកឯងគ្រាន់តែជាអ្នកព្រមាន ដល់ពួកអ្នកណាៗ ដែលកោតខ្លាចចំពោះវា (ថ្ងៃបរលោក) ។ إنما أنت منذر من يخشيها ٤٥

៤៦. ហាក់ដូចជា (ថ្ងៃបរលោក) ពួកទាំងអស់នោះ នឹងបានឃើញហើយវា (ថ្ងៃបរលោក) នោះ ហាក់បីដូចជា ពួកទាំងអស់នោះ គ្មានបាន រស់នៅក្នុងលោកីយនេះលើសពីមួយល្ងាច ឬពេលព្រឹក ប៉ុណ្ណោះ ។ كأنهم يوم يرونها لم يلبثوا إلا عشية أو ضحيها ٤٦

បិទកថាពិរ៉ាក់ ទំព័រនេះបានបញ្ចប់អំពី សម្បត្តិរបស់អល់ឡោះ នៅនឹងពេលកទៅ (ដូម៉ែ) ដោយប្រាប់ពីការប្រាប់ហើយ ក្រោយពីការរបស់អល់ឡោះ ។ ដោយប្រាកដថ្ងៃជះកាល ([illegible]) នោះ ទុកជាមិនកើតមានឡើងទាំងមាន ។ ទៀតអល់ឡោះនឹងបង្កើត មនុស្សលោក ឡើងវិញដោយហើយ ស្រួល នាមួយលះស្រេចបានត្រឡប់ក៏បាន ទៅបណ្តាអ្នកមូស្លីម

. អុសព្រោះ និង បង្កើតឡើងវិញ ដោយសារព្រះរសូល
. ហើយនិងការគោរពតាមអ៊ីមាន នៅចំពោះ បណ្ដាអ្នកដែល បរិសោធ
នូវការបង្កើតឡើងវិញ ។

តាវុណាកម្ម ដែលហៅថា គូរអាន បានទទួលរួចមកហើយនោះ ព្រះមហា
មួយទៀត និងអ្នកដែលតាមហៅថា គ្រិស្ដសាសនា ។

វិគ្គលេះ បាន បញ្ជាក់ច្បាស់ នូវព្រឹត្តិការណ៍ដែលកើតឡើង របស់បណ្ដា
អ្នកមូស្រិគីន (مشركين) នៅក្នុងសម័យកាល (جاهلية) ។

ដែលបណ្ដាន់..! តាវុណាកម្ម ហៅថា យ៉ាងច្បាស់លាស់នៅក្នុង
សម័យកាលនោះ ។

ពត៌មានដ៏សំខាន់ النبأ

កំណើតវគ្គ. គេបានបញ្ចុះវគ្គនេះនៅ មឹកកាស់ ដែលមាន ៤០ ឃ្លា ។
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ المعارج
ឈ្មោះ النبأ មានន័យថា ពត៌មានដ៏សំខាន់ ។
គេយកមកពីពាក្យសំដី النبأ ដែលមាននៅក្នុងឃ្លាទី២ នៃវគ្គនេះ ។

គេហៅឈ្មោះទៀតថា عم يتساءلون ដែលគេយកមកពីពាក្យសំដី عم يتساءلون ដែលបានមកពីឃ្លាដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ជំនឿ:

បណ្ដាអ្នកមុស្ហរិក (مشركين) ដែលបានបដិសេធនៅថ្ងៃដែលគេបានបង្កើតមនុស្សលោកឡើងវិញ ហាប្តូយនឹងការណ៍ក្ដី របស់អល់ឡោះ ទៅលើដំណោះអាកប្បកិរិយា របស់អ្នកទាំងអស់នោះ ។

អល់ឡោះ មានឫទ្ធិអំណាច ដែលគេបានឃើញក្នុងលោកីយនេះ ជាភស្តុតាងថា មានថ្ងៃបង្កើតឡើងវិញ ។

ហេតុការណ៍កើតឡើង នៅថ្ងៃដែលគេបង្កើតមនុស្សលោកឡើងវិញ នៅថ្ងៃនោះឯង ។ ចំពោះបណ្ដាអ្នកដែលបានភូតកុហក នឹងភស្តុតាងរបស់អល់ឡោះនោះ អ្នកទាំងនោះនឹងទទួលទារុណកម្មពីភ្លើងនរក

រីឯបណ្ដាអ្នកដែលមានជំនឿជឿ នឹងភស្តុតាងរបស់អល់ឡោះ អ្នកទាំងនោះហើយ គ្រាន់ជានឹងបានសួគ៌ស្រស់ស្រាយមិនមានទៀយ ។

អ្នកដែលគ្មានជំនឿ (كافر) នោះ មុខជាមានវិប្បដិសារីសោកស្ដាយជាខ្លាំងទៀយ នៅពេលថ្ងៃគេះកាល (قيامة) នោះ ។

النَّبَأ

ពត៌មានដ៏សំខាន់

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

នឹងព្រះនាមអុលឡោះ ម្ចាស់ទ្រង់មហាសាធារណ៍ ទៀតទ្រង់មហាមេត្តាប្រណី ។

١ عَمَّ يَتَسَآءَلُوْنَ

១. រឿងអ្វីទៅ អ្នកទាំងអស់នោះសួរគ្នាទៅវិញទៅមក ។

٢ عَنِ النَّبَإِ الْعَظِيْمِ

២. រឿងពត៌មានដ៏មហាសំខាន់ ។

٣ الَّذِيْ هُمْ فِيْهِ مُخْتَلِفُوْنَ

៣. ដែលអ្នកទាំងអស់នោះខ្វែងយោបល់ក្នុងវា (ពត៌មាន) ។

٤ كَلَّا سَيَعْلَمُوْنَ

៤. ចូរកុំជឿដូចនោះអី! អ្នកទាំងអស់គេនឹងដឹង ។

٥ ثُمَّ كَلَّا سَيَعْلَمُوْنَ

៥. បន្ទាប់មក ចូរកុំជឿដូចនោះអី! អ្នកទាំងអស់គេនឹងដឹងទេ ។

٦ أَلَمْ نَجْعَلِ الْأَرْضَ مِهٰدًا

៦. ពុំដឹងទេឬ? យើងបានបង្កើតផែនដីឲ្យដូចជាកំរាល ។

٧ وَالْجِبَالَ أَوْتَادًا

៧. ហើយបញ្ចេញភ្នំទាំងឡាយ ឲ្យដូចជាស្នឹង ។

٨ وَخَلَقْنٰكُمْ أَزْوَاجًا

៨. ហើយយើងបានបង្កើតអ្នកឯងទាំងអស់ជាគូៗ ។

៩. ហើយយើងបានបង្កើតការដេក របស់ពួកឯង
ទាំងអស់គ្នា ដើម្បីជាការឈប់សំរាក ។ — وَجَعَلْنَا نَوْمَكُمْ سُبَاتًا ٩

១០. ហើយយើងបានបង្កើតពេលយប់
ដើម្បីជាសំលៀកបំពាក់ — وَجَعَلْنَا اللَّيْلَ لِبَاسًا ١٠

១១ ហើយយើងបានបង្កើតពេលថ្ងៃ
ដើម្បីជាការរស់នៅ ។ — وَجَعَلْنَا النَّهَارَ مَعَاشًا ١١

១២ ហើយយើងបានកសាងនៅពីលើពួក
ឯងទាំងអស់គ្នា ប្រាំពីរជាន់ដែលមា
នរឹងប៉ឹង ។ — وَبَنَيْنَا فَوْقَكُمْ سَبْعًا شِدَادًا ١٢

១៣ ហើយយើងបានបង្កើតចង្កៀងមួយដែល
មានពន្លឺរស្មីដ៏ភ្លឺថ្លា ។ — وَجَعَلْنَا سِرَاجًا وَهَّاجًا ١٣

១៤ ហើយយើងបានបញ្ចុះពីពពក
ទឹកដ៏ច្រើន ។ — وَأَنزَلْنَا مِنَ الْمُعْصِرَاتِ مَاءً ثَجَّاجًا ١٤

១៥. ដើម្បីយើងនឹងបញ្ចេញនូវពីវានោះ
គ្រាប់ធញ្ញា ហើយនិងដំណាំផ្សេងៗ ។ — لِنُخْرِجَ بِهِ حَبًّا وَنَبَاتًا ١٥

១៦. ហើយនិងសួនច្បារដែលពោរពេញទៅ
ដោយរុក្ខជាតិ គ្រប់ប្រភេទយ៉ាងច្រើន ។ — وَجَنَّاتٍ أَلْفَافًا ١٦

១៧. ពិតប្រាកដនៅថ្ងៃកាត់សេចក្ដី (ថ្ងៃនោះកាល) — إِنَّ يَوْمَ الْفَصْلِ كَانَ مِيقَاتًا ١٧

- គឺជាថ្ងៃវិនិច្ឆ័យកំណត់ទុក ។

១៨. នៅថ្ងៃនោះ គេផ្លុំស្នែង
(الصُّوْرُ ، سقكلا) ហើយអ្នកនឹងមកទាំងអស់
គ្នា បានមកដល់ជាក្រុមៗ ។

يَوْمَ يُنفَخُ فِي الصُّورِ
فَتَأْتُونَ أَفْوَاجًا ١٨

១៩. ហើយគេបានបើកមេឃ ទើបមេឃ
បានក្លាយទៅជាមានមាត់ទ្វារច្រើន ។

وَفُتِحَتِ السَّمَاءُ فَكَانَتْ
أَبْوَابًا ١٩

២០. ហើយគេបានបណ្តើរភ្នំទាំង
ឡាយ ទើបវាហើរហើយវាក៏ដូចនោះ
សណ្ឋានដូចជាពពកមាន ។

وَسُيِّرَتِ الْجِبَالُ فَكَانَتْ
سَرَابًا ٢٠

២១. តាមពិតនរកជាដីកន្លែងនោះ មានហើយ
គឺ ជាកន្លែងឃ្លាំមើលទុក ។

إِنَّ جَهَنَّمَ كَانَتْ مِرْصَادًا ٢١

២២ សំរាប់អ្នកបំពានច្បាប់ កន្លែងនោះ
និងហើយ ជាកន្លែងអ្នកទាំងអស់នោះវិល-
ត្រឡប់ ។

لِلطَّاغِينَ مَآبًا ٢٢

២៣. អ្នកទាំងឡាយនោះ បានរស់នៅក្នុងវា
ជាប់ជានិច្ច ។

لَابِثِينَ فِيهَا أَحْقَابًا ٢٣

២៤ អ្នកទាំងអស់នោះ គ្មានបានស្គាល់រសជាតិ
ត្រជាក់ នៅក្នុងវាឡើយ ហើយគ្មាន
ស្គាល់រសជាតិផឹក ។

لَا يَذُوقُونَ فِيهَا بَرْدًا
وَلَا شَرَابًا ٢٤

២៥. លើកលែងតែទឹកពុះដ៏ក្តៅ ហើយ និងទឹកខ្ទុះ ។ — ٢٥ إِلَّا حَمِيمًا وَغَسَّاقًا

២៦. ជាការតបស្នងដោយសមហេតុសមផល — ٢٦ جَزَاءً وِفَاقًا

២៧. ពិតប្រាកដ ពួកគេទាំងអស់នោះ កាលពីមុន ពួកគេទាំងនោះ គ្មានសង្ឃឹមថា នឹងមានការជំនុំជម្រះទេ ។ — ٢٧ إِنَّهُمْ كَانُوا لَا يَرْجُونَ حِسَابًا

២៨. ហើយ ពួកគេទាំងអស់នោះ បានភូតភរ និងអាយាត់ របស់យើង ភូតភរ ដោយពិតប្រាកដ ។ — ٢٨ وَكَذَّبُوا بِآيَاتِنَا كِذَّابًا

២៩. ហើយគ្រប់សព្វវត្ថុទាំងអស់ដែល យើងបានកត់ទុក វារួចមកហើយនៅ ក្នុងព្រះគម្ពីរ ។ — ٢٩ وَكُلَّ شَيْءٍ أَحْصَيْنَاهُ كِتَابًا

៣០. ដូចនោះ ចូរអ្នកឯងទាំងអស់គ្នា ព្រៀប ភ្លក់ចុះ រសជាតិ ហើយយើងនឹងគ្មាន បន្ថែមទេលើអ្នកឯងទាំងអស់គ្នា លើកលែងតែ ការទារុណកម្ម ដ៏ខ្លាំងក្លា ។ — ٣٠ فَذُوقُوا فَلَن نَّزِيدَكُمْ إِلَّا عَذَابًا

៣១. ពិតប្រាកដ ចំពោះអ្នកដែលកោតខ្លាច នោះបានជ័យជំនះ ។ — ٣١ إِنَّ لِلْمُتَّقِينَ مَفَازًا

៣២ ជាការនានា ហើយនិងទំពាំងបាយជូរ — ٣٢ حَدَائِقَ وَأَعْنَابًا

៣៣ ហើយបណ្ដាស្រីៗ ដែលពេញក្រមុំ | وَكَوَاعِبَ أَتْرَابًا ٣٣
ពាវ័យ មានអាយុស្មើគ្នាទាំងអស់ ។

៣៤ ហើយកែវទាវដែលពោរពេញ | وَكَأْسًا دِهَاقًا ٣٤
(ដោយស្រាទៀងស៊ុដិក)

៣៥. គ្មានឮសោះទេ អ្នកទាំងអស់នោះនៅ | لَا يَسْمَعُونَ فِيهَا لَغْوًا ٣٥
ក្នុងវា (សួគ៌) ការដែលឥតប្រយោជន៍ | وَلَا كِذَّابًا
ហើយនិងការភូតភរកុហក ។

៣៦. ការតបស្នង អំពីម្ចាស់ទ្រង់ និងអំណោយ | جَزَاءً مِنْ رَبِّكَ عَطَاءً ٣٦
ដ៏ច្រើនលើសលុប | حِسَابًا

៣៧. ម្ចាស់ដែលគ្រប់គ្រងលើមេឃនិងផែនដី | رَبِّ السَّمٰوٰتِ وَالْأَرْضِ ٣٧
ហើយនិងអ្វីៗដែលនៅរវាងទាំង | وَمَا بَيْنَهُمَا الرَّحْمٰنِ
ពីរវា ទៀតដែលមហាសាការុណ៍ | لَا يَمْلِكُونَ مِنْهُ خِطَابًا
គ្មានអំណាចទេ អ្នកទាំងអស់នោះក្នុងការ
ឆ្លើយឆ្លង អំពីទ្រង់ ។

៣៨. នៅថ្ងៃដែលកំពូលទេវតាជីព្រាអ៊ីល ហើយ | يَوْمَ يَقُومُ الرُّوحُ وَالْمَلٰئِكَةُ ٣٨
និងពពួកទេវៈ(ملك) ជាជួរៗ | صَفًّا لَا يَتَكَلَّمُونَ إِلَّا مَنْ
អ្នកទាំងអស់នោះ គ្មាននិយាយស្ដីទេ | أَذِنَ لَهُ الرَّحْمٰنُ وَقَالَ
លើកលែងតែ នរណាៗដែលបានអនុញ្ញាត | صَوَابًا
ហើយជំពោះថា ម្ចាស់ដ៏មហាសាការុណ៍
ដើម្បីវា (មនុស្សលោក) បាននិយាយ ដោយ
ត្រឹមត្រូវ ។

៣៩. នោះហើយជាថ្ងៃដែលពិតប្រាកដ ذَٰلِكَ الْيَوْمُ الْحَقُّ فَمَن شَاءَ ٣٩
ដើម្បីបានជា នរណាៗដែលមានគោលបំណង اتَّخَذَ إِلَىٰ رَبِّهِ مَآبًا
ចង់យកផ្លូវ ធ្វើដំណើរឆ្ពោះទៅ ម្ចាស់របស់
គាត់ ប្រាកដជាគាត់ បានជួប កន្លែងដែលល្អ
ប្រពៃ ។

៤០ ពិតប្រាកដ យើងបានព្រមាន ហើយអ្នកទាំង إِنَّا أَنذَرْنَاكُمْ عَذَابًا ٤٠
អស់គ្នា នឹង ទារុណកម្ម នោះជិតមកដល់ហើយ قَرِيبًا يَوْمَ يَنظُرُ الْمَرْءُ
នៅថ្ងៃនោះ មនុស្សលោក បានឃើញអ្វីៗដែល مَا قَدَّمَتْ يَدَاهُ وَيَقُولُ
គេបានប្រព្រឹត្ត ហើយសំពីអំពើដើម الْكَافِرُ يَا لَيْتَنِي كُنتُ تُرَابًا
របស់គេ ហើយ អ្នកដែលគ្មានជំនឿ
បានពោលថា ឱ! វាស្តា អញហើយ មាន
សំណាងហើយអញ បើប្រសិនណា កាលពី
មុនខ្លួនអញ ក្លាយទៅជាធូលី ។

បិតកថាវគ្គ ១៨ (النبأ) បានបញ្ជាក់ អំពីបណ្តាអ្នកមុសរិកីន ដែលបាន
ចម្ងល់ ដំណោះថ្ងៃ ដែលគេបានបង្កើតមនុស្សលោកឡើងវិញ ហើយ
និយាយ ការប្រមាថមើលងាយ របស់ ពួកគេ ទៅលើ អាកម្មមវិបាក អ្នកទាំងនេះៗ
- គេដាក់ទារុណកម្ម ទៅដល់ អ្នក មុសរិកីន (مشركين) ។
- ហើយ គេផ្តល់សេចក្តីសុខ ទៅដល់បណ្តា អ្នកដែល
មានជំនឿ ទៅថ្ងៃ បរលោក (قيامة) នោះ ។

មាតិការៀបរៀងនៃអត្ថបទនានា

លេខរៀង	ឈ្មោះអត្ថបទផ្សេងៗ		លេខទំព័រ
១	អាល់គួរអានប្រែសម្រួលជាភាសាខ្មែរ		5
២	កថាមុខ		7
៣	របាយការណ៍និងសមាសភាពរបស់ក្រុមរៀបរៀងបកប្រែសម្រួលអាល់គួរអាន		19
៤	សេចក្តីគាំទ្រ អំពី ស្ថានទូតនិង ([illegible]) ផងដែរ		21
៥	ប្រវត្តិអាល់គួរអាន (القرآن)		28
៦	បណ្តាឈ្មោះ អាល់គួរអាន		35
៧	ដំណើរបើកនៃការសូត្រ		37
៨	ការបើកកថាវត្ថុ, សេចក្តីផ្តើម		41
៩	វគ្គ ការបើកកថាវត្ថុ	سورة الفاتحة	43
១០	កថាវត្ថុ, វគ្គមនុស្សលោក និងការប្រែសម្រួល	سورة الناس	45
១១	កថាវត្ថុ, វគ្គភាពភ្លឺរៀបភ្លឺ និងការប្រែសម្រួល	سورة الفلق	47
១២	កថាវត្ថុ, វគ្គ ការស្មោះត្រង់ និងការប្រែសម្រួល	سورة الاخلاص	49
១៣	កថាវត្ថុ, វគ្គអណ្តាតភ្លើងនិងការប្រែសម្រួល	سورة اللهب	51
១៤	កថាវត្ថុ, វគ្គ ជំនួយនិងការប្រែសម្រួល	سورة النصر	53
១៥	កថាវត្ថុ, វគ្គបណ្តាអ្នកគ្មានជំនឿ, និងការប្រែសម្រួល	سورة الكافرون	55
១៦	កថាវត្ថុ, វគ្គស្រះស្រស់ពោរពេញទៅដោយវត្ថុ ក្នុងឋានសួគ៌ា និងការប្រែសម្រួល	سورة الكوثر	57
១៧	កថាវត្ថុ, វគ្គ របស់របរសំរាប់ប្រើប្រាស់ និងការប្រែសម្រួល	سورة الماعون	59

លេខរៀង	ឈ្មោះអត្ថបទមេរៀនផ្សេងៗ		លេខទំព័រ
១៨	ភជាវគ្គ, វគ្គបណ្ដាត្រកូលគូរ៉ៃស និងការប្រែសម្រួល	سورة قريش	61
១៩	ភជាវគ្គ, វគ្គដំរី និងការប្រែសម្រួល	سورة الفيل	63
២០	ភជាវគ្គ, វគ្គ ពួកនិយាយដើមគេ និងការប្រែសម្រួល	سورة الهمزة	65
២១	ភជាវគ្គ, វគ្គ ពេលវេលា និងការប្រែសម្រួល	سورة العصر	69
២២	ភជាវគ្គ, វគ្គ ការលើកដំកើងខ្លួន និងការប្រែសម្រួល	سورة التكاثر	70
២៣	ភជាវគ្គ, វគ្គ ថ្ងៃជោះកាល និងការប្រែសម្រួល	سورة القارعة	73
២៤	ភជាវគ្គ, វគ្គ ហ្វូងសត្វសេះដែលរត់យ៉ាងលឿនក្នុងសង្គ្រាម និងការប្រែសម្រួល	سورة العٰديٰت	76
២៥	ភជាវគ្គ, វគ្គ ការរំជួយ និងការប្រែសម្រួល	سورة الزلزلة	79
២៦	ភជាវគ្គ, វគ្គ ភស្តុតាងដ៏ច្បាស់លាស់ និងការប្រែសម្រួល	سورة البينة	82
២៧	ភជាវគ្គ, វគ្គ [illegible] និងការប្រែសម្រួល	سورة القدر	86
២៨	ភជាវគ្គ, វគ្គ សាច់ឈាមមួយដុំ និងការប្រែសម្រួល	سورة العلق	88
២៩	ភជាវគ្គ, វគ្គ ផ្លែទីន និងការប្រែសម្រួល	سورة التين	93
៣០	ភជាវគ្គ, វគ្គ ការទូលំទូលាយ និងការប្រែសម្រួល	سورة الانشراح	95
៣១	ភជាវគ្គ, វគ្គពេលព្រឹកពេញពន្លឺ និងការប្រែសម្រួល	سورة الضحى	97
៣២	ភជាវគ្គ, វគ្គ ពេលរាត្រី និងការប្រែសម្រួល	سورة الليل	100
៣៣	ភជាវគ្គ, វគ្គព្រះអាទិត្យ និងការប្រែសម្រួល	سورة الشمس	105

លេខរៀង	ឈ្មោះអត្ថបទពន្យល់		លេខទំព័រ
៣៤	គហាវគ្គ, វគ្គ ស្រុក និងការប្រែសំរួល	سورة البلد	109
៣៥	គហាវគ្គ, វគ្គ ពេលពន្លឺព្រះអាទិត្យ រៀបនឹងរះ និងការប្រែសំរួល	سورة الفجر	113
៣៦	គហាវគ្គ, វគ្គ ថ្ងៃបរលោក និងការ ប្រែសំរួល	سورة الغاشية	119
៣៧	គហាវគ្គ, វគ្គ ម្ចាស់ដ៏មហាខ្ពង់ខ្ពស់ និងការប្រែសំរួល	سورة الأعلى	124
៣៨	គហាវគ្គ, វគ្គ ផ្កាយដែលមានពន្លឺ ពេលរាត្រី	سورة الطارق	128
៣៩	គហាវគ្គ, វគ្គ កន្លែងផ្កាយនិងការប្រែសំរួល	سورة البروج	132
៤០	គហាវគ្គ, វគ្គ ការផ្ទាក់បែក និងការ ប្រែសំរួល	سورة الانشقاق	137
៤១	គហាវគ្គ, វគ្គ អ្នកកេងប្រវ័ញ្ច និងការ ប្រែសំរួល	سورة المطففين	142
៤២	គហាវគ្គ, វគ្គ ការបែកខ្ទេច និងការ ប្រែសំរួល	سورة الانفطار	148
៤៣	គហាវគ្គ, វគ្គ ការមូរក្ដិ និងការប្រែសំរួល	سورة التكوير	153
៤៤	គហាវគ្គ, វគ្គ ការញញើមុខ និងការ ប្រែសំរួល	سورة عبس	158
៤៥	គហាវគ្គ, វគ្គ មនុស្សខ្លាំង និងការប្រែសំរួល	سورة النازعات	165
៤៦	គហាវគ្គ, វគ្គ ពត៌មានដ៏សំខាន់ និងការ ប្រែសំរួល	سورة النبأ	173

សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់ អស់លោក និងបងប្អូន [illegible] ជាទីស្នេហាទាំងឡាយ សូមរង់ចាំអានភាគ២ ពាក្យខ្លះៗទៀត រាប់ពីអាល់គួរអាន ពាក្យពេចន៍ដែលខ្ញុំនិងខំខ្នះខ្នែងបកប្រែសម្រួល [illegible] ហើយនិងអក្ខរាវិរុទ្ធដដែលៗទៀត ក្នុងជំពូកសាសនា [illegible] បញ្ចប់ រាប់ពីការប្រែសម្រួល អាល់គួរអាន តាមអាយ៉ាត់ ([illegible]) នេះ ។

អ៊ិនសាអល់ឡោះ ។

والله ولي التوفيق •

والسلام عليكم ورحمة الله وبركاته •

International Islamic Federation of Student Organizations

P. O. BOX 8631

SALIMIAH - KUWAIT 22057